# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣១ លេខ ៣ ខែមីនា

ព.ស. ២៥០១ គ.ស. ១៩៥៩

ភ្នំពេញ

ក.165

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា — បញ្ជីរឿង — ទំព័រ

- វិសារជ្ជករណធម៌ របស់ព្រះមហា សុខ-ប៊ួរ . . . . . . . . . ២៣៩
- កិលេសធម៌ របស់ព្រះមហា វើក-ភឹម . . . . . . . . . . ២៥៦
- សុវណ្ណជាតក ( តមក ) លោក ថង-វង ចម្លងពីសាស្ត្រស្លឹករឹត . . . ២៦៤

ផ្នែកអក្សរសាស្ត្រ

- អត្ថន័យនៃការសិក្សា លោក ស៊ិន-ហ៊ាន រៀបរៀង. . . . . . . ២៨៤
- រឿងសព្វសិទ្ធិ របស់ ហ្លួងភក្ដីអក្សរ គង់ លោក ប៊ូ-ប៊ូ ចម្លងពីសាស្ត្រស្លឹករឹត . ២៩០
- និទានចៅកាំបិតល្ហោល លោក ម៉ុន-អេង រៀបរៀង. . . . . . ៣១១
- សុភាសិតជាតិស៊ីរីនិងលីបង់ (តចប់) លោក ភ៉ុយ-ប៊ុក ប្រែរៀបរៀង. . . . ៣២៥
- រឿងសាមកុក (តមក) ឧកញ៉ា នូ-កន ប្រែ . . . . . . . . ៣២៨
- ដើមកំណើតរបាំ លោក ស៊ិន-ហ៊ាន រៀបរៀង . . . . . . . . ៣៣៨

ផ្នែកកំណត់និងប្រវត្តិការណ៍

- ពិធីបុណ្យពុទ្ធជយន្តី ប្រទេសជប៉ុន . . . . . . . . . ៣៤៧
- ពត៌មានផ្សេង ៗ របស់ក្រសួងធម្មការ . . . . . . . . . ៣៥០
- វចនានុក្រមសំស្ក្រឹត-ខ្មែរ ( តមក ) ព្រះមហា ប៉ាង-ខាត់ រៀបរៀង. . . . . ៣៥២

មួយឆ្នាំមាន ១២ សៀវភៅ ដំឡៃជារ ២៣០៛០០

# KAMBUJASURIYA

Revue religieuse et litteraire
éditée par l'Institut Bouddhique

## sommaire

### Partie religieuse :


-Vesârajjakaranadhamma par Preah Moha SOK-YOU . . . . 239

-Kilesadhamma par Preah Moha VŒUK-PHIM. . . . . . 256

-Surabajataka relevé du manuscrit sur
feuilles de latanier par M. THANG VONG . . . 264


### Partie littéraire :


-L'Utilité de l'Instruction par M. SIN-HEAN. . . . . . . 284

-Histoire de Sabbasiddhi ( suite ) par Phakdei Aksar TAN revue
et corrigée par M. BOU-PO . . . . . . . . . . 290

-Légende d'un couteau (mâle) par M MAN-ENG . . . . 311

-Proverbes syriens et libanais traduits par M. RAY-BUC . . 325

-Histoire de Sam Kok (suite) par M. NOU-KAN . . . . 328

-L'Origine du Théâtre et de la Danse par M. SIN-HEAN . . 338


### Notes et Chroniques :


-La Fête du Buddha Jayanti au Japon . . . . . . . 347

-Nouvelles diverses du Ministère des Cultes . . . . . . . 350

-Dictionnaire Sanskrit-Khmer (suite) par vén. PANG KHAT . . 352



Prix d'abonnement annuel (comprenant 12 numéros : 230$00 .

# សព្ទសាធុការពរឆ្នាំថ្មី

| | |
|---|---|
| ឆ្នាំកុរឯកស័កថ្មីដ៏លើសលុប | ព.ស. គម្រប់ពីរពាន់ប្រាំ· |
| រយមួយប្រាំកដតាមចំណាំ | ខែចេត្រចូលឆ្នាំថ្មីក្បែរកក្តិ ១ |
| ក្រុមពុទ្ធសាសនបណ្ឌិត្យ | ប្រសិទ្ធិពរថ្វាយ-ជូនសព្វបាន : |
| –សូមជាតិសាសនាមហាក្សត្រក្រក្តិ | ថ្កើងថ្កានបានសុខនិទ្ទិកា ! |
| –សូមព្រះឧបតីពីរអគ្គក្សត្រ | សោយរាជសម្បត្តិដ៏ខេមរ |
| ទ្រង់មានព្រះជន្មាយុវែង | មានរិទ្ធិបេស្កាថ្កើងសីហនាទ ! |
| –សូមអគ្គសម្តេចព្រះបិតា | ឯកពង្សសះជាព្រះគារពារ |
| ដើម្បីទ្រង់នាំខេមរជាតិ | ឲ្យឃ្លាតទីទាបឡើងខ្ពស់ខ្ពង់ ! |
| –សូមក្រុមព្រះញាតិវង្ស | បានគង់សុខាគ្រប់ព្រះអង្គ |
| ចំរើនសិរីរឿងរុង | ទ្រទ្រង់សក្តាមហាសួស្តី ! |
| –សូមព្រះរាជរដ្ឋាភិបាល | បានសុខក្សេមក្រោលកលអប្រិយ |
| បំពេញកិច្ចការកែតផែនដី | បានស្រីសួស្តីសុខសាន្តត្រាណ ! |
| –សូមពួកមន្ត្រីគ្រប់ក្រសួង | ធំ តូចទាំងពួងអម្បាលម៉ាន |
| មានសុខចំរើនគ្រប់ៗប្រាណ | ស្មោះស្មានបំរើកម្ពុជា ! |
| –សូមក្រុមព្រះសង្ឃបវរកល្យាណ | ដែលបានព្រមព្រៀងរួមរក្សា |
| ទ្រធម៌វិន័យពុទ្ធសាសនា | រួបរួមគ្នាគ្រប់អង្គកាយ ! |
| –សូមសន្តិសុខស្ងប់ក្រៃលែង | កើតមានជាក់ស្តែងសុខសប្បាយ |
| ដល់ពួកពលរដ្ឋផងទាំងឡាយ | ស្រស់ស្រាយក្រោមម្លប់រាជបល្ល័ង្ក! |

ពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា

# វេសារជ្ជករណធម៌

## ធម៌សម្រាប់ធ្វើសេចក្ដីក្លាហាន

ព្រះមហាសុខ-ប៊ួរ វិជ្ជុណ្ណលោម រៀបរៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៗ

សូមនមស្ការចំពោះព្រះអរហន្តសម្មាសម្ពុទ្ធវិសុទ្ធិគុណ ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ ដោយគោរព ។

វេលានេះ សូមលើកយកគន្លង នៃធម៌សម្រាប់ធ្វើសេចក្ដីក្លាហាន មានសេចក្ដីដូចតទៅនេះ :

ពាក្យថា វេសារជ្ជករណធម៌ ធម៌ធ្វើសេចក្ដីក្លាហាន ចែកចេញជា ៥ យ៉ាងគឺ

១– សទ្ធា ការជឿរបស់ដែលគួរជឿ,

២– សីល ការរក្សាកាយ វាចា ឲ្យរាបសា,

៣– ពាហុសច្ច ការជាបុគ្គលសិក្សាច្រើន,

៤– វីរិយារម្ភៈ ប្រារព្ធសេចក្ដីព្យាយាម,

៥– បញ្ញា សេចក្ដីដឹងតាមពិត ។

ធម៌ទាំង ៤ យ៉ាងនេះ តាំងនៅក្នុងបុគ្គលណា បុគ្គលនោះតែងមានសេចក្តីក្លាហានអង់អាច មានសមត្ថភាពក្នុងទីទាំងពួងជានិច្ច ពោះបីបុគ្គលនោះចូលទៅកាន់ទីប្រជុំតូចក្តី ធំក្តី ក៏ឥតមានសេចក្តីតក់ស្លុតរន្ធត់ញាប់ញ័រដោយហេតុណាមួយឡើយ ជាធម៌សម្រាប់ការពារភ័យទាំងអស់មានទុគ្គតិភ័យជាដើម ។

សូមលើកយកអត្ថបទទាំង ៤ យ៉ាងនោះ មកសំដែងមួយម្តង ៗ ជាលំដាប់តទៅ :

១- ពាក្យថា សទ្ធា ប្រែថា ជំនឿ គឺជឿរបស់ដែលគួរជឿ សទ្ធាក្នុងទីនេះ បានសេចក្តីថា ជឿកម្មនិងផលរបស់កម្ម ជឿដោយមានហេតុ-ផល ដូចជឿថា ផលអាក្រក់កើតមកអំពីអកុសលកម្មជាហេតុ ផលល្អកើតមកអំពីកុសលកម្មជាហេតុ បុគ្គលធ្វើនូវកម្មណា កម្មនោះឈ្មោះថាជាហេតុ តែងឲ្យផលដល់សាមីខ្លួនអ្នកធ្វើ គឺថាអំពើល្អនិងអំពើអាក្រក់របស់បុគ្គលនោះជាមូលហេតុ ហើយតែងឲ្យផលដល់បុគ្គលអ្នកធ្វើវិញ គឺថាកម្មជាអ្នកចែកសត្វឲ្យអាក្រក់ល្អ សមដូចបាលីថា កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ កម្មគឺអំពើតែងចែងចែកឲ្យសត្វថោកទាប ខ្ពង់ខ្ពស់ ។ សត្វត្រូវតែទទួលនូវផលដែលខ្លួនធ្វើជាធម្មតា ការជឿបែបនេះទើបឈ្មោះថា ជឿរបស់ដែលគួរជឿ បើជឿក្រៅពីនេះដូចជឿថា សេចក្តីអង្វរករបន់ស្រន់ចំពោះវត្ថុទៃ គឺអារក្ស

អ្នកតា បង់បត់ ដុំថ្ម ដុំដី ឈើព្រៃផ្សេងៗ ថា តែសក្តិសិទ្ធិអាចសម្រេចសេចក្តីសុខចំរើនដល់ខ្លួន មិនហៅថា ជឿរបស់ដែលគួរជឿទេ ព្រោះសេចក្តីសុខចំរើនសព្វបែបសព្វយ៉ាង គ្មានបុគ្គលបន់ស្រន់អង្វរបាន ដោយមិនបាច់ធ្វើនោះទេ បើជាបន់ស្រន់អង្វរគេបានមែននោះ មនុស្សសត្វគ្រប់ប្រភេទ ប្រហែលជាបានសេចក្តីសុខចំរើន ដោយបន់ស្រន់ឲ្យកើតនៅឋានសួគ៌ ព្រហ្ម ព្រះនិព្វាន គ្មានសល់ម្នាក់ឡើយ សូម្បីការងារក្នុងលោកសព្វថ្ងៃនេះ លុះតែខំប្រឹងធ្វើ ទើបបានទទួលលទ្ធផល បើមិនធ្វើទេ ហើយចាំតែបន់ស្រន់នោះ គ្មានបានទទួលលទ្ធផលឡើយ ។

សទ្ធានេះមានច្រើនប្រភេទ តែក្នុងទីនេះចែកដោយសង្ខេបមានពីរយ៉ាងគឺ លោកិយសទ្ធា ១ លោកុត្តរសទ្ធា ១ ។ លោកិយសទ្ធាបានដល់ការជឿត្រឹមត្រូវតាមលទ្ធិព្រះពុទ្ធសាសនា តែសទ្ធានោះមិនទាន់បានសម្រេចគុណវិសេស មានសោតាបត្តិមគ្គជាដើម ដល់បុគ្គលអ្នកធ្វើនោះទេ ព្រោះសន្តានចិត្តបុគ្គលជាបុថុជ្ជន ក្រាស់ដោយកិលេសដែលញាំញីជះជាន់សន្តតិសន្តាននៅក្នុងភព មិនទាន់លាស់រួចអំពីភពទាំង៣នៅឡើយ ទើបបានឈ្មោះថា លោកិយសទ្ធា ។ ឯលោកុត្តរសទ្ធានោះបានដល់សទ្ធារបស់អរិយបុគ្គលទាំង ៨ ពួក មានសោតាបន្នបុគ្គលជាដើម លោកខំប្រឹងប្រែងបំពេញវត្តបដិបត្តិគឺ សីល សមាធិ បញ្ញា ឲ្យមាននៅក្នុងខន្ធសន្តានគ្រប់គ្រាន់ហើយ កំចាត់បង់បាននូវកិលេស

សេចក្តីសៅហ្មង ដែលកើតអំពីចិត្តឲ្យផុតស្រឡះស្រឡាំហើយ ឈ្មោះថា បុគ្គលដូនរំលងនូវភពទាំង ៣ បាន ទាំងយកព្រះនិព្វានជាអារម្មណ៍ ហៅថា លោកុត្តរសទ្ធា ។

សទ្ធាមានឈ្មោះហៅបានច្រើនយ៉ាងគឺ មានក្នុងពលធម៌ ៥ ហៅថា សទ្ធាពលំ កម្លាំងគឺសទ្ធា, មានក្នុងអរិយទ្រព្យ ៧ ហៅថា សទ្ធាធនំ សទ្ធាជាទ្រព្យ ។ សទ្ធាយ តរតិ ឱឃំ បុគ្គលឆ្លងអន្លង់ទាំង ៤ គឺ កាមោឃៈ អន្លង់គឺកាម, ភវោឃៈ អន្លង់គឺភព, ទិដ្ឋោឃៈ អន្លង់គឺទិដ្ឋិ, អវិជ្ជោឃៈ អន្លង់គឺអវិជ្ជា ទៅបានដោយសារសទ្ធាដែរ ។ សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ សទ្ធាទុកជាទ្រព្យដ៏ប្រសើររបស់បុរសស្ត្រីក្នុងលោក បុគ្គលក្នុងលោកគ្រប់ប្រភេទ ដែលបំពេញករណីយកិច្ចទាំងផ្លូវធម៌ក្តី ផ្លូវលោកក្តី អាចសម្រេចប្រយោជន៍បានតាមបំណង ក៏ព្រោះអាស្រ័យសទ្ធាជាមេដឹកនាំផ្លូវដែរ បើប្រាសចាកសទ្ធាហើយ ក៏មិនអាចនឹងញ៉ាំងប្រយោជន៍ណាមួយ ឲ្យសម្រេចដល់ខ្លួនឡើយ ។

បណ្តាចេតសិកធម៌ទាំង ២៥ ក៏មានសទ្ធាជាដើម ញ៉ាំងចេតសិកធម៌ដទៃឲ្យសម្រេចតាមបំណងខ្លួន ។

ក្នុងសម័យបច្ចុប្បន្ននេះ ពួកពុទ្ធបរិស័ទគ្រប់ប្រភេទ បញ្ចេញសទ្ធាសេចក្តីជ្រះថ្លាដ៏មុះមុតរបស់ខ្លួន គឺជឿចំពោះលទ្ធិព្រះពុទ្ធសាសនា ដើម្បីជួយឧបត្ថម្ភទំនុកបំរុងមន្ទីរពេទ្យ សម្រាប់ព្យាបាលព្រះសង្ឃពុទ្ធសាសនិក

ដែលមានអាពាធ ត្រូវប្រគល់រាងកាយលោកទាំងមូល ជូនលោកគ្រូពេទ្យព្យាបាលឲ្យ ។

តែឥឡូវនេះ មន្ទីរពេទ្យព្រះសង្ឃអាចទទួលព្រះសង្ឃ ដែលមានអាពាធនោះបានចំនួនតែ ៥០ អង្គទេ ឯកន្លែងសម្រាប់ព្រះសង្ឃសឹងនោះមានសព្វគ្រប់ហើយ សឹងបាន ១០០ អង្គក៏បានដែរ តែនៅខ្វះឱសថគឺថ្នាំសម្រាប់តែពេលនោះ ពុំគ្រប់គ្រាន់ ព្រោះថវិកាសមាគមគិលានសង្គ្រោះមានកម្លាំងខ្សោយណាស់ ។

ព្រោះហេតុនោះ សូមអស់លោកអ្នកពុទ្ធបរិស័ទ ជួយផ្តល់សមាគមមន្ទីរពេទ្យព្យាបាលព្រះសង្ឃ ដែលមានអាពាធនោះឲ្យមានកម្លាំងពេញលក្ខណៈ ទាំងស្បៀងអាហារទាំងថ្នាំតែពេលតទៅទៀត ដើម្បីនឹងទទួលព្រះសង្ឃដែលមានអាពាធ ឲ្យចូលព្យាបាលបានរាប់រយអង្គ ព្រោះគ្រឹះស្ថានមន្ទីរពេទ្យព្យាបាលព្រះសង្ឃនេះ សូមអស់លោកអ្នកពុទ្ធបរិស័ទគ្រប់ឋានៈជ្រាបថា មន្ទីរពេទ្យនេះ មិនមែនជាគ្រឹះស្ថានសម្រាប់ឯកជន យកចំណេញម្នាក់ៗ ដូចសមាគមឯទៀតៗទេ គឺជាគ្រឹះស្ថានរបស់ពុទ្ធបរិស័ទគ្រប់ភេទទាំងប្រទេស គឺព្រះរាជអាណាចក្រកម្ពុជា ដោយគោលបំណងគឺផលបុណ្យកុសលតែម្យ៉ាង មានព្រះមហាក្សត្រជាប្រធាន ទ្រង់ចំណាយព្រះរាជទ្រព្យជួយឧបត្ថម្ភជាបដរាបសព្វថ្ងៃនេះ ព្រោះទ្រង់សព្វព្រះរាជហឫទ័យនឹងព្រះរាជកុសលនេះណាស់ ។

ឯការជួយផ្តល់កម្លាំងសមាគមនោះ គឺជួយជាបច្ច័យបង់ប្រចាំខែ ១០ រៀលក្តី ២០ រៀលក្តី ៥០ រៀលក្តី ១០០ រៀលក្តី ក៏សមាគមទទួលដោយត្រេកអរទាំងអស់ ឬក៏ជួយផ្តល់ខាងគ្រឿងឧបភោគបរិភោគ មានសំពត់ស្រង់ទឹកសម្រាប់ព្រះសង្ឃអាពាធប្រើប្រាស់ក្តី ឧស អង្ករ ថូទឹក កែវ ចាន ពែង ចាន ស្លាបព្រាជាដើមក្តី ក៏សមាគមទទួលយកប្រើការសម្រាប់ព្រះសង្ឃអាពាធបានទាំងអស់ ។

អស់លោក-អ្នកពុទ្ធបរិស័ទដែលមានសទ្ធា គួរជួយឧបត្ថម្ភមន្ទីរពេទ្យព្យាបាលរោគព្រះសង្ឃដែលមានកម្លាំងខ្សោយនេះ ឲ្យមានកម្លាំងជាស្ថាពរមាំទាំឡើង ព្រោះសមាគមគ្មានអ្វីពឹងទេ មានតែពឹងលើពុទ្ធបរិស័ទទាំងឡាយនេះទេ ទើបសមាគមមានអាយុជីវិតរស់នៅបាន បើពុទ្ធបរិស័ទមិនជួយឧបត្ថម្ភទេ សមាគមមុខជាទន់ខ្សោយមិនខាន ។ សមាគមនេះជាមធ្យោបាយដោះស្រាយជម្ងឺកាត់នៃព្រះសង្ឃ ដែលមានអាពាធមុខជាមានជីវិតដោយលំបាក ព្រោះរោគចូលមកញាំញីមិនខាន ។

ទីបំផុតនេះ សមាគមមានសេចក្តីសង្ឃឹមលើពុទ្ធបរិស័ទទាំងបព្វជិតគ្រហស្ថ មុខជានឹងឧបត្ថម្ភឲ្យមានកម្លាំងពេញលក្ខណៈ ដើម្បីជាកុសលផ្តល់ខ្លួនដោយសទ្ធាជ្រះមុតពុំខាន ។

សទ្ធានេះចាត់ជាវេសារជ្ជករណធម៌ទី ១ ។

២-- សីលៈ ការរក្សាកាយ វាចា ឲ្យរាបសា បានដល់ចេតនាវៀរ

ចាកអំពើទុច្ចរិតគឺការប្រព្រឹត្តអាក្រក់ដោយកាយ មាន ៣ គឺ ការសម្លាប់សត្វ ឬមនុស្ស ១ ការលួចឆក់ដណ្តើមប្រវ័ញ្ចទ្រព្យសម្បត្តិអ្នកដទៃយកមកធ្វើជាទ្រព្យសម្បត្តិរបស់ខ្លួន ១ ការប្រព្រឹត្តកន្លងប្រវេណីគឺកូនប្រពន្ធរបស់បុគ្គលដទៃ ដែលគេហួងហែងរក្សាគ្រប់គ្រងឲ្យមានបរិយាមារយាទសណ្តាប់ធ្នាប់ត្រឹមត្រូវ ១ ។

វាចា វៀរចាកសំដីខុស ឬអាក្រក់ ៤ យ៉ាងគឺ

មុសាវាទ ពោលពាក្យកុហកកូតករគឺមិនពិតមិនទៀងត្រង់ និយាយបំផ្លើសឲ្យលើស របស់តិចទៅជាច្រើន របស់តូចទៅជាធំ របស់ល្មមឲ្យទៅជាណាស់ ឬដោយប្រាថ្នានិសេចលេងសប្បាយ ១ ។

បិសុណវាចា ពោលពាក្យញុះញង់សិកសៀតបំបែកបំបាក់បុគ្គលដទៃឲ្យបែកបាក់ព្រាត់ប្រាស់គ្នា ១ ។

ផរុសវាចា សំដៅយកត្រង់សំដីទ្រគោះបោះបោក ឬ សំដីញេចញើជិះជាន់ធ្វើឲ្យគេអាប់មុខអាប់កេរ្តិ៍ឈ្មោះ ដោយសារសំដីរបស់ខ្លួនណាមួយ ពុំនោះបើវាចាផ្អែមល្ហែម តែចិត្តអាក្រក់ក៏ហៅថា ផរុសវាចាដែរ ព្រោះសំដីអាក្រក់ចេញមកអំពីចិត្តអាក្រក់ ១ ។

សម្ផប្បលាបៈ និយាយពាក្យពេយពាយគ្មានបានផលប្រយោជន៍អ្វីអំពីការនិយាយ គឺនិយាយមិនតាំងចិត្តគំនិតឲ្យអ្នកស្តាប់ចូលចិត្តចង់ស្តាប់

ឬថាលើកពាក្យឡើងនិយាយគ្រាន់តែបញ្ចើចបញ្ចើគេ គ្មានផលប្រយោជន៍ក្នុងលោកនិងក្នុងធម៌ ១ នេះចាត់ជាអំពើដែលត្រូវវៀរដោយវាចា ការរក្សាកាយវាចាឲ្យរាបសាឈ្មោះថា សីល ។

សីល: ចែកជាច្រើនប្រភេទគឺ និច្ចសីល ឧបោសថសីល អតិរេក-សីល ចតុប្បារិសុទ្ធិសីល ។ តែសីលក្នុងទីនេះ សូមចែកដោយសង្ខេប មាន ២ យ៉ាងគឺ លោកិយសីល សីលជាលោកិយ ១ លោកុត្តរសីល សីលជាលោកុត្តរ ១ ។ លោកិយសីល បានដល់សីលរបស់បុគ្គលបុថុជ្ជន ដែលបានសិក្សាចេះដឹង ហើយប្រព្រឹត្តកាន់តាមក្បួនរបស់សីលនោះ ដោយត្រឹមត្រូវ តែមិនទាន់បានធ្វើកិលេសឲ្យខ្ចាត់ខ្ចាយទៅបាន ព្រោះខ្លួនជាបុថុជ្ជនក្រាស់ដោយកិលេសនៅឡើយ មិនទាន់អាចដើម្បីលោសខ្លួនចេញចាកភពទៅបាន ។ លោកុត្តរសីល បានដល់សីលរបស់ព្រះអរិយៈ ដែលលោកបានបំពេញវត្តប្រតិបត្តិពោលគឺ សីល សមាធិ បញ្ញា ដរាបដល់រលត់នូវភ្លើងទុក្ខភ្លើងកិលេស ហើយមានព្រះនិព្វានជាអារម្មណ៍ ហៅថា លោកុត្តរសីល ព្រោះសីលនេះអាចឆ្លងកាត់ភពទាំង ៣ គឺ កាមភព រូបភព អរូបភពទៅបាន ។

សីលបើនិយាយអំពីអត្ថ ដោយសង្ខេប មាន ២ យ៉ាងគឺ

ក) សមាទាន: អត្ថថា ផ្ទុកទុកខ្លួនកាយកម្មវាចាដើម្បីតាំងនៅល្អ មិនឲ្យពេកពាយកាយទៅផ្សេងៗ ដោយភាពដែលទ្រុស្តសីល ។

១) ឧបធារណា: អត្ថថា ជួលទៅទ្រទ្រង់ទុកនូវកុសលធម៌ទាំងពួង ។ ន័យមួយទៀតថា សីលនេះធៀបដូចផែនដី គឺផែនដីទទួលទ្រនូវវត្ថុមានវិញ្ញាណ ឥតវិញ្ញាណ ឬវត្ថុមានក្លិនអសោចិ៍ និងវត្ថុមានក្លិនល្អ ក៏មិនប្រកែក ឯសីលក៏ទទួលភារៈបើកសិទ្ធិសេរីភាពឲ្យពុទ្ធបរិស័ទកាន់បានគ្រប់ជាន់ថ្នាក់ ឥតឃាត់ឃាំងរារាំងអ្វីឡើយ ។ បុគ្គលណាមានសីលនៅក្នុងខ្លួនហើយ បុគ្គលនោះឈ្មោះថាមានផែនដីឈរ បើគ្មានសីលប្រភេទណាមួយនៅក្នុងខ្លួនទេ ក៏ឈ្មោះថា គ្មានផែនដីឈរដែរ ។

ហេតុនេះ គួរពុទ្ធបរិស័ទគ្រប់ប្រភេទ ខំប្រឹងធ្វើខ្លួនឲ្យជាអ្នកមានសីលឡើង បើបុគ្គលណាមានសទ្ធានិងសីលនៅក្នុងខន្ធសន្តាន បុគ្គលនោះ ទោះត្រាច់ទៅក្នុងទីណា ក៏តែងមានគេបូជា ថ្វាយ ប្រគេន ជូនក្នុងទីនោះដែរ សមដូចពុទ្ធភាសិតថា :

សទ្ធោ សីលេន សម្បន្នោ យសោភោគសមប្បិតោ
យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។

បុគ្គលមានសទ្ធាព្រមទាំងបរិបូរដោយសីល រមែងផ្អែកស្កប់ស្កល់ដោយយសនិងភោគៈ ទោះបីគប់រកនូវប្រទេសណា ៗ តែងមានគេបូជាក្នុងប្រទេសនិងទីនោះៗ ។ សីលនេះចាត់ជាវេសារជ្ជករណធម៌ ២ ។

៣ - ពាហុសច្ចៈ: ប្រែថា ភាវៈនៃបុគ្គលដែលបានរៀន បានស្តាប់ ចេះដឹងច្រើន ។

ពាហុសច្ចៈ បើតាមទេសនាវណ្ណនា សំដែងថាមានពីរប្រការគឺ

ក) បរិយត្តិពាហុសច្ចៈ ភាពជាពហុស្សូត ដោយបានរៀនព្រះបរិយត្តិ,

ខ) បដិវេធពាហុសច្ចៈ ភាពជាពហុស្សូត ដោយបានត្រាស់ដឹងមគ្គផល ។

បរិយត្តិពាហុសច្ចៈនេះ សូមពោលចំពោះធុរៈធម៌តែម្យ៉ាង ឯផ្លូវលោកមិនបានពោលដល់ ពីរជនណាសិក្សាស្វាធ្យាយព្រះបរិយត្តិ ដោយកម្លាំងវីរិយៈរបស់ខ្លួន រហូតដល់ចេះដឹងនូវនិកាយមួយក្តី ពីរក្តី បីក្តី បួនក្តី ប្រាំក្តី ពីរជននោះ ឈ្មោះថា ពហុស្សូត ផ្នែកខាងព្រះបរិយត្តិ ។ ម្យ៉ាងទៀត ការចំរើនកម្មដ្ឋានញយ ៗ ដោយការចេះស្ទាត់ហើយ ក៏ចាត់ថាជាពហុស្សូតដែរ ដូចអដ្ឋកថាធម្មបទខុទ្ទកនិកាយ ត្រង់ដកវគ្គវណ្ណនាថា អរិយកម្មដ្ឋានំ បន ឧគ្គហេត្វា អនុយុញ្ជន្តោ ពហុស្សុតោ បើបុគ្គលរៀនយកនូវកម្មដ្ឋានតិចតួច តែខំព្យាយាមចំរើនញយ ៗ បុគ្គលនោះឈ្មោះថា ជាពហុស្សូតដែរ ។

បដិវេធពាហុសច្ចៈ ភាពជាពហុស្សូត ដោយការត្រាស់ដឹងមគ្គផល សំដៅយកព្រះអរិយបុគ្គលដែលបានត្រាស់ដឹងមគ្គ ៤ ផល ៤ តែបណ្តាព្រះអរិយៈទាំងអស់ ដែលជាពហុស្សូតវិសេសបំផុត គឺព្រះអរហន្តដែលមានបដិសម្ភិទា ។ ឯព្រះអរហន្តសុក្ខវិបស្សកៈនោះ ពុំប្រសើរស្មើនឹងព្រះ-

អរហន្តដែលបានបដិសម្ភិទា ៤ ឡើយ ។

បដិសម្ភិទា ៤ នោះគឺ

១- អត្ថប្បដិសម្ភិទា សេចក្តីបែកធ្លាយចំពោះអត្ថ,

២- ធម្មប្បដិសម្ភិទា សេចក្តីបែកធ្លាយចំពោះធម៌,

៣ និរុត្តិប្បដិសម្ភិទា សេចក្តីបែកធ្លាយចំពោះភាសា ដែលសំដែងនូវអត្ថនិងធម៌,

៤- បដិភាណប្បដិសម្ភិទា សេចក្តីបែកធ្លាយ ដោយប្រាជ្ញាមិនទើសទាល់ ។

អស់លោកអ្នកសប្បុរសទាំងឡាយ ធ្លាប់បានឮមកហើយ ចំពោះពហុស្សូតថ្នាក់នេះ ដូចព្រះថេរៈទាំងឡាយ មានព្រះសារីបុត្តជាដើម ។

ពាហុសច្ចៈ ទាំងពីរប្រការ ឬដែលហៅថា បុគ្គលពហុស្សូតនោះ ក្នុងសម័យបច្ចុប្បន្ននេះ មានតែបរិយត្តិពាហុសច្ចៈមួយទេ គ្រាន់នឹងទីពឹង ។

ឯបដិវេធពាហុសច្ចៈ រលត់ហើយ តាំងពីក្នុងសតវត្សរ៍ទី ៩-១០ ម៉្លេះ ព្រោះមិនមានព្រះអរហន្ត បើទុកជាមានព្រះអរិយបុគ្គលខ្លះ ក៏ត្រឹមព្រះអរិយបុគ្គលថ្នាក់ទាប ។

ការសំដែងពណ៌នា អំពីពាហុសច្ចកថា ដោយខ្លី ៗ មកនេះ ដើម្បីជាសវនាការ នៃកល្យាណជនទាំងឡាយ ដែលមានមនោរថប្រាកដ

ប្រជា ធ្លាប់ជ្រាបអំពីពាហុសច្ចកថា ។ ពាហុសច្ចៈ មានសេចក្តីខ្លីៗ នេះ ចាត់ជាវេសារជ្ជករណធម៌ ទី ៣ ។

៤- ពាក្យថា វីរិយារម្ភៈ ប្រែថា ការប្រារព្ធនូវសេចក្តីព្យាយាម សេចក្តីប្រឹងប្រែងខ្មីឃ្មាត តាមបាលីហៅថា វីរិយៈ និង អារម្ភៈ សេចក្តីប្រារព្ធ ពាក្យទាំងពីរមកតភ្ជាប់គ្នាជាវីរិយារម្ភៈ ។

វីរិយារម្ភៈ ជាឈ្មោះនៃការប្រារព្ធចំពោះសេចក្តីព្យាយាម ដែលមានកម្លាំងក្លៀវក្លា ។ ពាក្យថា ព្យាយាម ខ្មែរយើងមានពាក្យវេវចនសព្ទ គឺសំដីនិយាយផ្លាស់ប្តូរជាច្រើនយ៉ាង ភាសាបាលីក៏មានវេវចនសព្ទច្រើនយ៉ាងដែរ ដូច វីរិយៈ ប្រាសចាកៈសេចក្តីទ្រោក បធានៈ សេចក្តីព្យាយាម វាយាមៈ ព្យាយាម ឬឈានទៅមុខ ឧស្សាហៈ ខ្មីឃ្មាត បរក្កមៈ ទទួប ទទៃ អដ្ឋិត មិនឈប់នៅ អប្បដិវាទិ មិនត្រឡប់ថយក្រោយ អនិក្ខិត្តឆន្ទតា មិនលះបង់សេចក្តីប្រាថ្នា អសិថិលបរក្កមតា ខំប្រឹងប្រែងមិនបន្ធូរបន្ថយ អនិក្ខិត្តធុរតា មិនដាក់ធុរៈចោល ។

សេចក្តីក្រវើនក្រវេតខ្នះខ្នែងក្នុងកិច្ចការ មិនបណ្តែតបណ្តោយ មិនធ្វេសប្រហែសពាយឆាយ មិនខ្ជិល គឺមានភាពជាអ្នកស្រវាស្រទេញស្រឡាញ់ការងារ ដែលខ្លួនត្រូវធ្វើមិនខ្លាចលំបាក ខំប្រឹងកំចាត់បង់នូវកោសជ្ជៈ សេចក្តីខ្ជិលច្រអូសចោលចេញពីខន្ធសន្តានៗ ព្រោះថា កោសជ្ជៈនេះជាទំនាស់គ្នានឹងសេចក្តីព្យាយាម ទោះមានឧបសគ្គយ៉ាងណា ក៏មិនត្រូវ

ទំលាក់ការងារដែលខ្ជិលធ្វើនោះចោលឡើយ ។

វិរិយារម្ភៈ ការប្រារព្ធចំពោះសេចក្តីព្យាយាម ចែកចេញជា ៤ យ៉ាងគឺ:

១- សំវរវិរិយារម្ភៈ ប្រារព្ធសេចក្តីព្យាយាម ដោយប្រយ័ត្នមិនឲ្យបាបកើតឡើងក្នុងសន្តាន,

២ - បហានវិរិយារម្ភៈ ប្រារព្ធសេចក្តីព្យាយាម ដោះបង់បាបដែលកើតឡើងហើយ,

៣- ភាវនាវិរិយារម្ភៈ ប្រារព្ធសេចក្តីព្យាយាម ដោយញ៉ាំងកុសលឲ្យកើតឡើងក្នុងសន្តាន,

៤ - អនុរក្ខនាវិរិយារម្ភៈ ប្រារព្ធសេចក្តីព្យាយាម ដោយរក្សាទុកនូវកុសលដែលកើតឡើងហើយ មិនឲ្យសាបសូន្យទៅវិញ ។

សេចក្តីព្យាយាមទាំង ៤ យ៉ាងនេះជាធម៌ប្រពៃ គួរប្រកបឲ្យកើតមានក្នុងសន្តាន ។ អធិប្បាយថា សេចក្តីព្យាយាមមាន ២ យ៉ាងគឺព្យាយាមប្រព្រឹត្តទៅក្នុងផ្លូវកាយ ១ ប្រព្រឹត្តទៅក្នុងផ្លូវចិត្ត ១ តែសេចក្តីព្យាយាមក្នុងទីនេះ បំណងយកសេចក្តីព្យាយាមក្នុងផ្លូវចិត្ត គឺការដែលមិនក្រោចខ្ជិល មានស្មារតីប្រុងប្រយ័ត្នគ្រប់លក្ខណៈ ចាំហេតុទាំងពួងមិនក្រោចត្រចៀក ជាអ្នកមានកាយកម្មជាដើម ឥតទោសឥតកំហុស ឬថា ជាអ្នកធ្វើការទាំងពួងសំរិតសំរាំងឲ្យបានស្អាតល្អ ជាអ្នកពិចារណាមុនហើយទើបធ្វើ គឺការដែលខ្ជិលទៅស្មៀមៗ ក៏រមែងគិតទុកជាមុនថា បើហេតុដូច្នេះកើត

ឡើង អញ្ចឹងធ្វើយ៉ាងនេះ កាលបើគ្រោះពិបាកណាហើយទើបធ្វើគ្រប់កិច្ចការទាំងពួង ជាអ្នកសង្រួមកាយ វាចា ចិត្ត បំរុងប្រយ័ត្នមិនឲ្យទោសអាក្រក់កើតឡើងបាន ជាអ្នកចិញ្ចឹមជីវិតប្រកបដោយគន្លងធម៌ មានសេចក្តីប្រយ័ត្ន មិនគិតដល់សេចក្តីលំបាក ដោយហេតុណាមួយ យ៉ាងនេះហៅថា សំវរវិរិយារម្ភៈ ១ បើមានសេចក្តីភាំងភ្លាត់ក្នុងពេលខ្លះ ម្តងមួយកាល ព្រោះខ្លួនមានសតិមិនបរិបូណ៌ សេចក្តីអាក្រក់ ទោសកំហុស បានឱកាសកើតឡើង ក្នុងសន្តានបានហើយ មិនព្រងើយកន្តើយ បណ្តោយឲ្យសេចក្តីអាក្រក់នោះ កើតឡើងហួសកាលនោះទេ ក៏តាំងព្យាយាមដើម្បីកំចាត់បង់នូវអកុសល ដែលកើតឡើងនោះ ឲ្យឃ្លាតឆ្ងាយពីខ្លួនសន្តាន យ៉ាងនេះហៅថា បហានវិរិយារម្ភៈ ១ សេចក្តីព្យាយាមអប់រំបំពេញកុសលឲ្យកើតឡើង គឺសេចក្តីល្អដទៃៗ ឲ្យមានច្រើនក្នុងសន្តាន ដោយឧបាយផ្សេងៗ ស្រេចហើយតែកុសលកើតមានឡើង ដោយឧបាយយ៉ាងណា ក៏ខំព្យាយាមអប់រំ ដោយឧបាយយ៉ាងនោះ យ៉ាងនេះហៅថា ភាវនាវិរិយារម្ភៈ ១ ការប្រារព្ធចំពោះសេចក្តីព្យាយាមរក្សាកុសល ដែលខ្លួនបានអប់រំឲ្យកើតឡើង ក្នុងសន្តានហើយ ក៏ខំព្យាយាមមិនឲ្យកុសលនោះសាបសូន្យទៅវិញ ហៅថា អនុរក្ខនាវិរិយារម្ភៈ ចាត់ជាវេសារជ្ជករណធម៌ទី៤ ។

៥- បញ្ញា ប្រែថា ដឹងទូទៅ វិសេសជាងសញ្ញានិងវិញ្ញាណ ។ បញ្ញានេះចាត់ជាលំអងចុងនៃព្រះពុទ្ធសាសនា ដែលហៅថា បរិយោ-

សានគល្យាណំ មានលំអានចុង ៗ យ៉ាងទៀត គួរនឹងកាំនាំង៣ យ៉ាង គ្រង់ទ្រង់ទី ៣ ថា សចិត្តបរិយោទបនំ ឲ្យជុះទាត់សន្តានចិត្តឲ្យបរិសុទ្ធ ដោយសារបញ្ញា ដែលជាសមាធិបទដ្ឋាន ៗ បើនរជនប្រុសស្រីណា ខំព្យាយាមរៀនសូត្របរិកម្ម ភាវនា វិជ្ជាផ្លូវលោកផ្លូវធម៌ ដោយមធ្យតភាព ធ្វើនរជននោះឲ្យភ្លឺភ្លុះប្រុះប្រាជ្ញ កំចាត់បង់នូវងងឹតគឺមោហន្ធការហើយឲ្យជ្រាបនូវអនិច្ចាទិលក្ខណៈ ឥតមានល្អៀងដោយគុណជាតិនៃបញ្ញា ៗ បញ្ញានេះ មានច្រើនបែបច្រើនប្រការ តែបើពោលដោយខ្លីមាន ២ គឺលោកិយ-បញ្ញា ១ លោកុត្តរបញ្ញា ១ ៗ បញ្ញាដែលសម្បយុត្តដោយមគ្គជាលោកិយ ហៅថា លោកិយបញ្ញា, ដែលសម្បយុត្តដោយមគ្គជាលោកុត្តរ ហៅថា លោកុត្តរបញ្ញា ៗ អធិប្បាយថា ប្រាជ្ញាដែលមិនទាន់ប្រព្រឹត្តទៅក្នុងសន្តាននៃព្រះអរិយបុគ្គល ៨ ពួកមានព្រះសោតាបន្នជាដើម មានព្រះអរហន្តជាទីបំផុត ប្រាជ្ញានោះហៅថា លោកិយបញ្ញា បានដល់បញ្ញាយើងគេទាំងឡាយ ដែលជាកល្យាណបុថុជ្ជនពួកកល្យាណជន បើទុកជាចេះថ្វីងឫទ្ធិមានហោះហើរដើរលើអាកាសហោហាំ មុជជ្រែកទឹក ដ៏ប្តូនិម្មិតជាសុក ទេវតា ព្រហ្ម ឬ សត្វអ្វី ៗ ដោយសារអភិញ្ញាណកៈដោយ បញ្ញារបស់កល្យាណជននោះ មិនទាន់ជាលោកុត្តរបញ្ញាទេ ព្រោះមិនសម្រេចមគ្គផលមានសោតៈជាដើម ដូចយ៉ាងបញ្ញាទេវទត្តភិក្ខុ ៗ បញ្ញាបិតនៅក្នុងសន្តាននៃសេក្ខាសេក្ខបុគ្គល មានសោតាបន្នជាដើម ស្តូប្បី

សោតាបន្នបុគ្គលនោះ មិនចេះប្រើរិទ្ធិ ដោយមិនទាន់សម្រេចឥទ្ធិវិធី កំបញ្ញារបស់សោតាបន្នបុគ្គលនោះ ចាត់ជា លោកុត្តរបញ្ញាដែរ ព្រោះបុគ្គលនោះ មានសេយ្យចិត្តក៏បាន៖ អរិយជន ៗ បណ្តាវិជ្ជា ៨ យ៉ាង មានតែអាសវក្ខយវិជ្ជាមួយទេ ដែលជាគួលោកុត្តរបញ្ញាពិត ៗ ដទៃក្រៅពីវិជ្ជានេះ ជាលោកុត្តរបញ្ញាក៏មាន ជាលោកិយបញ្ញាក៏មាន ៗ បញ្ញាទាំងពីរស្ថាននេះ រមែងកើតមានដល់ប្រជាជន ដោយការគិតខ្លះ ដោយស្តាប់ខ្លះ អប់រំខ្លះ បញ្ញាណាកើតឡើងដោយការគិត ដូចជាបណ្ឌិត អគ្គកោវិទខ្លះ គ្រាន់តែគិតត្រិះរិះរំពឹងសញ្ជឹង តាមក្រសែចិត្ត ក៏កើតសេចក្តីដឹងព្រមតាមការគិតទៅ បញ្ញាប្រភេទនោះហៅថា ចិន្តាមយបញ្ញាខ្លះ ៗ មិនចេះគិតដោយប្រាជ្ញាប្រត្យក្សរបស់ខ្លួនទេ លុះណាតែបានស្តាប់ទឹង ឆ្ងាប់ស្តាប់អំពីសំណាក់នៃបជន ទើបកើតសេចក្តីដឹងប្រាកដតាមគេឡើង សេចក្តីដឹងនេះចាំមានសភាពដូច្នេះ ហៅថា សុតាមយបញ្ញា ៗ បុគ្គលខ្លះទៀត បានគិតផង បានស្តាប់គេឯងផង ហើយចំរើនអប់រំបន្ទុំវិជ្ជានោះ ញយៗរហូតដល់កើតសេចក្តីដឹងច្បាស់ជាក់លាក់ បញ្ញាកើតឡើងអំពីការប្រតិបត្តិការ យ៉ាងនេះហៅថា ភាវនាមយបញ្ញា ៗ កំបញ្ញាទាំង៣ប្រភេទនេះកើតមានក្នុងសន្តាននៃជនណា ជននោះឈ្មោះថា មានរតនៈដ៏សក្តិសិទ្ធិក្នុងខ្លួន ដូចពុទ្ធភាសិតក្នុងសំយុត្តនិកាយ សគាថវគ្គថា បញ្ញា នរានំ រតនំ ប្រែថា បញ្ញាជារតនៈនៃជនទាំងឡាយៗ រតនៈទាំងឡាយក្នុងលោក

ដូចយ៉ាងមាសប្រាក់កែវមណីជាដើម ដែលកើតឡើងបាន ក៏អាស្រ័យ
បញ្ញានេះដែរ បើខ្វះបញ្ញាហើយរតនៈទាំងឡាយក៏មិនកើតមានបាន បើ
មានស្រាប់ដោយសារជារបស់នៃត្រកូលមក ក៏គង់តែវិនាសហិនហោច
ទៅវិញ ព្រោះជននោះគ្មានចេះវិធី ក្នុងការរៀបចំទុកដាក់និងចាយវាយ ៗ
បុគ្គលណាកើតមកក្នុងត្រកូលខ្សត់ខ្សោយទ្រព្យសម្បត្តិ ជាត្រកូលហីន
លក្ខណ៍ តែបុគ្គលនោះមានប្រាជ្ញា ក្នុងការរៀនសូត្រហូតដល់បាន
ចេះដឹងប្រាកដប្រជាឡើងជាវរៈជន អាចតាំងខ្លួនជាធនិនបាន ៗ រតនៈ
ទាំងឡាយ ក៏កើតចូលឥតសល់ពេលវេលា ថែមទាំងនាំត្រកូលនោះឲ្យ
ទៅជាឆ្នើមត្រកូល ប្តូរខ្ទមត្រកូលដោយសារបញ្ញា ៗ ព្រោះហេតុនោះ
ហើយបានជាព្រះសម្ពុទ្ធទ្រង់ពោលទុកថា បញ្ញា នរានំ រតនំ ៗ បញ្ញា
មានគុណការៈដ៏ជ្រាលជ្រៅណាស់ សំដែងមកនេះជាសេចក្តីងាយ ល្មមធម្មតា
ជនទទួលសវនាការគ្រាន់ជាទិដ្ឋានុគតិតទៅ បញ្ញានេះចាត់ជាវេសារ-
ជ្ជករណធម៌ទី ៥ ៗ ធម្មទេសនាអំពីវេសារជ្ជករណធម៌ ៥ យ៉ាង សូម
បញ្ចប់តែប៉ុណ្ណេះ សូមថ្វាយព្រះរាជកុសលចំពោះព្រះមហាក្សត្រទាំងពីរ
ព្រះអង្គ ចំពោះសម្តេចព្រះឧបយុវរាជ សូមជូនកុសលចំពោះលោកអ្នក
ពុទ្ធបរិស័ទទាំងអស់ក្នុងកម្ពុជរដ្ឋ សូមឲ្យប្រកបដោយពរ ៤ ប្រការគ្រប់ ៗ
គ្នា កុំបីឃ្លាតឡើយហោង ៗ

បប់

# កិលេសធម៌

ភិក្ខុ រ៉ើក-ភិម វត្តខណ្ឌាឈោម រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការចំពោះព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយគោរព ។

លំដាប់ពីនេះ សូមសំដែងអំពីកិលេសធម៌ ដោយសេចក្ដីសង្ខេប ដូចតទៅ ៖

កិលេសនេះ បានសេចក្ដីថា ធម៌ជាគ្រឿងសៅហ្មង ឬធម៌ជាគ្រឿងញុំាងសន្ដានចិត្តរបស់បុគ្គលឲ្យសៅហ្មងជានិច្ច ។ កិលេសទាំងអស់ជាមហាគតធម៌ ធម៌ត្រូវលះ ។

ចិត្តជាប្រក្រតីលោកហៅថា ភវង្គចិត្ត ចិត្តនេះមែនមានរស្មីថ្លាល្អ ប៉ុន្តែបើ កិលេសកើតគ្រាំនៅជាមួយហើយ ចិត្តនោះក៏ត្រឡប់ប្រែក្លាយទៅជាអាប់រស្មីវិញ ដូចមានពុទ្ធភាសិតក្នុងគម្ពីរធម្មបទបឋមភាគថា ៖

បភស្សរមិទំ ភិក្ខវេ ចិត្តំ
តញ្ច ខោ អាគន្ដុកេហិ
ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ ។

ម្នាលភិក្ខុទាំងឡាយ ចិត្តមានរស្មីត្រចះ ប៉ុន្តែ ចិត្តនេះមានឧបក្កិលេស

ដែលទើបនឹងមកថ្មី តែងចូលទៅ ធ្វើឲ្យសៅហ្មង បានជាគាប់ស្មើ ទៅវិញ ។

កិលេសនោះចែកចេញជា ៣ ផ្នែកគឺ

១- លោភោ សភាវៈធ្វើចិត្តឲ្យជាប់ជំពាក់នៅក្នុងអារម្មណ៍,

២- ទោសោ សភាវៈប្រទូស្តក្នុងអារម្មណ៍,

៣- មោហោ សភាវៈធ្វើចិត្តឲ្យវង្វេងក្នុងអារម្មណ៍ ។

កិលេស ៣ ប្រការនេះ ជាសត្រូវចំពោះកុសលធម៌ទាំងពួង ធំបំផុតក្នុងលោក ទឹងរកសត្រូវណាមកប្រៀបផ្ទឹមពុំបាន ព្រោះសត្រូវឯទៀតៗ ធ្វើបុគ្គលឲ្យដល់នូវសេចក្ដីអន្តរាយ បានតែត្រឹមខ្លួន និងទ្រព្យសម្បត្តិធម្មតាប៉ុណ្ណោះ ឯសត្រូវគឺកិលេស ៣ ប្រការនេះ អាចធ្វើនូវសេចក្ដីសាបសូន្យអន្តរាយដល់ខន្ធសន្តាន នៃសត្វលោកទាំងអស់ ព្រមទាំងធ្វើសេចក្ដីអន្តរាយដល់លោកិយធម៌ និងលោកុត្តរធម៌ផង ។

លោភោ ជាសភាវៈដែលធ្វើចិត្តឲ្យជាប់ជំពាក់ក្នុងអារម្មណ៍ ព្រោះតែសេចក្ដីលោភហួសប្រមាណនេះ នាំឲ្យសាបសូន្យចាកប្រយោជន៍សព្វយ៉ាង ដូចមានពុទ្ធភាសិតក្នុងគម្ពីរខុទ្ទកនិកាយ ខុទ្ទកនិបាតជាតកថា

អតិលោភេន អត្ថម្ហា យេវ ហាយតិ សត្វលោករមែងសាបសូន្យចាកប្រយោជន៍ទាំងពួង ព្រោះតែសេចក្ដីលោភខ្លាំងពេក ។ លោភៈនោះ ចាត់ជាសត្រូវទី ១ ទុកជាឫសគល់នៃបាបអកុសល ។

សេចក្តីលោភដែលកើតឡើងបាន ព្រោះតែសត្វលោកមានសេចក្តីសង្ឃឹមថា សម្បត្តិទ្រព្យគ្រឿងទាំងនោះ មុខជានឹងបានមកខ្លួនអញ មុខជាចំរើនឡើង ត្រង់សេចក្តីវិនាសបង់ខាតទៅវិញនោះ មិនសូវបានគិតឃើញទេ ម៉្លោះហើយក៏ចំប្រឹងប្រែងឧបាយកល ដែលប្រកបដោយផ្លូវទុច្ចរិតមិននិយមតាមផ្លូវព្រះពុទ្ធសាសនាទេ ច្រើនតែនិយមខាងអំពើទុច្ចរិតម៉្លោះហើយក៏សាបសូន្យបាត់ប្រយោជន៍សព្វយ៉ាង ដែលខ្លួនប៉ុនប៉ងប្រាថ្នានោះ ដូចមានពុទ្ធភាសិត ក្នុងគម្ពីរសំយុត្តនិកាយ សគាថវគ្គថា

លោភោ ធម្មានំ បរិបន្ថោ សេចក្តីលោភជាសេចក្តីអន្តរាយនៃលោកិយធម៌នឹងលោកុត្តរធម៌ទាំងឡាយ ។ ឯលោកិយធម៌ គឺសីល សមាធិ បញ្ញារបស់បុថុជ្ជន ឬ លោកិយសម្បត្តិជាគ្រឿងឧបភោគបរិភោគផ្សេង ៗ សម្រាប់លោក ។ លោកុត្តរធម៌ គឺ មគ្គ ផល និព្វាន មានតែសេចក្តីលោភនេះឯង ដែលអាចធ្វើឲ្យវិនាសអន្តរាយទៅបាន គឺថា បើលោកិយធម៌ ឬលោកិយសម្បត្តិកើតឡើងហើយ សេចក្តីលោភអាចបំផ្លាញធម៌នឹងសម្បត្តិនោះ ឲ្យវិនាសខ្ចាត់ខ្ចាយបាត់បង់ទៅវិញប្រាកដ ។ ចាំបាច់និយាយទៅថ្វីដល់ធម៌នឹងសម្បត្តិដែលមិនទាន់កើតឡើង សូម្បីលោកុត្តរធម៌ដែលបំរុងនឹងកើតឡើង ក៏សត្រូវពោលគឺសេចក្តីលោភនេះ ធ្វើឲ្យអន្តរាយទៅបាន ហេតុដូច្នេះហើយ បានជាមានពុទ្ធភាសិត ក្នុងគម្ពីរខុទ្ទកនិកាយ ជាតកថា

អតិលោភោ ចាបកោ សេចក្ដីលោភជាធម៌យ៉ាងលាមកក្រៃលែង ។

សេចក្ដីលោភនេះតែកើតមានឡើង ក្នុងសន្ដានចិត្តរបស់បុគ្គលណា ហើយ បុគ្គលនោះត្រូវដឹងខ្លួនឲ្យហើយទៅថា ខ្លួនអាត្មាអញរមែងមិនជាទីស្រឡាញ់នៃអ្នកដទៃឡើយ គឺជាសំអប់ ឬជាទីធុញទ្រាន់ដល់សន្ដាននៃបុគ្គលដទៃ ដោយហេតុនោះ សូម្បីតែបុគ្គលនោះ ឈមមុខទៅកាន់លំនៅរបស់អ្នកណាមួយ អ្នកនោះរមែងមានសេចក្ដីធុញទ្រាន់ តាំងពីឃើញមុខមកពីចម្ងាយ ដោយគេគិតថា មុខជានឹងមករកខ្ចីរបស់អ្វីមួយមិនខាន ។

មិនតែប៉ុណ្ណោះ សេចក្ដីលោភនេះជាធម៌លាមកអាក្រក់ក្រៃពេកជាសត្រូវធំបំផុត ជាមហាសាវជ្ជៈមានទោសច្រើន ទាំងលះបង់បានដោយក្រ បើកើតឡើងក្នុងសន្ដានចិត្តអ្នកណា មិនដែលធ្វើអ្នកនោះឲ្យបានសេចក្ដីសុខចំរើន មិនដែលធ្វើបុគ្គលនោះ ឲ្យងើបមុខទៅរកសុគតិភពបានទេ រមែងធ្វើអ្នកនោះឲ្យមានមុខសំយុងចុះ ទៅកាន់អបាយភូមិតែម្យ៉ាង ។ លោភៈនេះ ចាត់ជាសត្រូវទី ១ របស់សត្វលោក ។

ទោសៈ សេចក្ដីក្រេវក្រោធ ទទឹងទទែង មិនគិតខុសត្រូវអ្វីសោះ ហេតុមិនគួរខឹងក៏ខឹងទៅកើត ហេតុនេះហើយបានជា លោកចាត់ថា ទោសៈនេះជាសត្រូវទី ២ ។ ទោសៈ បើកើតឡើងក្នុងសន្ដានចិត្តរបស់បុគ្គលណាក្នុងពេលណា បុគ្គលនោះភ្លេចបុណ្យបាប គុណទោស សីល

ទានការនាគ្គនពេលនោះអស់ហើយ គឺជាអំពើបាបណាមកដែលជាហេតុ ឲ្យមានពៀរវេរទៅបរលោក ក៏ហ៊ានធ្វើឥតញញើតឥតកោតក្រែងសោះ ៗ ចំណែកអំពើបុណ្យ ដែលជាហេតុចំរើនផលានិសង្ស ហូរដូរទៅខាងមុខ ក៏មិនត្រូវការធ្វើ គឺថា ធ្វើដោយឥតគិតកោតក្រែងដោយហេតុទោសៈគ្របសង្កត់ ។

ទោសៈនេះ ជាគ្រឿងបណ្តាលឲ្យកើតកហុសផ្សេង ៗ ជាច្រើន លោកចាត់ជាមហាសាវជ្ជៈ មានទោសច្រើន ប៉ុន្តែ លះបង់បានងាយ សមនឹងពុទ្ធភាសិត ក្នុងគម្ពីរខុទ្ទកនិកាយ ត្រង់សុខវគ្គថា :

នត្ថិ ទោសសមោ កលិ ទោសខុសអ្វីមិនស្មើនឹងទោសៈឡើយ ។

ទោសៈនេះ បើមានតាំងនៅក្នុងសន្តានចិត្ត របស់បុគ្គលណាហើយ បុគ្គលនោះរមែងប្រព្រឹត្តខុសផ្សេង ៗ មានការប្រព្រឹត្តខុស ដោយកាយជាដើម ដូចជាចាប់កាន់វត្ថុអ្វីមួយដោយដៃ ហើយវត្ថុនោះ ក៏ធ្លាក់ពីដៃបែកបាក់អស់ទៅ ព្រោះបុគ្គលនោះតែងធ្វើអំពើ ដែលប្រកបដោយទោសៈ ។ ឯទោសៈនេះ អាចធ្វើឲ្យសាមញ្ញជន ខាតប្រយោជន៍សព្វបែបសព្វយ៉ាង ទោះប្រយោជន៍បច្ចុប្បន្ននេះក្តី ប្រយោជន៍ខាងមុខក្តី ក៏ទោសៈធ្វើឲ្យដល់នូវសេចក្តីអន្តរាយ វិនាសបាត់បង់ទៅបាន ។

មោហៈ ជាសឹកសត្រូវមួយយ៉ាងធំ លោកចាត់ថាជាសត្រូវទី៣ ។

មោហៈ បើកើតមានក្រាស់ក្រែល ក្នុងសន្តានចិត្តបុគ្គលណា ក៏រមែងតែ បុគ្គលនោះឲ្យងងឹតឈ្លប់ មិនឲ្យមានសេចក្តីភ្លឺស្វាងឡើយ ។ មោហៈនេះ ជាមហាសាវជ្ជៈ មានទោសច្រើនពេក លះបង់បានដោយកម្រផង ។

បើបុគ្គល មានមោហៈ សេចក្តីល្ងង់ងងឹតជានិច្ច គ្របសង្កត់ជាប់ ហើយ រមែងមិនបានសេចក្តីរីករាយសប្បាយ ក្នុងពួកជនឡើយ មិនបាន សេចក្តីត្រេកអរ ក្នុងការធ្វើកិច្ចតាំងពិត ។

មោហៈនេះ ទុកជាសំណាញ់មួយ សម្រាប់ចាក់ស្រេះសន្តានចិត្តនៃ សត្វលោកគ្រប់ពួក ជាបណ្តាញសំណាញ់បំផុត ពិបាកដោះស្រាយ ណាស់ សមនឹងពុទ្ធភាសិត ក្នុងគម្ពីរធម្មបទខុទ្ទកនិកាយ ត្រង់មល- វគ្គថា នត្ថិ មោហសមំ ជាលំ បណ្តាញស្មើដោយមោហៈ មិនមានឡើយ ។

គ្រឿងចាក់ស្រេះទាំងឡាយ មានសំណាញ់ជាដើម ជាគ្រឿង ក្រសោបរឹតកក់តឹងហើយ ប៉ុន្តែ សត្វមានស្មារតីប្រុងប្រយ័ត្ន នឹងគេច ចេញរួច សត្វណា ដែលមានកម្លាំងច្រើន គងជៀសវាងផុតរួច រឺឲ្យ រួចពីសំណាញ់នោះ គង់ៗ លុះតែសត្វណាដែលមានសេចក្តីធ្វេសប្រហែស និងមានកម្លាំងតិច ទើបជាប់នៅក្នុងសំណាញ់នោះបាន ។ តែបើទុកជា ដូច្នោះ ក៏ដល់នូវសេចក្តីវិនាសអន្តរាយ បានត្រឹមតែអត្តភាពមួយប៉ុណ្ណោះ

មិនដែលសត្វណាជាប់សំណាញ់តែម្តង ដល់នូវសេចក្តីអន្តរាយពីបើជាតិ ទៅខាងមុខនោះទេ ។

ចំណែកសំណាញ់គឺមោហៈនេះ អាចដាក់ស្រះរួចតែស្ទើរតែគ្មាន សត្វណាគេចរួច ឬធ្វើម្ដាយឲ្យរួចផុតស្រឡះបាន ព្រោះថា សំណាញ់ គឺមោហៈនេះ បើសត្វណាបានចូលជាប់ហើយ ក៏មិនរួចរតដាក់ស្រះ សត្វនោះ ឲ្យវិនាសក្នុងអត្តភាពនេះ ទាំងក្នុងបរលោកជាច្រើន គឺមិន បិទបាំងប្រាជ្ញាសត្វនោះ មិនឲ្យស្គាល់អំពើបាបទាំងពួងបានឡើយ ។

សមនឹងពុទ្ធភាសិតក្នុងគម្ពីរទីឃនិកាយមហាវគ្គ ត្រង់មហាបរិនិព្វាន សូត្រថា ចាចាធិ គាម្ហាធិ គាវេត្ថិ មោហា ជនទាំងឡាយរមែង ធ្វើបាបកម្មទាំងឡាយ ព្រោះសេចក្តីល្ងង់ ។

សេចក្តីមិនដឹងច្បាស់នូវហេតុនិងផល នៃអំពើទាំងពួង ជាហេតុឲ្យ ជនទាំងឡាយ ហ៊ានធ្វើបាបកម្មឥតញញើត ឬជាហេតុឲ្យជនទាំងឡាយ ចូលចិត្តថា បានសេចក្តីចំរើន សុខ ព្រោះអំពើបាប មានសម្លាប់សត្វនិង លួចទ្រព្យគេជាដើម ។ កាលបើជនទាំងនោះ ខំប្រឹងតែធ្វើអំពើបាប ដរាបតែដល់នូវសេចក្តីវិនាស ទើបដឹងខ្លួនថាធ្វើនេះខុស មានសត្វខ្លះមិន ទាំងដឹងខ្លួនថា ធ្វើនេះខុសផង ទាល់តែអំពើអាក្រក់នោះឲ្យផល ទើបដឹង ខ្លួន ។ នេះមកសេចក្តីល្ងង់ មិនដឹងខុស មិនដឹងត្រូវ ទាល់តែដល់ នូវសេចក្តីលំបាក ទើបដឹងខ្លួនថា ឱ ! អំពើបាបនេះមិនល្អទេតើ ។

កិលេសធម៌ទាំងបីប្រការនេះ ជាបហាតព្វធម៌ ជាធម៌ត្រូវលះ ព្រោះជាមេបាបធម៌ដ៏បំផុតក្នុងលោកទាំងមូល បើបាបធម៌កើតនៅក្នុងសន្តានចិត្តរបស់បុគ្គលណាហើយ អាចបណ្ដាលដឹកនាំបុគ្គលនោះ ឲ្យដើរឈ្លានពានរឹបជាន់ឥតគិតក្រែងរងចិត្តគេសោះ ។ កិលេសធម៌នេះ អ្នកប្រាជ្ញទាំងឡាយចាត់ទុកជាសត្រូវដ៏ក្រៃលែង ។ ដំណើរដូច្នេះហើយ គួរពួកពុទ្ធបរិស័ទទាំងឡាយ នាំគ្នាលះបង់កិលេសធម៌នេះ កុំឲ្យមាននៅក្នុងសន្តានចិត្ត ហើយខំប្រឹងស្វែងរកសេចក្ដីបរិសុទ្ធ មានការរក្សាសីលធ្វើទានជាដើម ដែលជាមូលហេតុ នៃសេចក្ដីសុខ ចំរើន កុំបីធ្វេសប្រហែសឡើយ ។

កិលេសធម៌ដែលបានសំដែងមកដោយសង្ខេបនេះ សន្មតថាចប់សមគួរតាមពេលវេលា ។

សព្វេ សត្តា អវេរា ច អព្យាបជ្ឈា ច និព្ភយា
អរិយា សុខិតា សព្វេ និយ្យាយន្តិ ច សព្វទា ។

សត្វទាំងឡាយទាំងពួង កុំឲ្យមានពៀរពេរានឹងគ្នា កុំឲ្យមានទុក្ខ កុំឲ្យមានភ័យ សូមឲ្យពួកសត្វនិករទាំងឡាយ បានប្រកបដោយសុខភាពដ៏ប្រសើរ ឲ្យបានរលត់ទុក្ខសព្វកាល ។

សូមពពួកទេវតា ដែលមានមេត្តាព្រហ្មវិហារធម៌ ក្នុងទេវស្ថានក្ដី ក្នុងក្រុងទាំងអស់ក្ដី ជួយបីបាច់ថែរក្សាពលសាសនា ពលរដ្ឋ ឲ្យបានប្រកបដោយសុខភាព វឌ្ឍនភាព កុំបីឃ្លាតក្លាយទៅជាបការៈដទៃឡើយ ។

x x x

# សុរពជាតក

(តមក)

លោក ចិង-វេង ចម្លងពីសាស្ត្រាស្លឹករឹត

បន្ទាប់មក សេនាបតីនោះគិតថា អ្នកទាំង ៤ នាក់ មកអាស្រ័យនៅនាសាលា ប្រហែលជាដឹងឧបាយថ្លឹងដំរីបាន គិតហើយដើរទៅកាន់សាលា សន្ទនាហេតុការណ៍ផ្សេងៗ រួចសួរថា តើអ្នកទាំងអស់ដឹងឧបាយខ្លះដែរឬទេ? ឥឡូវ សម្តេចព្រះមហាក្សត្រាធិរាជនៃយើង មានប្រាថ្នាចង់ដឹងទម្ងន់មង្គលហត្ថី ជាដំរីព្រះទីនាំង អស់អ្នកទាំងនេះដឹងឬទេ ? ។ ឯបណ្ឌិតអាមាត្យទទួលថាដឹង ។ សេនាបតីសួរបន្ថែមថា តើធ្វើដូចម្តេច ? ។ បណ្ឌិតអាមាត្យបង្គាប់ថា ចូរអ្នកពល់គ្នាទៅយកដើមឬស្សី ឲ្យបានច្រើនមកចងផ្គាប់គ្នាធ្វើជាក្បូន ហើយបរដំរីឡើងលើក្បូននោះ, មើទឹកលិចក្បូនត្រឹមណា ឲ្យគ្រិតត្រឹមនោះ រួចនាំដំរីចេញពីក្បូន ហើយឲ្យសែងដុំថ្ម-ឥដ្ឋទៅដាក់ ឲ្យដល់គំរិតដែលដាក់ដំរី, បើដល់គំរិតត្រឹមត្រូវហើយ ចូរយកដុំ ថ្ម ឥដ្ឋនោះមកថ្លឹង បានទម្ងន់ប៉ុន្មាន ដំរីក៏ទម្ងន់ប៉ុណ្ណោះដែរ ។ សេនាបតីបានស្តាប់ហើយត្រេកអរឥតឧបមា ទើបធ្វើតាមបង្គាប់បណ្ឌិតអាមាត្យ ហើយឡើងទៅក្រាបទូលព្រះរាជា ។ ព្រះអង្គត្រាស់សួរថា អ្នកថ្លឹងមង្គលហត្ថីរួចហើយឬ ? ។ – ព្រះករុណាថ្លៃពិសេស ថ្លឹង

រួចហើយ ៗ - អ្នកថ្មីដូចម្តេច ? ។ សេនាបតីក្រាបទូលតាមបណ្ឌិតអាមាត្យបង្គាប់ ។ ព្រះមហាក្សត្រមានព្រះរាជហឫទ័យត្រេកអរពន់ប្រមាណ ទ្រង់ព្រះរាជទានដល់សេនាបតីនូវសេះ គោ ក្របី រាជរថមាស ប្រាក់ កែវកង ពៃទូរ្យ សុរិកាន្តជាច្រើន ៗ ថ្ងៃនីសេនាបតីនោះ មានកូនក្រមុំមួយអាយុ ១៦ ឆ្នាំ ប្រកបដោយរូបឆោមលោមពណ៌ស្រស់បំព្រង មានសម្បុរដូចមាសឆ្អិន , ជាស្ត្រីកបកល្យាណី ; សេនាបតីលុះវិលមកដល់ផ្ទះវិញគិតថា អយំ មយ្ហំ ពហុបការកោ បណ្ឌិតអាមាត្យនេះ មានឧបការដល់អញច្រើនណាស់ , មួយសោតគាត់មានប្រាជ្ញាវៃក្លៀនខ្លាំងបំផុត ឯបុត្រីនៃអញក៏មានអាការៈប្រហែលនឹងអាកប្បកិរិយារបស់គាត់ដែរ គួរអញលើកឱ្យទៅគាត់ចុះ ក្រែងបំណោរទៅឯមុខ មានភយន្តរាយណាមួយដល់អញ ៗ គ្រាន់នឹងបានគាត់ជាទីពឹង, លុះគិតសព្វគ្រប់ហើយ ក៏ផ្ទុកទ្រព្យទាំងនោះលើខ្នងដំរីទាំង ៥ បរទៅកាន់សាលា លើកបុត្រីនៃអាត្មាព្រមទាំងទ្រព្យ ជូនចំពោះបណ្ឌិតអាមាត្យ ៗ បណ្ឌិតអាមាត្យរំពឹងថា ព្រះមហាក្សត្រនៃអញ ព្រះអង្គឥទាថា ពុំមានព្រះអគ្គមហេសីទីប្រតិបត្តិទៀបព្រះបាទា គួរអាត្មាអញលើកកុលធីតានេះថ្វាយព្រះអង្គ, លុះគិតដូច្នោះហើយ ក៏ថ្វាយកុលធីតានោះ ចំពោះព្រះរាជាខ្លួន ៗ ចំណោរតមក ព្រះមហាក្សត្រាធិរាជនារីនោះ ទ្រង់សោយព្រះទំរិះគិត ៗ អស់ពួកមន្ត្រីទាំងសេនាបតីបបួលគ្នាថ្វាយព្រះភ្លេងរណ្តាប

លើកសពស្រេបហើយ ជំនុំគ្នាថា ភោ ភោ ហៃអ្នកទាំងឡាយដ៏ចំរើន ! នគរណាមួយ ពុំមានព្រះមហាក្សត្រាធិរាជសោយរាជសម្បត្តិ , អស់អាណាប្រជារាស្ត្រ មិនបានសេចក្ដីសុខសប្បាយឡើយ, ព្រះមហាក្សត្រនៃយើង ព្រះអង្គគ្មានព្រះរាជបុត្រាសោះ មានតែព្រះរាជបុត្រីមួយអង្គ ដែលមានវ័យក្មេង ខ្ចីសេចក្ដី ធម្មតាស្ត្រីតែងទន់ ពុំក្លាហាន ពុំគួរនឹងលើកអភិសេក ឲ្យសោយរាជ្យបាន តើយើងរាល់គ្នាគួររកក្សត្រអង្គណា ឲ្យសោយរាជ្យ? ។ អ្នកខ្លះឆ្លើយថា គួរសេនាបតី, អ្នកខ្លះថា គួរបុរោហិត, អ្នកខ្លះថា គួរឃុនឃាំង, អ្នកខ្លះថា គួរឃុនពល ។ ទើបបុរោហិតប្រកាសសេចក្ដីថា ហៃអ្នកទាំងឡាយអើយ ! យើងនឹងលើកអ្នកអស់នេះ ឲ្យសោយរាជ្យមិនបានទេ គួរយើងយករាជរថមកទឹមអស្វផ្សងរកអ្នកមានបុណ្យ កាលបើរាជរថអណ្ដែតត្រសែតទៅរកអ្នកណា ត្រូវអភិសេកអ្នកនោះ ឲ្យសោយរាជ្យ ។ អស់មន្ត្រីនឹងសេនាបតីគិតព្រមគ្នាហើយ ក៏រៀបចំរាជរថ ហើយលែងទៅ ។ រាជរថនោះដល់សាលាប្រទក្សិណ ៣ ជុំហើយឈប់ស្ងៀម ។ អាមាត្យទាំង ៤ នាក់ អញ្ជើញព្រះមហាក្សត្រាធិរាជគង់លើរាជរថ បរនាំព្រះអង្គចូលទៅក្នុងព្រះបរមរាជវាំង ។ ពួកមន្ត្រីសេនាបតីនឹងប្រជារាស្ត្រទាំងឡាយ អភិសេកព្រះរាជធីតា ជាព្រះអគ្គជាយាខាងស្ដាំ ឯបុត្រីសេនាបតី ជាព្រះអគ្គមហេសីឆ្វេង ។ ព្រះមហាក្សត្រាធិរាជ ទ្រង់តាំងបណ្ឌិតអាមាត្យជាឧបរាជ , យកភារពី

សេនាបតីឲ្យទៅវិនិច្ឆ័យអាមាត្យ, យកនាយពីកណ្ណតារកៈ (អ្នករក្សាឃ្លាំង) ឲ្យទៅជាជំទង , យកនាយពីយុទ្ធពលឲ្យទៅពលអាមាត្យ ។ ឥតស្នា បណ្ឌិតសេវនាយ អត្ថញ្ញូ បរញ្ញូ ព្រោះហេតុនោះបុគ្គលដែលបានសេគ្រសមាគមជាមួយអ្នកប្រាជ្ញ រមែងបានប្រយោជន៍ ចំពោះខ្លួនផង ចំពោះអ្នកដទៃផង ដូចទាននៃដែលបានថ្លៃមកនេះឯងហោង ។

គតោ អនុបុត្តិកាថា ឥឡូវនេះ យើងនឹងសំដែងនិទានតទៅទៀត ។ បុព្វេ បពិត្រអើយ ក្នុងកាលនោះ មាននគរមួយឈ្មោះកោសេយ្យនគរ មានពាណិជម្នាក់ឈ្មោះ វិធុរបណ្ឌិត ប្រកបដោយប្រាជ្ញាវាងវៃ មានកូនប្រុសមួយឈ្មោះជោតិកមាណព ។ ឯវិធុរបណ្ឌិតនោះជានាយសំពៅធំជាងពួកនាយសំពៅទាំង ៧០០ នាក់ ។ ថ្ងៃមួយ វិធុរបណ្ឌិតផ្ទុកទំនិញលើសំពៅ ចេញទៅជួញជាមួយនាយសំពៅ ទាំង៧០០ នាក់ ។ សំពៅបើកទៅសព្វប្រទេស បានដល់ទៅនគរមួយឈ្មោះពហុលនគរ ។ ចំណែកខាងវិធុរបណ្ឌិត ក៏មានជម្ងឺពោះមកបៀតបៀន ។ អស់ពួកអ្នកនគរឃើញសំពៅច្រើនក៏គិតគ្នាថា សំពៅចូលមកចតដល់ទៅ ៧០០ ពួកវានឹងមកបៀតបៀនយើងទេដឹង ? ប្តូរមួយ មកដណ្តើមស្រុកអ្នករបស់យើង ! ពួកយើងនឹងអន្តរាយ ទាំងលែងទៀយ ហើយនាំគ្នាទៅក្រាបទូលព្រះបាទពហុលរាជថា ទេវ៖ បពិត្រព្រះសម្មតិទេព ! ឥឡូវ មានសំពៅចូលមកចតក្នុងស្រុកយើងច្រើនណាស់ យល់ជាសត្រូវនឹងព្រះអង្គ សូមទ្រង់

រឹបយកអស់ទ្រព្យរបស់ស្រេចហើយ លែងតែសំពៅឲ្យទៅវិញ ។ ព្រះបាទពាហុលរាជ លុះទ្រង់ព្រះសណ្តាប់ហើយ ក៏ទ្រង់ព្រះរាជបញ្ជាឲ្យរឹបយកទ្រព្យអ្នកសំពៅទាំង ៧០០ នោះ ។ វិធុរបណ្ឌិត លុះជាថ្មីហើយ គិតថា គួរអញធ្វើឧបាយកលយកទ្រព្យឲ្យបានមកវិញ គិតស្រេចក៏ប្រដាប់ស្ត្រីមួយរូប គិតជាតម្លៃមួយសែនដំឡឹង ផ្តាំអស់ពាក្យពេចន៍ល្បិចកិច្ចកលសព្វគ្រប់ហើយ ក៏យកទៅលាក់បំពួន នៅក្នុងបិការខ្ទឹមរបស់ព្រាហ្មណ៍ម្នាក់ ហើយវិលមកវិញ ទើបចូលទៅក្រាបទូលព្រះមហាក្សត្រាធិរាជថា ខៈ បពិត្រព្រះសម្មតិទេព ! ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នានេះ ជាពួកឈ្មួញនាំទំនិញចូលមកព្រះនគរព្រះអង្គ ប្រាថ្នាឲ្យព្រះនគរព្រះអង្គសម្បូណ៌ដោយគ្រឿងប្រើប្រាស់ផ្សេងៗ , ឥឡូវនេះ ភរិយាទូលព្រះបង្គំជាខ្ញុំ ចុះទៅងូតទឹកស្រាប់តែបាត់ទៅ ទូលបង្គំជាខ្ញុំត្រាច់រកសព្វច្រកល្ហកពុំឃើញឡើយ ហើយឥឡូវ ទូលបង្គំជាខ្ញុំយល់ថា ប្រាកដជាមានបុរសណាមួយ នាំពង្រត់ភរិយាទូលបង្គំជាខ្ញុំទៅ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសរកចោរនោះ នាកាលឥឡូវនេះ ។ កាលនោះ សម្តេចព្រះមហាក្សត្រាធិរាជមានព្រះរាជឱង្ការថា ហៃនាវិកអើយ ! យើងឥតជឿថា អ្នកជាពាណិជសោះ យើងគិតថា អ្នកជាសត្រូវនឹងយើង ដ្បិតអ្នកនគរមកប្រាប់យើងថា ពួកអ្នកប្រុងមកវាយយកនគរយើង ទើបឲ្យរឹបយកទំនិញដាក់ក្នុងឃ្លាំង បើពួកអ្នកពិតជាពាណិជមែន យើងនឹងប្រគល់ទ្រព្យទាំងអស់

មកពួកអ្នកវិញ លុះទ្រង់ត្រាស់ដូច្នោះហើយ ក៏ប្រើពួកអាមាត្យឲ្យទៅរកករិយាពាណិជ ។ ពួកអាមាត្យទំព្រាប់ផ្គាត់ទៅរកករិយាពាណិជគ្រប់ទីតាំងពួន ក៏ពុំឃើញ លុះដើរទៅដល់ចំការខ្ទមរបស់ព្រាហ្មណ៍ម្នាក់ បានឃើញនាងម្នាក់នៅក្នុងចំការខ្ទម ហើយនាំមកថ្វាយព្រះមហាក្សត្រ ។ ព្រះរាជាទ្រង់ត្រាស់ហៅវិធូរបណ្ឌិតមក ត្រាស់សួរថា គឺ អធាយម្នាលវិធូរបណ្ឌិត ! ប្រពន្ធអ្នកតើយកអ្វីទៅខ្លះ ? ។- វិធូរបណ្ឌិតក្រាបទូលតបថា ប្រពន្ធទូលព្រះបង្គំជាខ្ញុំ ប្រដាប់ដោយរតនៈមានតម្លៃ ១ សែនដំឡឹង ។ គ្រានោះ ព្រះមហាក្សត្រទ្រង់ត្រាស់សួរថា នរណានាំនាងទៅ ? នាងស្គាល់ឬទេ ? ។ នាងក្រាបទូលថា ខ្ញុំម្ចាស់ពុំស្គាល់ ពុំចាំមុខទេ ។ ព្រះអង្គទ្រង់ត្រាស់ដណ្ដឹងទៅអាមាត្យថា អ្នកពលគា រកឃើញនាងនៅឯណា ? ។ ពួកអាមាត្យក្រាបទូលថា បាវិតទេវត្ថ ប្រសព្វម ទូលព្រះបង្គំជាខ្ញុំទាំងឡាយ រកនាងឃើញក្នុងចំការខ្ទមរបស់ព្រាហ្មណ៍នោះ ។ ព្រះមហាក្សត្រទ្រង់ត្រាស់ហៅម្ចាស់មកត្រាស់ដណ្ដឹងសួរថា ម្នាលបុរស! អ្នកឯងនាំប្រពន្ធនាយសំពៅទៅឬ ? ។ បុរសនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព! ឆត្ថិទូលព្រះបង្គំជាខ្ញុំឥតនាំនាងទៅឡើយ ។ – ចុះចំការអ្នកណា ? ។ –ទេវ: បពិត្រព្រះសម្មតិទេព! ចំការទូលព្រះបង្គំជាខ្ញុំ ។ ព្រះមហាក្សត្រទ្រង់ត្រាស់ថា បើអ្នកជាម្ចាស់ចំការ ទោសនេះត្រូវធ្លាក់លើអ្នកឯង ព្រោះ

កាលអាមាត្យនាំនាងនេះមក រកម្ចាស់ចំការពុំឃើញ លុះយើងស៊ើបសួរទៅដឹងថា អ្នកឯងនាំយកប្រពន្ធនាយសំពៅទៅលាក់ទុក ក្នុងចំការខ្លួន ចំណែកនាងនោះ គឺយើងបានដណ្ដឹងសួរហើយ នាងឆ្លើយថាពុំស្គាល់មុខអ្នកនាំមកទេ, ឥឡូវយើងសួរអ្នកឯងជាម្ចាស់ចំការ អ្នកឯងក្លែងកុហកថា មិនដឹង, អ្នកឯងធ្វើអ្វីបានជាមិនរក្សាចំការ គួរយើងលក់ពិន័យម្ចាស់ចំការ យកប្រាក់ ៥០០ ដំឡឹង ហេតុដ្បិតម្ចាស់ចំការ មិនរក្សាចំការ បើមិនចោរ ក៏ទុកដូចជាចោរ ត្រូវយកប្រាក់ ៥០០ តំឡឹងទៅឲ្យនាយសំពៅប្ដីនាងនេះ អបិច មួយសោត អស់ពួកអ្នកនគរនាំគ្នាចោទពាណិជជាចោរជាសត្រូវ បានរឹបយកទំនិញក្នុងសំពៅនោះ តើមានប៉ុន្មាន? ត្រូវនាំមកប្រគល់ឲ្យម្ចាស់សំពៅវិញ ។ ឥស្សរ ពហុលរញ្ញោ គិរិឥយោ ជិតា បានឮថា ធីតារបស់ព្រះបាទពហុលរាជ មានព្រះអង្គប្រកបដោយរូបឆោមលោមព័ណ៌ល្អឥតខ្ចោះត្រង់ណា, ជាស្ត្រីប្រកបដោយលក្ខណា ហាក់ដូចទេវធីតានាស្ថានសួគ៌ ។ តាសំ គិរិត្តិសរឡោ ព្រះរាជធីតានោះល្បីឮព្រះកេរ្តិ៍ទូទាំងសាកលជម្ពូទ្វីប ។

អថខោ ឮដំណាលនោះ មានស្តេចមួយព្រះអង្គ សោយរាជ-សម្បត្តិនៅអញ្ញាតរនគរ (នគរដទៃ) តាសំ គិរិត្តិសរឡោ លុះឮល្បីព្រះនាមព្រះរាជធីតានោះ ប្រាថ្នាចង់បានក៏ប្រុងប្រៀបអស់រេហ៍ពលសកលយោធាជាច្រើន លើកចូលទៅដល់នគរព្រះបាទពហុលរាជ ហើយបញ្ជប់

កងពលក្នុងព្រះនគរនោះទ្រង់ឲ្យចាប់ក្អែបពីរគឺ ញី ១ ឈ្មោល ១ មកដាក់ក្នុងប្រអប់មាសហើយបោះត្រា, ព្រះអង្គឲ្យយកក្អែបឯទៀត មានទាំងកូន ២ ផង មកដាក់ក្នុងប្រអប់មួយផ្សេងទៀតបោះត្រាដែរ ទ្រង់ផ្ញើព្រះរាជ-សារឲ្យរាជទូតនាំទៅជាសេចក្ដីថា ភោ ពាហុលរាជ ហៃព្រះបាទពាហុលរាជដ៏ចំរើន! បេ តុំ បណ្ឌិតោ បើអ្នកជាអ្នកប្រាជ្ញមានប្រាជ្ញាឈ្លាសវៃ ចូរដោះស្រាយសតបទិកបញ្ហានៃយើង ឥឡូវយើងលើកទ័ពមកជាច្រើន បើអ្នកដោះស្រាយបាន យើងនឹងបូជាអ្នក ហើយនាំកងទ័ពត្រឡប់ទៅវិញ បើដោះស្រាយមិនបាន យើងនឹងលើកទ័ពចូលទៅវាយព្រះនគរ ឲ្យល្អិតជាផង់ធុលីក្នុងកាលឥឡូវនេះ ប្រស្នានោះចូរអ្នកដោះស្រាយថា ក្អែបនេះញី ក្អែបនេះឈ្មោល ក្អែបនេះបង ក្អែបនេះប្អូន តែមួយណា ?" ។ ពួករាជទូតក៏នាំព្រះរាជសារ ព្រមទាំងប្រអប់នោះទូលទៅថ្វាយព្រះបាទពាហុលរាជ ។ ព្រះមហាក្សត្រត្រាស់សួរថា តាតោ អាគតោ អ្នកអញ្ជើញមកពីស្រុកទេសណា ? ។ - បពិត្រក្សត្រថ្លៃប្រសើរអើយ! ពួកទូលព្រះបង្គំជាខ្ញុំមកពីអញ្ញតរនគរ ។ - អ្នកមានការអ្វីទើបចូលមកកាន់សំណាក់យើង? ។ - ទូលព្រះបង្គំនាំព្រះរាជសារមកថ្វាយល្អិតធុលីព្រះបាទ ។ ព្រះបាទពាហុលរាជទ្រង់ទតព្រះរាជសារពិចារណាដល់សតបទិកបញ្ហា ក៏ពុំដឹងថាដូចម្ដេច. ទើបទ្រង់ជំនុំជាមួយពួកសេនា-មាត្យ ។ តេបិ អជានន្តា អាមាត្យទាំងអស់ពុំមុខមន្ត្រីរកអស់

រយៈវេលា ២-៣ ថ្ងៃក៏ពុំដឹងជាអ្វី ម្នោះហើយ ព្រះបាទពហុលរាជទ្រង់បារ៉ា
គង់ប្រាប់មនុស្សម្នាមហាជនឲ្យមកជួយដោះស្រាយប្រស្នានោះអស់ពេល ១
ថ្ងៃ ក៏គ្មានអ្នកណាមួយអាចដោះស្រាយបាន, ទើបព្រះអង្គទ្រង់នឹកព្រះរាជ-
ហឫទ័យគិតដល់នាយសំពៅ ដែលមានជំរះប្រាជ្ញាជ្រៅជ្រះ ទ្រង់ឲ្យហៅ
វិធូរបណ្ឌិតមកដណ្ដឹងសួរថា បណ្ឌិត ហៃលោកប្រាជ្ញ ! អ្នកអាចដោះ
ស្រាយសតបទឹកបញ្ហាបានឬទេ ? ។ វិធូរបណ្ឌិតក្រាបទូលថាប្រស្នាក្អែប
នោះដូចម្ដេច ? ។ សម្ដេចព្រះមហាក្សត្រាធិរាជទ្រង់ប្រាប់ថា ព្រះបាទ
អញ្ញតរាជ ទ្រង់ឲ្យរាជទូតនាំព្រះរាជសារមក ហើយឲ្យដោះស្រាយប្រស្នា
អំពីសត្វក្អែបឲ្យដឹងថា ក្អែបនេះឈ្មោល នេះញី នេះបង នេះប្អូន អស់
យើងទាំងព្រះនគរនេះបានជំនុំគ្នាជាច្រើនថ្ងៃ ពុំអាចដោះស្រាយបាន ។ វិធូរ
អ្នកប្រាជ្ញក្រាបទូលថាដឹង ហើយក្រាបទូលទៀតថា ទូលព្រះបង្គំដឹងពិត
តែក្រែងមហាជនពុំជឿ ដ្បិតពុំមានអ្វីជាបន្ទាល់, ដូច្នេះ ទូលព្រះបង្គំសូម
ក្រយាបូជាគ្រឿងទៀនធូបអុជអធិដ្ឋានបូជា ដល់ពពួកទេវតា ជាបន្ទាល់ ព្រោះ
ក្រែងពួកមនុស្សម្នាមហាជនគេពុំជឿ តែពួកទេវតានោះដឹងពាក្យរបស់
ទូលព្រះបង្គំជាខ្ញុំ ។ ព្រះមហាក្សត្រទ្រង់បានជ្រាបពាក្យវិធូរបណ្ឌិតហើយ ក៏ឲ្យ
រៀបគ្រឿងពិធីការស្រេចហើយ ឲ្យហៅវិធូរបណ្ឌិតមក ។ ទើបវិធូរអ្នកប្រាជ្ញ
ប្រកាសដល់ទេវតាថា ភោន្តោ ទេវសង្ឃា យោ បពិត្រពពួកទេវតា
ទាំងឡាយដ៏ចំរើន ! ទេវតាដែលឋិតនៅនាស្ថានសួគ៌ឆត្រ ឬ ប្រាង្គប្រាសាទ

អ្នកចូរមកជាសាក្សីពេជ្រញាណរបស់ខ្ញុំ បើខ្ញុំស្រដីសច្ចំទៀតទាត់ សូមទេវតាឲ្យពរសព្ទសាធុការដល់ខ្ញុំ បើស្រដីពុំទៀងសូមប្រាប់ខ្ញុំឲ្យដឹងផង, ហើយបើកប្រអប់មាសចាប់យកក្អែបនោះចេញមក ពិចារណាស្រេចហើយក្រាបទូលថា ទេវ បពិត្រព្រះអង្គដ៏ចំរើន! អយំ សតរធនិកោ រីក្អែបនេះ មានក្បាលធំ គល់កន្ទុយធំ កណ្តាលខ្លួនមូលតូច បុរិសោ ចេវ ប្រាកដជាឈ្មោលហោង, អយំ សតរបនី ក្អែបនេះញី ព្រោះមានក្បាលតូច គល់កន្ទុយតូច រាងតំបាក់កណ្តាលខ្លួន ឥត្ថី ច ពិតជាញីហោង, អបិច ម្យ៉ាងទៀត ក្អែបនេះបងី ព្រោះវាវារទៅមុន, អយំ បច្ឆានុគច្ឆតិ ក្អែបនេះប្អូន ព្រោះវាវារទៅតាមក្រោយ ។ អស់ពួកទេវតាដែលរក្សាស្វេតច្ឆត្រ ក៏ប្រាយកយគន្ធមាលាជាគ្រឿងបូជា ហើយឲ្យសព្ទសាធុការ ឯមនុស្សម្នាមហាជនក៏ឲ្យពរសព្ទសាធុការទ្រហឹងអឺងកងពេញទាំងព្រះរាជវាំង ។ ឯរាជទូតស្តាប់ហើយ ថ្វាយបង្គំលាព្រះបាទពហុលរាជវិលទៅក្រាបទូលព្រះបាទអញ្ញតរាជតាមដំណើរ ។ កាលនោះព្រះបាទអញ្ញតរាជទ្រង់ជ្រាបហើយ មានព្រះរាជហឫទ័យត្រេកអរ ឥតឧបមា ទ្រង់ព្រះរាជទានមាស ១ សែនដំឡឹង ជាគ្រឿងបូជាដល់វិធូរអ្នកប្រាជ្ញហើយលើកទ័ពត្រឡប់ទៅកាន់ព្រះនគរវិញ ។ ទើបព្រះបាទពហុលរាជត្រាស់សួរវិធូរបណ្ឌិតថា នាវិកៈ ម្នាលនាយសំពៅ! ហេតុដូចម្តេចទើបអ្នកដឹងកិរិយារបស់ក្អែបនោះ ? ។ វិធូរបណ្ឌិតក្រាបទូលថា ទូល

បង្គំដឹងបុរាណធម៌ ។ ព្រះអង្គត្រាស់សួរទៀតថា បុរាណធម៌នោះដូចម្ដេច ? ។ វិធូរបណ្ឌិតក្រាបបង្គំទូលថា :

ភូតបុព្វំ និធានំ មានទំនងតាំងពីដើមមក, អតីតេ ឃគោ រាជា កោរព្យោ នាម គឺកាលដែលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមកោរព្យៈ សោយរាជសម្បត្តិនៅកោរព្យនគរ មានព្រះរាជបុត្រា ២ ព្រះអង្គ ទ្រង់ឃើញទោសកាមគុណ មានព្រះរាជហឫទ័យប្រាថ្នាចង់បួស ទ្រង់ឲ្យហៅព្រះរាជបុត្រា ២ ព្រះអង្គមក ប្រគល់រាជសម្បត្តិដល់ព្រះរាជបុត្រច្បង ហើយទូន្មានព្រះរាជបុត្រទាំងពីរព្រះអង្គថា តាតា ហៃកូនសួនទាំងពីរអើយ! បើបាដើរតាមផ្លូវ បាឲ្យបងដើរមុន ប្អូនដើរក្រោយ, បើអង្គុយត្រូវបងអង្គុយមុន ប្អូនអង្គុយក្រោយ, បើសោយរាជ្យត្រូវបងសោយរាជ្យមុន ប្អូនសោយរាជ្យក្រោយ នេះជាប្រវេណីធម៌ ចូរបាចាំទុកកុំភ្លេច, លុះទ្រង់ប្រៀនប្រដៅរួចហើយ ព្រះបាទកោរព្យរាជចេញចាកព្រះនគរឆ្ពោះទៅព្រៃព្រះហិមពាន្ត ទ្រង់ព្រះផ្នួសជាតាបស ដោយប្រការដូច្នេះឯង, បពិត្រក្សត្រថ្លៃប្រសើរអើយ ! ទូលបង្គំដឹងប្រវេណីធម៌មកយ៉ាងនេះឯង ។

អតីតេ កិរ ឃគោ មាណវោ ធលិន្ទោ បាទព្ទថា គឺកាលដែលកន្លងទៅហើយ មានបុរសម្នាក់កំសត់ទុគ៌តក្រលែង មាតាបិតាញាតិកាស្លាប់ចោលអស់ ក៏ចេញទៅបួសជាតាបសអាស្រ័យនៅ-

ក្បែរមាត់ស្រះមួយក្នុងព្រៃព្រះហិមពាន្ត បំពេញឈានសមាបត្តិ ។ កាល
នោះ មានមេក្អែបផើម ១ វារចុះទៅខាងមាត់ស្រះ ក៏ធ្លាក់ទៅក្នុងស្រះ
នោះ ។ ឃាតោ តាក្កដតោ មានក្តាម ១ ឃើញក្អែបក៏វារ
ដើម្បីនឹងទៅចាប់ស៊ីជាអាហារ ។ កាលនោះ តាបសចុះទៅខ្ទះមាត់ ។
ក្អែបញីឃើញតាបសទើបស្រែកថា បពិត្រតាបស ! សូមអម្ចាស់យក
ជីវិតខ្ញុំផង ។ តាបសក្រឡេកទៅឃើញត្រីមួយស្លាប់ ក៏ចាប់ត្រីស្លាប់
នោះទៅឲ្យក្តាម ហើយនាំមេក្អែបយកទៅទុកក្នុងអាស្រម ។ ឯក្អែប
ញីផើមបាស់ផ្ទៃទៀបនឹងសម្រាល ទើបនិយាយនឹងតាបសថា បពិត្រ
តាបស ! សូមលោកកេបំពង់ឲ្យមួយនឹងសម្រាលកូន ។ តាបសក៏
កេបំពង់ឫស្សីឲ្យក្អែបញី ។ ឯមេក្អែបនោះសម្រាលបានកូនញី ១ ឈ្មោល
១ តែងនាំកូនទាំងពីរមកស៊ីសំណល់បាយឯអាស្រមតាបសរាល់ៗថ្ងៃ ។
តាបសឃើញក្អែបមកដូច្នោះ ដណ្តឹងសួរថា ឯណាបង ឯណាប្អូន ។
ក្អែបញីប្រាប់ថា: នេះបង នេះប្អូន, ឯបងនោះ ក្បាលធំ គល់កន្ទុយ
ធំ កណ្តាលខ្លួនតូចវារមកមុន បុរិសោ ឈ្មោល ; នេះក្អែបញីត្រូវជា
ប្អូន ក្បាលតូច គល់កន្ទុយតូច កណ្តាលខ្លួនធំ វារមកតាមក្រោយ ។
វិធូរបណ្ឌិត លុះនាំនិទានមកដូច្នេះហើយ ក៏ក្រាបបង្គំទូលព្រះចៅពហុល-
រាជថា បពិត្រក្សត្រថ្លៃប្រសើរអើយ ! ទូលព្រះបង្គំជាខ្ញុំបានដឹងពុកណ-
ធម៌មកយ៉ាងនេះ ទើបហានទាយថា នេះក្អែបឈ្មោល នេះក្អែបញី ។

ពួកប្រជារាស្ត្រហើយនាំគ្នាឲ្យពរស័ព្ទសាធុការ ឮសូរទ្រហឹងអឹងកង ៗ ឯវិធុរបណ្ឌិតថ្វាយបង្គំលាទៅកាន់សំណាក់វិញ ៗ រីពួកពាណិជរៀបចំអីវ៉ាន់ ជិះសំពៅបើកតាមមហាសមុទ្រ រហូតដល់នគរគោត្ថា ហោង ៗ វិធុរបណ្ឌិត នៅជាសុខសប្បាយ លុះយូរទៅជរាមកបៀតបៀនទៀបទីមរណា ក៏ហៅជោតិកមាណពជាកូនមកផ្តាំថា តាត បិយបុត្តកា: ហៃកូនស្ងួនសំឡាញ់! ឪពុកក្សយហើយ អ្នកនៅឯក្រោយឪពុកនឹងផ្តាំទុក បើអ្នកទៅដួញប្រទេសណាឪពុកមិនឃាត់ទេ ឃាត់តែស្រុកពហុលនគរព្រោះនៅស្រុកនោះគេជះឧបាយកលបញ្ឆោតយកទំនិញយើង, មួយសោតព្រះបាទពហុលរាជ ព្រះអង្គមានព្រះរាជបុត្រី ៣ ព្រះអង្គ ប្រកបដោយរូបឆោមលោមពណ៌ ហាក់ដូចស្រីទេពអប្សរបរិកញ្ញា អស់ស្តេចទាំងឡាយក្នុងជម្ពូទ្វីបមានសេចក្តីប្រាថ្នា ចង់បានព្រះរាជបុត្រីទាំងនោះគ្រប់ៗ រូប ៗ តស្មា ព្រោះហេតុដូច្នោះ អ្នកនៅក្មេងសេចក្តី ចូរបាចាំទុកបណ្តាំឪពុក, ឥតិបុត្តស្ស អនុសាសិត្វា វិធុរបណ្ឌិតទូន្មានកូនរួចហើយ ក៏អស់សង្ខារទៅកាន់លោកខាងមុខទៅ ៗ ជោតិកមាណពបូជាព្រះភ្លើងព្រះបិតារួចហើយ ប្រមូលទ្រព្យរបស់បិតាមកទុក ៗ

អបរភាគេ លុះចំណេរមកខាងក្រោយ ជោតិកមាណពចំរើនធំឡើង មានប្រាជ្ញាឈ្លាសវៃលើសអស់ពាណិជទាំងឡាយទាំង ៧០០ នាក់ ក៏គិតដល់បណ្តាំរបស់ឪពុក ដែលផ្តាំមិនឲ្យទៅដួញនៅពហុលនគរ

ទុំ បឋ គាថា ស្រុកនោះសោតដូចម្ដេច ? គួរអញនឹងទៅឲ្យបាន
ដឹង, គិតស្រេចហើយ ជោតិកមាណពក៏ឲ្យរៀបចំសំពៅចាំង ៧០០ ផ្ទុក
អស់ទំនិញ ហើយបើកកាត់សមុទ្រចូលទៅចតទៅកំពង់នៃពាហុលនគរ
នោះ ៗ តទា ក្នុងកាលនោះ មានកុក ១ ជើងក្រហម ស្វែង
រកចំណី ហើរមកជិតសំពៅនោះ ៗ ជោតិកមាណពក៏បាញ់កុកនោះ
ស្លាប់ ៗ កូនឈ្នួញយកកុកនោះមកទុកក្នុងសំពៅ ៗ អថ ខោ
បុរិសោ បដិភាណវាចាយ កុសលោ តំ ទិស្វា
អាណាវិត្វា ចោទេតិ លំដាប់នោះ មានបុរសកំណាចម្នាក់
ជាអ្នកឈ្លាសខាងសំដី កាលបើឃើញជោតិកមាណពបាញ់កុកស្លាប់
ស្រុះទៅហៅថា ហៃនាយសំពៅ ! ហេតុអ្វីអ្នកបាញ់កុកជាបិតាអញ
ឲ្យស្លាប់ ៗ ជោតិកមាណពក៏ស្ងៀមពុំស្រដី ៗ តទា បឋ. សមយេ
ថ្ងៃមួយទៀត មានបុរសម្នាក់ចូរមកនិយាយ នឹងជោតិកមាណពថា
ម្នាលនាយសំពៅ ! អ្នកជាកូនចៅអ្នកណា ? ៗ យើងជាកូន
របស់វិជ្ជូបណ្ឌិត ៗ បុរសនោះ លុះដឹងថា ជោតិកមាណពជាកូន
នៃវិជ្ជូបណ្ឌិតហើយ ទើបហៅថា អម្ភោ ណាវិក ម្នាលនាយសំពៅ
ដំបូរនេ ! បហាតភាលុកាំ ១ ធិត្វា បិតាអ្នកឯងមកដកអណ្ដូង
ខ្សាច់ នាំយកកែវមណីយើងទៅ, ឯកែវមណីនោះមានតម្លៃស្មើនឹង
ព្រះនគរមួយ ឥឡូវ អ្នកឯងជាកូនត្រូវសងកែវមណីនោះមកះយើង ៗ

ជោតិកមាណពនៅស្ងៀមពុំស្រដីឡើយ ។ អថេកោ បុរិសោ គ្រានោះ មានបុរសម្នាក់ទៀត មកស្រដីដោយជោតិកមាណពថា អម្ភោ នាវិកា ហៃនាយសំពៅដ៏ចំរើន! យើងមានកូនជ្រូកសមួយ បិតានៃអ្នកឯងមកអង្វរខ្ញុំយើងថា សហាយកា ហៃសំឡាញ់អើយ! យើងសូមខ្ចីកូនជ្រូកសមួយ យកទៅបង្កាត់កូននៅកោះមានឈ្មោះដូច្នេះៗ បើបង្កាត់រួចហើយ យើងយកមកជូនវិញ កូនជ្រូកនេះមានតម្លៃស្មើព្រះនគរមួយ ប៉ុន្តែ ឥឡូវ បិតានៃអ្នកអស់បុណ្យទៅហើយពុំបានមក ត្វំ បង បុត្តា ម្តេចក៏អ្នកឯងជាកូន មិនយកកូនជ្រូកនោះមកផង, ដូច្នេះ អ្នកឯងត្រូវយកកូនជ្រូកមកឥឡូវនេះ ។ ជោតិកមាណពនៅស្ងៀមពុំឆ្លើយថា ដូចម្តេចឡើយ ។ លំដាប់នោះ មានបុរសម្នាក់មានចក្ខុតែម្ខាង តស្ស សន្តិកំ អាគន្ត្វា មកកាន់សំណាក់ជោតិកមាណពស្រដីដោយថា អម្ភោ នាវិកា ហៃនាយសំពៅដ៏ចំរើន! បិតានៃអ្នកមកខ្ចីភ្នែកយើងម្ខាងយកទៅ ឥឡូវពុំបានវិលមក, ត្រូវអ្នកជាកូនយកភ្នែកនោះមកសងយើង ដ្បិតយើងទទួលទុក្ខវេទនាមកយូរហើយ ។ គ្រានោះ ជោតិកមាណពនៅស្ងៀម ។ តេ ចត្តារោ ជនា ជនទាំង ៤ នាក់នោះ ចូលទៅក្រាបទូលព្រះបរមក្សត្រាធិរាជ តាមដំណើររឿងខ្លួន ។ ព្រះមហាក្សត្រទ្រង់ព្រះតំរិះថា វិជ្ជបណ្ឌិតជាបិតានៃជោតិកមាណព មានឧបការលើអញ រកអ្វីថ្លឹងពុំបាន គាត់បានដោះសាអាថ៌

ប្រស្នាលើកស័ក្តិលើកយសអញ, កាលនោះ បើកុំតែបានគាត់ ព្រះនគរអញវិនាសអន្តរាយទៀតប្រាកដហោង, ឯចៅជោតិកមាណពទំនងជាមានប្រាជ្ញាឈ្លាសវៃ ដូចវិធូរបណ្ឌិតដែរ បើដូច្នោះ គួរអញល្បងនូវប្រាជ្ញាគាត់មើលចុះ, គិតជា — ព្រះបរមក្សត្រាធិរាជទ្រង់ឲ្យហៅជោតិកមាណពឲ្យចូលមក ។ ជោតិកមាណព លុះចូលមកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ព្រះរាជាដណ្តឹងសួរថា មាណវក កោ នាមោសិ ហៃចៅមាណព! ចៅឯងឈ្មោះអ្វី ? ។ — ជោតិកមាណពក្រាបបង្គំទូលព្រះបង្គំជាខ្ញុំ ឈ្មោះជោតិកមាណព ។ — កស្ស បុត្តោ ចៅឯងជាកូនអ្នកណា ? ។ — ទូលបង្គំជាខ្ញុំជាកូននៃវិធូរបណ្ឌិត ។ ព្រះរាជាទ្រង់មានព្រះបន្ទូលថា បិតានៃអ្នកទៅឯណា? ម្តេចក៏មិនមកកាន់សំណាក់យើង ។ ជោតិកមាណពក្រាបទូលថា បិតារបស់ទូលព្រះបង្គំជាខ្ញុំវិលានបញ្ចខន្ធទៅហើយ, ប៉ុន្តែ មុននឹងវិលានខន្ធនោះ បិតាទូលព្រះបង្គំជាខ្ញុំបានផ្តាំថា ម្នាលបា! បើបាធំឡើង ចូរបាទៅជួញនៅពហុលនគរកុំខានឡើយ ។ ព្រះបរមក្សត្រាធិរាជទ្រង់មានព្រះរាជឱង្ការថា ហៃចៅជោតិកមាណព! បិតានៃបាឯងមានគុណចំពោះយើងច្រើនណាស់ នាកាលព្រះបាទអញ្ញាតរាជមកចោទប្រស្នា អស់អាមាត្យធំតូចក្នុងព្រះនគរដោះប្រស្នាពុំបានឡើយ បានបិតាបាឯងជាអ្នកដោះប្រស្នាឲ្យ កាលនោះ បើប្រសិនពុំបានបិតាឯង នោះព្រះនគរយើងវិនាសដោយ

ដែលត្រូវប្រាកដហោង, ឥឡូវយើងឃើញបាឯងជាកូនវិទូរបណ្ឌិត ហាក់ដូចជាកូនចេញពីសាច់យើង ! អើ ! បុរស ៤ នាក់មកប្រាប់យើងដោយដំណើរទីទៃពីគ្នា, បុរសទី ១ មកប្រាប់យើងថា ចៅឯងបានបាញ់កុកជាបិតារបស់គេឲ្យស្លាប់ តើចៅសម្លាប់មែនឬ ? ។-សច្ចំ ទេវ បពិត្រព្រះសម្មតិទេព ! ទូលព្រះបង្គំជាខ្ញុំបានបាញ់សម្លាប់មែន ។- កុកនោះ ជាបិតារបស់នៃបុរសនេះ ហេតុអ្វីបានជាបាញ់បិតាគេឲ្យស្លាប់។- បពិត្រមហាពល! ទូលព្រះបង្គំជាខ្ញុំសម្លាប់ក៏ពិតមែន ប៉ុន្តែ ទូលព្រះបង្គំជាខ្ញុំមិនបានបរិភោគឡើយ ។- កុកនោះ មានទោសដូចម្តេច បានជាចៅសម្លាប់? ។ - អយ្យំ តស្ស ទិតា កុកជាបិតានៃបុរសនោះ មកចាប់ស៊ីត្រីជាបិតានៃទូលព្រះបង្គំជាខ្ញុំជាអាហារ មួយទៀត ទូលព្រះបង្គំជាខ្ញុំសម្លាប់បិតានៃបុរសនេះជាសត្តិព្រានឥតបានបរិភោគទេ, ឯកុកសម្លាប់បិតានៃទូលព្រះបង្គំជាខ្ញុំជាត្រី ហើយស៊ីត្រូវឲ្យបុរសនេះសងថ្លៃទូលព្រះបង្គំជាខ្ញុំហោង ។ស្តេចត្រាស់សួរថា កុកសម្លាប់បិតាបានោះ មានសាក្សីឬទេ ? ។ - បពិត្រព្រះសម្មតិទេព! សេចក្តីនេះកើតពីបុរសអ្នកចោទទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គត្រាស់សួរបុរសនោះមុនចុះ ។ គ្រានោះ ព្រះមហាក្សត្រត្រាស់សួរទៅបុរសចោទថា កុកជាបិតាប្រស្តែងនោះ មានបន្ទាល់សាក្សីឬទេ? ។ ឯបុរសនោះក៏ទុនក្បាលបពុំស្រដីអ្វីឡើយ ។ បន្ទាប់មក ស្តេចត្រាស់សួរទៅដោតិកមាណពថា កុកសម្លាប់បិតានៃបាមានសាក្សីឬទេ ? ។ ដោតិកមាណពក្រាបបង្គំទូលថា

ទូលព្រះបង្គំជាខ្ញុំ មានព្រះអង្គជាសាក្សីពេជ្រញាណស្រាប់ មម បិតា
គាវ សិនេហា ត្បិតបិតានៃទូលព្រះបង្គំជាខ្ញុំ កាលនឹងធ្វើមរណកាល
សឹងមានចិត្តប្រតិព័ទ្ធ ចំពោះព្រះអង្គ លុះផុតអាយុទៅ បានចាប់កំណើត
ជាត្រីកាស្រ័យនៅនាកំពង់នេះ ; ឯកុកនេះ ហើរមកចាប់ត្រីជាបិតាទូល
ព្រះបង្គំស៊ីជាអាហារនៅនាកំពង់សំពៅនេះ ដូច្នេះ ទើបទូលព្រះបង្គំជាខ្ញុំ
ត្រូវតែបាញ់កុកនោះសម្លាប់ចោល ។ ព្រះបាទពហុលុកដទ្រង់ត្រាស់ថា
ភោ ចោទកៈ ហៃបុរសអ្នកចោទក៏ដំបើន ! ហេតុអ្វីក៏ប្រស្តែងមក
ចោទនាយសំពៅយ៉ាងនេះ លោកចិត្ត ប្រស្តែងជាអ្នកមានចិត្តលោភ
ឃើញទ្រព្យគេលោភចង់បាន, ទើបព្រះអង្គទ្រង់ត្រាស់ទៅកាន់ពួកអាមាត្យ
ទាំងពួងថា បូរអ្នកពលគ្នាកត់ត្រាសេចក្តីនេះជាច្បាប់តទៅ បើអ្នកណាប្តឹង
សេចក្តីដូច្នេះ គឺបើមាណពសម្លាប់បិតាបុរសនេះពិតមែន ត្រូវឲ្យមាណព
សងបិតាបុរសនេះវិញ បើរកសងពុំបាន ឲ្យលក់មាណពយកថ្លៃតាមចំនួន
ខ្លួនអ្នកត្រូវមាណពសម្លាប់, មួយសោត បើកុកជាបិតាបុរសនេះប្រាកដ
មែនថែមទាំងមានសាក្សីពេជ្រញាណផង ឲ្យពិន័យមាណពជា ៤ ភាគ ពីរ
ភាគជាទ្រព្យសំនួនខ្លួន ពីរភាគដាក់ឃ្លាំងហ្លួង, ការពិន័យនេះ ព្រោះសត្វ
កុកជាសត្វព្រៃពុំមែនជាសត្វចិញ្ចឹមដូចសត្វដទៃ ៗ ; បើជាសត្វចិញ្ចឹមដូច
ជាគោក្របីដំរីសេះឲ្យពិន័យជា ៨ ភាគ ៤ ភាគជាទ្រព្យជំនួសសត្វទាំងនោះ
៤ភាគជាទ្រព្យបញ្ចូលឃ្លាំងហ្លួង; មួយទៀត បុរសអ្នកចោទក៏មាណពថា

បានបាញ់កុកជាឪពុកខ្លួនស្លាប់ ប៉ុន្តែគ្មានសាក្សីពិតប្រាកដ ឲ្យពិន័យបុរសអ្នកចោទក៏ជា ៤ ភាគ ពីភាគ, បានទៅមាណព ពីភាគជាទ្រព្យហ្លួង: បុគ្គលណាមួយ សម្លាប់ខ្ញុំកំដររបស់គេក្តី សម្លាប់មនុស្សប្រើប្រាស់របស់គេក្តី ឲ្យសងជាទ្រព្យជំនួស ២ ភាគ, បើសម្លាប់មាតាបិតាគេ ឬសមណព្រាហ្មណ៍អ្នកមានសីល ត្រូវសម្លាប់អ្នកនោះវិញ បើអាល័យជីវិតឲ្យលោះខ្លួនជាទ្រព្យ១ពាន់ដំឡឹង ។ ព្រះមហាក្សត្រាធិកជទ្រង់ត្រាស់ដណ្តឹងទៀតថា ហោ មាណវកៈ ហៃចៅមាណពដ៏ចំរើន! បុរសនោះមកចោទថា វិធុរបណ្ឌិតជាបិតាឯងមកយកកែវមណី ដែលគេកប់ទុកក្នុងអណ្តូងខ្សាច់ ឥឡូវ ពុំបានយកមកឲ្យគេវិញ តើមែន ឬ ដូចម្តេច? ។ ចៅតិកមាណពក្រាបបង្គំទូលថា បើបិតាទូលព្រះបង្គំជាខ្ញុំយកកែវមណីក្នុងអណ្តូងខ្សាច់ប្រាកដដូច្នោះមែន សូមព្រះអង្គត្រាស់ប្រើបុរសម្ចាស់កែវមណីបាចទឹកឲ្យរីង ជញ្ជូនខ្សាច់ចេញឲ្យជ្រៅចុះទៅដល់កន្លែង ដែលដាក់កែវមណី បើដីកបានទូលព្រះបង្គំជាខ្ញុំនឹងសងកែវមណីជា ២ វិញ ។ ព្រះមហាក្សត្រទ្រង់ត្រាស់ប្រើបុរសនោះ ដូចពាក្យរបស់ចៅតិកមាណព ។ បុរសនេះ ខំបាចទឹកជញ្ជូនដីខ្សាច់ប៉ុន្មាន ៗ ក្តី ក៏ពុំអាចនឹងរីងស្ងួតឡើយ បានសេចក្តីលំបាកវេទនាយ៉ាងខ្លាំង ទើបវិលទៅក្រាបទូលព្រះរាជាវិញថា បពិត្រក្សត្រថ្លៃប្រសើរអើយ ! ទូលព្រះបង្គំជាខ្ញុំពុំអាចបាចទឹកជញ្ជូនដីខ្សាច់ធ្វើអណ្តូងនោះឲ្យរីងបានឡើយ មុសាវាទំ ភណាមិ ទូលព្រះ

បង្គំជាខ្ញុំស្រដីមុសាវាទពុំពិតឡើយ ៗ ព្រះមហាក្សត្រាធិរាជទ្រង់ដេរពោល ថា ភោ អន្តពាល ៖ ហៃប្រស្តែងអន្ធពាល! ប្រស្តែងជាមនុស្សល្ងង់ អប្បឥតប្រាជ្ញា សម្បូណ៌ដោយលោភចេតនា ឃើញទ្រព្យគេពុំគិតខុស ស្រដីដាក់ទោសអ្នកដទៃពុំគិតទោសកាត្នាឯង ទើបទ្រង់ត្រាស់ទៅសេនា-បតីថា យេ ច ជនា បើជនទាំងឡាយណា ស្រដីដាក់ទោសអ្នកដទៃថា គេបានបុលខ្ញុំទ្រព្យខ្លួនបើមិនពិត ឲ្យពិន័យជាទ្រព្យទ្វេ ១ ជាពីរ, តស្មា ព្រោះហេតុដូច្នោះ បុរសនេះមកស្រដីថា កែវមណីរបស់ខ្លួនថ្លៃស្មើនឹងព្រះនគរមួយ ចូរអ្នកពល់គាល់បុរសនេះទ្វេឡើងជានគរ២វិញ ម្យ៉ាងទៀត បុរសនេះជាអ្នកកំសត់ទុគ៌ត ខ្លួនមានតែកែវមណីឯណាថ្លៃស្មើនគរមួយ មានតែឲ្យបុរសអន្ធពាលនេះ ទៅក្រាបសំពះនៅនាបាតជើងជោតិក-មាណពអង្វរសូមទោសហើយពិន័យបុរសនេះជាប្រាក់តម្លៃ ១ ពាន់ ជាមាស ១ ពាន់, ជាកែវ ១ ពាន់ជាទង់ហ្វា ១ ពាន់ បើបុរសនេះពុំបានត្រូវឲ្យបុរសនេះព្រមទាំងមាតាបិតាញាតិកាបុត្រភរិយា ធ្វើជាខ្ញុំបំរើជោតិកមាណព ៗ ព្រះមហាក្សត្រទ្រង់ត្រាស់ទៅជោតិកមាណពទៀតថា បុរសនេះមកពោលថា បិតាចាឯងកាលសៅទៅឡើយ មកខ្ចីកែវបុរសនេះម្នាង យកទៅពុំបានវិលមកវិញឡើយ ៗ

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

# អត្ថន័យនៃការសិក្សា

លោក ស៊ុន-ហ៊ាន រៀបរៀង

ការសិក្សាជាគ្រឿងអលង្ការមួយបែប សម្រាប់តាក់តែងមនុស្ស ឲ្យបានជាមនុស្សពេញលក្ខណៈ មានសមត្ថភាពបរិបូណ៌គួរដល់ការងារ និងសម្រាប់ជួយមនុស្ស ឲ្យមានគុណធម៌ដ៏ល្អ ឲ្យចេះគ្រប់គ្រងជីវិត ទាំងជាមធ្យោបាយសម្រាប់សាងខ្លួន ឲ្យបានជាពលរដ្ឋដ៏ល្អ ៗ

ហេតុនេះ ទើបបណ្ឌិតទាំងឡាយ បានពន្យល់អត្ថន័យរបស់ការសិក្សាទុកច្រើនយ៉ាង ដូចតទៅនេះ៖

ក) ដើម្បីអប់រំចិត្តរបស់គេឲ្យចេះដឹង ជ្រើសរើសយកសេចក្ដីល្អទាំងពួង ;

ខ) ដើម្បីជាមធ្យោបាយសម្រាប់សាងខ្លួន ទប់ទល់ជីវិតគ្រប់យ៉ាង ឲ្យសមដល់អត្តភាព,

គ) ដើម្បីចែកសេចក្ដីចេះដឹងដល់មនុស្ស ឲ្យយកសេចក្ដីចេះដឹងនោះ ទៅប្រកបកិច្ចការផ្សេង ៗ ឲ្យត្រូវតាមគោលវិទ្យាសាស្ត្រ ;

ឃ) ដើម្បីឲ្យមនុស្សមានសេចក្ដីល្អវិសេស ប្រាសចាកសេចក្ដីអាក្រក់ ដោយប្រកបកិច្ចការទាំងពួង ត្រឹមត្រូវតាមលក្ខណការគ្រប់យ៉ាង ៗ

អ្នកប្រាជ្ញទាំងឡាយបានពន្យល់អត្ថន័យរបស់ការសិក្សាទុកច្រើនពេកហួសវិស័យ ទើបដកស្រង់យកមកពោលឲ្យសព្វគ្រប់ ជូនអស់លោកអ្នកនាងស្តាប់ក្នុងឱកាសនេះ ។ សរុបសេចក្តីខ្លឹមគឺ ការសិក្សាជាកិច្ចមួយប្រចាំជីវិតរបស់មនុស្សគ្រប់រូប មិនថាប្រុសឬស្រីទេ ទើបខានធ្វើពុំបាន ដើម្បីធ្វើសេចក្តីអន្ធកាលដែលមានទៅប្រចាំកាយស្រាប់ឲ្យចំរើនឡើង ដើម្បីញ៉ាំងប្រយោជន៍ខ្លួន និងប្រយោជន៍ជាតិឲ្យបានសម្រេចដោយល្អ បានសេចក្តីសុខ ព្រមទាំងរក្សាសេចក្តីសុខរបស់សង្គមឲ្យប្រព្រឹត្តទៅបានស្រួល ។

ឯការសិក្សាត្រូវប្រកបដោយអង្គផ្សេងៗច្រើនប្រការ តែក្នុងទីនេះសូមរៀបរាប់ដោយសង្ខេប គឺត្រូវប្រកបដោយអង្គ ៤ គឺ :

១- វិជ្ជាសិក្សា : បានខាងការសិក្សាផ្លូវវិជ្ជា គឺចំណេះគ្រប់យ៉ាងដើម្បីឲ្យកើតសេចក្តីចេះដឹងឈ្លាសវៃក្នុងការប្រកបការងារ ឲ្យបានសម្រេចផលល្អ ។ ឧទាហរណ៍ ដូចការរៀនវិជ្ជាផ្សេង ៗ តាមគោលសូត្រ ឬមេសូត្រ, អក្សរសាស្ត្រ, សព្ទសាស្ត្រ, ភាសាសាស្ត្រ, ប្រវត្តិសាស្ត្រ, គូមិសាស្ត្រ រហូតដល់វិទ្យាសាស្ត្រជាទីបំផុត ។

២-កម្មន្តសិក្សា: បានខាងការចុះដៃពិសោធធ្វើការងារគ្រប់បែប តាមចំណេះវិជ្ជា ដែលបានសិក្សាមកហើយនោះឲ្យបានស្ទាត់ជំនាញផ្ទាល់ខ្លួន ។ ឧទាហរណ៍ ដូចបានរៀនវិជ្ជាកសិកម្ម ហត្ថកម្ម ឧស្សាហកម្ម ជាដើម បានចេះដឹងហើយ បានចុះដៃធ្វើការនោះ ៗ ដោយខ្លួនឯង ឲ្យបានចំណេះ

តាមចំណេះដែលបានរៀនមកនោះឯង ។

៣–ពលសិក្សា: បានខាងការសិក្សាផ្លូវកាយបរិហារ ឬអត្តពលកម្ម ឲ្យមានរាងកាយមាំទាំ ការពារមិនឲ្យមានរោគភ័យឈឺចាប់ ឲ្យបានសុខកាយសប្បាយចិត្ត ចំរើនកម្លាំងពលំ និងដុំសាច់ ។ ឧទាហរណ៍ ដូចរៀនការហាត់ប្រាណ, ការរត់-លោត-ដាល់-គុន ការហែលទឹក ការលេងយោលទៅយោលមក, ការទាញចុះទាញឡើង រហូតដល់កីឡាផ្សេង ៗ របស់សាលារៀន ដែលជាការហ្វឹកហាត់រាងកាយឲ្យមាំមួន ។

៤- ចរិយាសិក្សា: បានខាងការសិក្សាអប់រំផ្លូវកាយ វាចា ចិត្ត ឲ្យបានទៅជាអ្នកដឹងច្បាប់ខុសត្រូវ តាំងនៅក្នុងសីលធម៌ល្អ ដើម្បីជាឧបករណ៍គ្រឿងដឹកនាំឲ្យកើតសេចក្ដីសុខ សេចក្ដីចំរើនដល់ខ្លួន ដល់ក្រុមគ្រួសារ ឬដល់សង្គម និងដល់ប្រទេសជាតិ ។ ឧទាហរណ៍ ដូចជានិស្សិតដែលរៀនការអប់រំចរិយារបស់ខ្លួនក្នុងសាលារៀនជាដើម ។

និយាយដោយខ្លីគឺ សិក្សាឲ្យបានជាមនុស្សមានសេចក្ដីចេះដឹងចេះធ្វើការងារតាមចំណេះ សេចក្ដីប្រព្រឹត្តត្រឹមត្រូវល្អ និងជាមនុស្សមានរាងកាយមាំទាំរឹងប៉ឹង ។

អង្គ ៤ របស់ការសិក្សានេះ ត្រូវអាស្រ័យគ្នានិងគ្នាជានិច្ច ខ្វះពុំបាន បើខ្វះអង្គណាមួយ មិនរាប់ថាជាការសិក្សាពេញអង្គបានឡើយ, ព្រោះថា បើខ្វះអង្គឯណានីមួយ រមែងជាឧបសគ្គដល់ការចិញ្ចឹមជីវិត សូមលើក

ឧទាហរណ៍មកប្រៀបឲ្យងាយយល់ ដូចជាអ្នកមានវិជ្ជាបេះដូងល្អ មានសេចក្តីប្រព្រឹត្តិល្អ ថែមទាំងបានចុះដៃពិសោធធ្វើការងារដោយល្អផងទៀត តែជាមនុស្សមានរោគប្រចាំកាយឈឺជានិច្ច ឬទុព្វលភាពក៏មិនអាចមានកម្លាំងហ្មមនឹងប្រកបអាជីវកម្ម បំពេញមុខក្រសួងបាន ឬមានសេចក្តីប្រព្រឹត្តិល្អ មានកម្លាំងពលំគ្រាន់បើ ទាំងមានព្យាយាមធ្វើការងារទៀត តែខ្វះវិជ្ជាក៏រមែងប្រកបការ បំពេញមុខក្រសួងឲ្យកើតផលល្អពុំបាន ឬមួយមានសេចក្តីបេះដូងល្អ មានកម្លាំងពលំមាំមួន ទាំងបានព្យាយាមធ្វើការហើយ តែសេចក្តីប្រព្រឹត្តិមិនល្អ មិនមានអ្នកណាសេពគប់ជឿស្តាប់តាម ក៏រមែងប្រកបអាជីវកម្មមិនស្រួល បំពេញមុខក្រសួងមិនបានល្អ មិនបានចំរើនឡើយ ។

ព្រោះហេតុដូចបរិយាយមកនេះ លោកទាំងមូលទើបកំណត់ឲ្យយុវជន-យុវតីគ្រប់រូប ទទួលការសិក្សាទាំង ៤ ចំណែក ដូចពោលមកហើយនោះ ដោយសេចក្តីប្រឹងប្រែង ដើម្បីឲ្យមានវិជ្ជាល្អ មានចរិយាល្អ មានការងារល្អ មានកម្លាំងកាយល្អ ព្រមទាំងឲ្យមានទឹកចិត្តជាអ្នកកីឡាតាមសមគួរដល់អាជីពរបស់ខ្លួន ។

ប្រទេសណាបរិបូណ៌ដោយការសិក្សាពេញអង្គទាំង ៤ ទូទៅគ្រប់ទីដំបន់ និគមជនបទ ប្រទេសនោះជា « អារ្យប្រទេស » បានចំរើនរុង-

រឿងដោយអារ្យធម៌ វប្បធម៌ និងសម្បត្តិគ្រប់យ៉ាងពិត ៗ ។ ប្រទេសណា ប្រាសចាកការសិក្សាទាំង ៤ ផ្នែកនេះ ប្រទេសនោះជា " អនារ្យប្រទេស " ព្រោះខ្វះខាតខ្សោយអារ្យធម៌ វប្បធម៌ និងសម្បត្តិគ្រប់យ៉ាង, ប្រជាជាតិក្នុងប្រទេសទាំងមូលជាអនារ្យជន ។

ប្រទេសនីមួយ ៗ ទោះតូចក្តី ធំក្តី លុះតែបរិបូណ៌ដោយពលរដ្ឋមានវិជ្ជាល្អ ការងារល្អ សុខភាពល្អ បរិយាល្អផង បរិបូណ៌ដោយគ្រឿងស្ពានផ្លូវថ្នល់ទឹកភ្លើងគ្រឿងប្រាលរន្ទាលឆ្និនឆ្ពោះទៅគ្រប់ទីកន្លែងផង ទើបឈ្មោះថាជាអារ្យប្រទេស ពេញលក្ខណៈបាន ។

ព្រោះហេតុនេះ បានជាសម្តេចព្រះបិតាឯករាជ្យជាតិ ប្រធានសង្គមរាស្ត្រនិយម អគ្គប្រមុខនៃព្រះរាជរដ្ឋាភិបាលទ្រង់ប្រកបដោយព្រះមហាករុណាទិគុណ ទ្រង់ព្យាយាមផ្ទាល់ព្រះអង្គផង ទ្រង់ណែនាំប្រជាពលរដ្ឋគ្រប់ប្រភេទ គ្រប់ឋានៈផង ស្ថាបនានូវស្ថាបនកម្មទាំងឡាយច្រើនជាអនេកប្រការ មានការសិក្សាវិជ្ជាផ្សេង ៗ ទាំងខាងអាណាចក្រ ទាំងខាងពុទ្ធចក្រ គ្រឿងស្ពានសិក្សា មន្ទីរពេទ្យការសាធារណៈផ្លូវថ្នល់ ម៉ាស៊ីនទឹក ម៉ាស៊ីនភ្លើង ព្រមទាំងស្ថាបនាខាងផ្នែកសេដ្ឋកិច្ច កសិកម្ម មានទំនប់ទឹកសម្រាប់ពលរដ្ឋ ធ្វើស្រែចម្ការច្បារដំណាំជាដើម កសាងប្រទេសកម្ពុជាជាមាតុប្រទេស ទីស្នេហារបស់ព្រះអង្គឲ្យបានជាអារ្យប្រទេសពេញ

លក្ខណៈឡើង ដើម្បីឲ្យកូនចៅបានសេចក្ដីសុខ សេចក្ដីចំរើនតទៅអស់កាលជាអង្វែង ។

ដោយព្រះមហាករុណាធិគុណនេះហើយ បានជាខេមរជនជាពលរដ្ឋគ្រប់ប្រភេទ គ្រប់ឋានៈ ទូទៅទាំងព្រះរាជាណាចក្រកម្ពុជា ស្រុះស្រួលគ្នាហែតាមក្រោយព្រះរាជបល្ល័ង្ក នឹងតាមក្រោយព្រះអង្គដោយរីករាយសោមនស្សស្មោះស្ម័គ្រពិត ៗ ឥតមានរញ្ជួយឡើយ ។

បរិយាយអំពីអត្ថន័យនៃការសក្ការៈចប់តែប៉ុណ្ណោះ ។

សិល្បសាស្ត្រមានពីណាដល់អ្នកខ្ជិល
ទ្រព្យធនមានពីណាអ្នកឥតសិល្ប
មិត្រឯណាមានអ្នកមន្ទិលឥតជនជាន
សុខឯណាមានដល់អ្នកប្រាសចាកមិត្រ
បុញ្ញាទ្ធិឯណាមានដល់អ្នកឥតភក្ដិ
សិរីមោក្ខយោគនៃព្រះនិព្វាន
មានពីណាដល់អ្នកគ្មានបុណ្យសាង ។

លោកនីតិបករណ៍ ។

# រឿងសព្វសិទ្ធិ·

(តមក)

របស់ភ្នំភក្តីអក្សរគត់ លោក ប៊ូ-ប៊ូ ចំឡងពីសាស្ត្រាស្លឹករឹត

ថ្ងៃក្រោយទើបឲ្យកូនសេនា ទៅពល់ក្រគឹតគប់ទាន លង់លុះទាល់គ្រប់អស់អង្គប្រាណ នាំនាថកល្យាណគ្នាខាងៗ ៗ កិត្តិសព្ទផ្សាយផល់ព្រះមហាក្សត្រ ព្រះបាទព្រហ្មទត្តក្សត្រខត្តិយា ព្រះអង្គក៏ព្រួយព្រះចិន្តា ផ្ទាប់សេនាមាត្យមន្ត្រី ៗ ឲ្យបាតភ្នាក់ងារដៅវាយគង ប្រកាសប្រាប់គេពេញផែនដី ថាកូនកុដុម្ពិកសេដ្ឋី នៅក្នុងបុរីកាសិក ៗ បើអ្នកឯណាវាសនាមាន អាចរំដោះបានទៅសន្តានា ទំនងនាងស្រួលប្រាប់ជាកំពូល យើងក៏មិនភពាក្យសំដី ៗ

អាមាត្យមន្ត្រីចាំបង្គាប់ ក្រាបលាចេញធាប់ប្រញាប់ខ្ញាំ ប៉ាវគង ប្រកាសប្រាប់តាមសេចក្ដី ទូទាំងបុរីជាវង្ស ៗ ពួកកូនសេដ្ឋីនិងកុដុម្ពីក៏ នាំគ្នាមកមីរព្រើនត្រៀបត្រា សឹងទៅនិយាយប្រាយប្រាជ្ញា ដោយនូវវោហារអធិប្បាយ ៗ ព្រះនាងពុំស្ដាប់ពុំស្ដីផង ពុំដូចបំណងអ្នកទាំងឡាយ ទោមនស្សត្រូវចិត្តដៀតគិតស្ដាយ ក្រហល់ក្រហាយគ្រប់អង្គប្រាណ ៗ

រឿងនេះលើកទុកពុំទាន់ថែង ទំងហាត់សំដែងដោយដើមដាន ពីទៅសព្វសិទ្ធិបុទ្ធិកាហាន កាលវិលបាត់ស្ថានព្រះអាចារ្យ ៗ ពេល

យប់ឈប់ផ្ទុំក្នុងព្រឹក្សព្រៃ លុះព្រឹកឡើងនៃទើបយាត្រា ទំងក៏លៀងនែប
អែបកាយា ដោយដងអរញ្ញវ៉ាពនាល័យ ៗ ទតសត្វសឹងសត្វចតុប្បាទ
ទ្វេបាទក្រុកជាតក្រាសក្រៃលក្រៃ លង់លុះគប់ប្រាំដណ្តប់ថ្ងៃ បមត្រៃ
ត្រាចដល់ស្ថានអាត្មា ៗ ទើបអ្នកចូលទៅក្រាបវន្ទី ជនកជននីទាំងទ្វេ
ហា ទាំងពីរសេដ្ឋីឃើញបុត្រា អរតេតទុបមាទើបសួរថា ៗ កូនអើយ
កូនប្រាសបាត់មុខទៅ យើងនៅសឹងទុក្ខពុំសុខសាន្ត ថ្ងៃនេះបានស្បើយ
ល្ហើយព្រួយពុំណា ព្រោះបានឃើញមាយាត្រាដល់ ៗ មួយទៀតកូន
ធ្ងៀតរៀនកេទផង បេះមេ្តចពូកែផ្ទើយយោបល់ ប្រាប់យើងឲ្យស្ទោះ
សោះព្រួយធ្ងល់ តាមដោយកិច្ចកលកូនរៀនបាន ៗ កុមារស្តែងស្តាប់
សព្វវាទី ជនកជននីសួរសេងសាន ទើបក្រា ដំកបទៅវិញថាន តាម
ដោយដើមដាទឥតមានខ្វះ ។ សេដ្ឋីកំពុងបែងបរបា សួរសាកបុត្រា
ឲ្យជាក់ច្បាស់ គាប់ជួនអាមាត្យម្នាក់ស្ទួងស្ទះ ដើរមកដល់ផ្ទះមហា
សេដ្ឋី ៗ បានជួបបានដល់បានយល់អគ្គ ព្រះពោធិវង្សពង្សដំនស្រី
ល្អលើសល្អលុបកពផែនដី មានចិត្តមេត្រីចាប់បេតនា ៗ សួរដំណឹងថា
ទើបតែទឹងវិល មកពីរៀនសិល្បសាស្ត្រា ទើបលោលះណាកបាកគ្រឹបា
វិលចូលកិច្ចការក្សត្រថ្កើងក្កល ៗ ដំណាលទូលតាមដោយដំណើរ ថា
យើងខ្ញុំដើរបានទៅដល់ ឃើញកុមារម្នាក់រូបល្អសល់ មែនមានយោបល់
យល់កិច្ចការ ៗ ជាកូនកោណ្ឌញ្ញមហាសេដ្ឋី នៅក្នុងបុរីយើងនេះណា

នាមឈ្មោះសព្វសិទ្ធិកុមារ ដែលមានសេក្តីសាស្រស ៗ ទើបវិលមក ពីតក្កសិលា រៀនសិល្បសាស្ត្រចេះចាំងរស់ ស្រួចស្រួលប្រសប់ជាបក់ ទ្បារៈ គ្មានខ្ចប់គ្មានខ្ចះខ្ចាយសត្រូវណា ។

សម្តេចមហាក្សត្រាធិបតី ជ្រាបហើយចក្រមានឧត្តារ ថា ចាស់ចុះឯង ចរយាត្រា ទៅយកកុមារនោះមកឆាប់ ៗ អាមាត្យបង្គំក្រាបលុតលោ ចេញ ចរម៉ែមាជាប្រញាប់ ទៅបញ្ចូនក្រមតាមបង្គាប់ ដល់ហើយទើបក្រាបមហា សេដ្ឋ ៗ ថាព្រះករុណាជាម្ចាស់ មានឧត្តារត្រាស់លើសិរសា ឲ្យយក សព្វសិទ្ធិបុត្រធារើ ចូលគាល់បក្រគុំបវាន ៗ ឲ្យទៅឲ្យទាន់ក្នុងថ្ងៃនេះ តែម្ដេសឃើញយូរយល់តុំបាន សេដ្ឋីស្តាប់ហើយភ័យញ័រព្រាណ ដោយ ពុំដឹងជាខុសផ្តើមអ្វី ៗ ទើបក្រាបសព្វសិទ្ធិបុត្រពុំងា កូនអើយព្រះមហា-ក្សត្រាធិបតី ឲ្យបាទៅគាល់ព្រះបក្រ កុំបង្អង់ឡើយ ៗ កុមារស្តាប់ ដាក់គាក់ព្រួយព្រើ ព្រោះបានលេចព្រះពាក្យពណ៌នា ទើបរៀបចាត់ចែង គេនិអង្គ កប្បវប្បកណ្ដាលបុំមព្រួយ ៗ ភោជ្ជញ្ញព្រាយក្រាបទាន់ទេមា ឲ្យរៀបអាហារម្ហូបចំណី ពិសាពិសាលត្រកាលថ្មី ឲ្យពន្យជិនស្រើនទឹង អាផា ៗ នូវកំលៀងដែលជាគ្គគាប់ . បរិភោគស្កល់ស្កប់សព្វប្រការ នាំគ្នាចាំងចំណីយាត្រា ដើរដេរចលផ្កា ក្នុងក្រុងត្រែ ៗ មើលមានទំនិញ ពេញគ្រាគ្រៀប ពាយរៀបរបស់មានដំឡៃ ខៀវក្រែព្រាស្លាក្នុងតម្លូកគាត់សេ្យ គោមកែវចរណែញ្ញរដារ៉ែ ៗ មានហាងបាំកំគាំងទំនិញ ទំនេបរទេចទិញ

សុទ្ធសឹងតែ គោញាក់ឆាប់ផ្សេងបៀរប៉ុបៃ វិលមុតការហៀរឡើងរួមពំនូ ៗ កាស៊ិលសារ៉ូសាមពីញូង សំប៉ាញសារ៉ុងតំតៅម៉ាំង ហារក្ងកម៉ានទូវស្រា-ខ្ចាំង ចំពាំងសារីលម្ងូណាត ៗ មាសេសារៈឧនម៉ិនមានខ្វះ ពៀសម៉ង ហ្វ្រូម៉ាសទូវម្ហូកធ្រ្ត ស្រោមជើងស្បែកជើងខ្សែក្រវ៉ាត់ ប្រេនពណ៌ពេក កាត់ឥតខ្ចប់ម៉ិយ ៗ មានហាងជាងទេសមួយនោះម៉ាញ សុទ្ធសឹងទំនិញស្រុក ប៉ុំបៃ ចាប៉ុប៉ាប់ចិមចាត់តែកោះសិយៀ សឹងមានដាវខ្សែក្រកន្ទល់ ៗ ហាង ចិនជាជួរពលសម្ងួ មានសុទ្ធសារពើទំនិញផង អនេកគ្រប់ពណ៌ល្អឥត ហ្វូង ប៉ុនប៉ង់ទិញអ៊ីឥតមានខ្វះ ៗ

ថ្ងៃពីស្រីផ្សារដែលលក់ពន បែកែក្តតារោនតើបប្រទះ ឃើញរូប សត្វសត្វល្អិតល្អល្អ ចំឡែកពេកណាស់ពុំដែលយល់ ៗ នាំគ្នាសំឡឹងរឹង ទាំងក្តែក ប្របៀតជ្រៀតជ្រែក កវ៉ារៀល ខ្លះចូលៈទៅជិតស្ទើរទើរដល់ ខ្លះទល់បង្អួចល្អួចលបមើល ៗ ខ្លះតែទន្ទ្រានតាមហុចស្មា ខ្លះស្រែកផេរ ថាមេកំព្រើល ឃើញប្រុសលោសូះដើញជដើល ខ្លះតេងងើលមើលចង់ ផាក ៗ ខ្លះថាបើសិនណាអញបាន ជាគូរម្រុប្រាណនៃបម្រើក ធានា ថែទាំចាំពិតក្តី មិនឡើអើអក់គ្រណាក់ចិត្ត ៗ ខ្លះថាទុតេល្អបំពោង មើលមកប្តីឯងខ្មៅក្រិត មេមួយសំពីកធ្វើបុកស្ទួ ដោះលេចមិនស្បៀត គិតបំទប្រាំង ៗ ប្រុងតែទិញស្អួតមកសិតសក់ មើលមុខអាក្រក់ស្អុក ស្មុកស្មាំង ពួកអ្នកលេងថ្មីប្តីបារាំង ញែកខ្ទ្រកក្បាំងយ៉ាងស្អាតក្អែក ៗ

រាំយោលរយោគពាក់ត្រចៀក ហើយស្លៀកសារុងប្រាំស្រីខែក ទោមពុំន
កខ្សែផ្កាគ្រៃក មើលទៅចំឡែកតែសក់ក្បាល ។ សព្វសិទ្ធិលក្ខណ៍
អ្នកមានខ្នាស ឃើញស្រីផ្ដេសផ្ដាសមិនស្រេចស្រាល គេចដើរបន្ទំចំ
កណ្ដាល ផ្លូវហើយត្រអាលចរយាត្រា ។ អ្នកខ្លះនិយាយគ្នាអឹងកង
ថាគ្រានេះម្ដងឃើញបានការ ប្រហែលព្រះទានទាចផ្លា ឬចិត្តចរចាចាប់
មេត្រី ។ បើយ៉ាងម្ដេះហើយនាងមិនស្នេហ៍ មិនស្ងួនមានតែខានបាន
ប្ដី ល្អលើសនេះទៀតគ្មានទេ ក្រែងតែក្សត្រីចាំជាតិក្រោយ ។ ស្រី
ខ្លះទាហានហានស្រែកហៅ ខ្លះយកប្រេងម្សៅទៅហុចឲ្យ ខ្លះឆើតប្រឆើត
ដើរបន្ទំហួយ រត់តាមបណ្ដោយជាមួយគ្នា ។ ព្រះពោធិសត្វគ្នាឆោមឆៅ
ឮស្រីស្រែកហៅដោយផ្លូវផ្គា រៀនអន់កង់ចិត្តស្បិតទាំពា ស្រួតស្រូត
លើលាពុំពាន់ ។ លុះដល់ទីព្រះពជពេងរម្យ ក្រញាក្រោបបង្គំក្សត្រប្រ
ពន្ធ ព្រះអង្គទៀតទតយល់ពុំលង់ ទើបទ្រង់ត្រិះរិះឈ្ងងយល់ថា ។ ទៅ
សព្វសិទ្ធិនេះល្អមែន ល្អលើសលើសដែនដែនលោកា រូបទ្រង់ហាក់ដូចវង្ស
ក្សត្រា គួរគ្រងសីមាទាក្រុងត្រៃ ។ បើឲ្យធ្វើធំពុំបង់គេ ទីងបាន
បិតថេរដាមហៃ កស្ដ្រពាសតាំងពួងមានគាល័យ អាស្រ័យតឹងពាក់
ពុំទាក់បាន ។ ចាំមើលម្ដងៈខះតើយ៉ាងម្ដេច ទីងសម្រេចកិច្ចខុស
ខាន តែថាបើនាងមិនស្មោះស្មាន អញក៏ទីងប្រាំងបោលលែងគិត ។
យល់ស្រេចស្ដេចមានព្រះដម្រាស់ ទ្រង់ត្រាស់ហៅហៅសព្វសិទ្ធិ ឲ្យ

ចូរទៅដល់តាល់ទៅជិត ទើបព្រះបពិត្របន្ទូលថា ៗ ហៃហៃសត្វសិង្ហ
ប្ញទ្ធិរង្សី ចូរទៅស្រង់នីធីតា ជាបុត្រីអញទៀបទៅ តាមដោយប្រាជ្ញ
ប្រាជ្ញាឯងស្រាប់ ៗ បើនាងចូលចិត្តតស្មោះសរ រាំតបតតាមសណ្ដាប់
អញនឹងឲ្យធ្វើជាគូនាប់ ដូចដោយដម្រាបកដវេណី ៗ ហើយលើកដំ
កើងឡើងចំពោះ ជាតួមកដឲ្យចំទ័ គ្រាស់ស្រេចសម្ដេចព្រះភូមី បង្គាប់
ហោធរៀបតាមការ ៗ

លង់លុះយប់យាមផប់ថម ឯពួកនាយគ្រុមជាអាចារ្យ នាំនាំពួក
ពន្យកុមារ ទីនក៏លៀនជាដេដ្ឋាថៃ ៗ ឡើងលើមន្ទីរនារីគ្រៀ ដល់ហើយ
ទើបអ្នកគង់នៅញ ប្រមក្ខាប្រាសាទរត្នបវ៉ណ ទើបសែកសិល្បសៃវិជ្ជា
ការ ៗ ហើយអ្នកលើកបាតុទាំងឡាយ ប្រណម្យសព្វាអធិដ្ឋាន ថា
ហេតុកុសលផលខ្ញុំបាន សាងពីបុកណាបុរេជាតិ ៗ បើនាងនេះជាគ
ជាគូព្រេង តាំងផលរៀងនឿងហៅឃ្លាឃ្លាត សូមទេពអាណាគតិតជួយញាតិ
ជួយឲ្យនាងនាងថៃងបតោ ផ្សងស្រេចតុលធំពន្យរកេ សែក
ជាសព្ទវិជ្ជាការ មន្ត្រស្រួមដកយកជួនចិន្តា ពីអង្គកាយាកលៀងស្ងួន ៗ
ទៅជាកប់ប៉ាំងនោះមាត់ទ្វារ ទើបអ្នកសន្ទនាសួរទាន់ចិត្ត ថាហៃហាមាត
ទ្វារអ្នកប៉ាំងបិទ បួរអ្នកអាណាតយើងតបក៏ ឲ្យអ្នកស្រាលជ្រើស
រើសទិតាន តពេ្រងមុនមានមកខបទា យើងនឹងបានស្ដាប់សព្ទការា តាម
ដោយប្រាជ្ញាទ្វារបេះស្រាប់ ៗ គ្រានោះដូងថៃនៃកលៀង ព្ភព្រះសួរ

សៀងស្នូរសាសព្ទ ទើបឆ្លើយពីក្នុងមាត់ទ្វារប្រាប់ ថាខ្ញុំសម្រាប់គ្រាន់តែបំពេ ៗ ពេលថ្ងៃគេបើកយប់គេបុំាង ណាមែនអនិច្ចំក្នុងឋានបិត រឿងអ្ហ៎មិនចេះមិនចូលចិត្ត មិនអាចរិះគិតនិយាយបាន ៗ បើម្ចាស់ចេះដឹងដណ្ដឹងនោះ សូមទ្រង់សន្ដោសពោសព្រោសប្រាណ នាំយកសំដែងឲ្យខ្ញុំបាន ដឹងដោនដើមដល់សោះធ្លល់ធ្លាយ ៗ

ក្សត្រីស្រីតេវិសុទ្ធសំក្តិ ឯកអគ្គបមជាតិឆើតគោមឆាយ បានឮមាត់ទ្វារអកំប្រាយ ថែងចេះលែបខាយដូចោះខ្ញុំ ៗ ខនទឹកពិធលធ្លល់ពេកក្ដាត់ ព្រួបព្រឹប្រមាត់សួតសរសើរ ថាអែះត្បូវនេះម្ដេចចេះស្ដី ក្សត្រីគិតតែក្នុងយោបល់ ៗ ហេតុព្រះសម្ភារពោធិសត្វ មានបុណ្យពេកក្ដាត់ឥតថ្លឹមដល់ មកណែនាំចិត្តឲ្យនាងខ្វល់ សែនសល់សង្ស័យក្រៃសោះសោ ៗ នឹងត្រិះរិះឲ្យតែបង់ស្លាប់ មាត់ទ្វារសារសព្វឥតឧបមា គិតហើយក៏មើបនែបកាយា ចុះពីក្រឡាបន្ទំ ៗ មកផ្លាប់សន្ធិយាព្រះកាណ៌ស្ដាប់ ព្រះសូរសៀងសព្ទរីងរោម្ជ ឯអង្គសត្វសិទ្ធរៀងបុទ្ធ មានព្រះវាចាទៅកាន់ទ្វារ ថាបងមិនចេះមិនចាំរឿង ចូរប្រុងស្ដាប់យើងនិងពណ៌នា ៗ តាមពាក្យបុព្វណាព្រេងព្រឹទ្ធា តមកយូរយារជាអង្វែង ៗ

ថាកាលនោះមានព្រាហ្មណ៍បួននាក់ ជាតិជាមិត្តភក្ដិកៀនដេរស្បែង រៀនសិល្បសាស្ត្រឆ្លាតគួរស្ញែង ចំណោះនោះឯងសិនចំណាន ៗ អ្នកមួយរៀនជានាយប្រមាញ់ តែលើកធ្នូបាញ់អ្វីសឹងបាន អ្នកមួយចេះហោរា

ណាប្រាណ ទាយគូប៉ុន្មានមិនមានខុស ៗ ឥតលាភមានលាភអាត្រេក ល្អ ជាទៅឬស ប្រាកដច្បាស់ អ្នកមួយនេះប្រាប់មនុស្សស្រីប្រុស ដែលស្លាប់ចំពោះប្រសាសន៍បាន ៗ អ្នកមួយនេះមន្តមុជក្នុងទឹក ជ្រាលជ្រៅពន្ទឹកអម្បាលម៉ាន ពោះអ៊ីធ្លាក់បាត់ក្នុងផលសាន មុជយកមកបានដូចប្រាថ្នា ៗ សម័យថ្ងៃនោះប្រុសទាំងបួន ជួនជាចូលទៅក្នុងព្រៃក្បា ឃើញដើមឈើមួយមែកសាខា ដុះប្រទះធ្លោមហាសមុទ្រធំ ៗ សំឡាញ់បួនប្រាណចូលឈរឈប់ ក្រោមម្លប់ឈើនោះជាសុខុម សំឡាញ់ទាំងបីស្តីថាខ្ញុំ ចង់សុំសួរអ្នកជាហោរា ៗ ថ្ងៃនេះយើងមានលាភអ្វីខ្លះ ចូរទាយឲ្យច្បាស់ៗសុក្ក បុរសនេះហោរាគូរលេខផា ឃើញក្រាមទំបជាថ្ងៃនេះឯង ៗ មានសត្វឥទ្រិយមួយជាតិពិ ពាំស្រីក្រមុំលួចពៅពង់ ហើរមកឥឡូវនេះជាក់ស្តែង គិតពុំនៃថ្ងៃក្រោយប្រាប់គ្នា ៗ ពេចលោលេចសត្វឥទ្រិយ ពាំនាងនារីលើវិហាស អ្នកនេះបាញ់នោះស្ទុះក្រោធា បាញ់ទៅម្ចាស់ត្រូវឥទ្រិយ ៗ ក្បែរណាកន្លែងដើមពីតាំងជាក់ នាងនោះក៏ធ្លាក់ក្នុងផលធី បុរសដែលរៀនមុជវារី ចុះក្នុងទឹកមុជជម្រៅ ៗ ដល់ហើយកៀកឱបក្រសោបព នាំនាងនោះមកមិនបង្អង់ នាងនោះសូទ្យបាត់ជីវិតបង់ មើលមុខគ្រែយង់គុះឲ្យស្លាយ ៗ បុរសនេះប្រាប់សកម្មសមន្ត ទើបតាំងជបជន្ទល់ប្រខ្លួបក្លាយ នាងនោះរស់ប្រាណបានដងកាយ កៀនបួនសប្បាយចិត្តពាល់គ្នា ៗ ប្រកួតប្រកែកដណ្តើមឈ្មោះ ចង់បាននាងនោះជា

ភរិយា រឿងនេះបុកណាលោកគណិនា ចូរបងមាត់ទារថាតាមពិត ។ នាងនោះចំពោះបានអ្នកណា តាមដោយប្រាថ្នាបងរិះគិត ដូចខែកលៀន ផ្ទៀងស្តាប់ផិត ធ្វើយថាពេគ្រព្រះគុណធូន ។ នាងនោះបើតាមដោយ ខ្ញុំថា ត្រូវបានហោកអ្នកគ្រូគេន គួរយកទៅធ្វើជាប្រពន្ធ គុណាគេទម្ងន់ ជាងទាំងអស់ ។

កាលនោះឯនាងនាថសុវណ្ណ គេសរសោកំណជាស្រីស្រស់ ឮទារ ថាឆ្នោះយល់ខុសសោះ នាងទឹកគ្លុចទាស់ព្រះចិន្តា ។ ទារនេះមិនដែលបេះ ស្រដី ស្តីហើយហេតុអ្វីឲ្យខុសការ នាងទបពុំបានមានវាចា ទារឯងមេ្តច ថាខុសនឹងច្បាប់ ។ ឯយើងយល់ឃើញដោយហេតុយល់ ថែលគិតឲ្យដល់ តាមសណ្តាប់ នាងនោះគួរបានទៅអ្នកចាប់ ឯកប្រាណបានធាប់ពីដលធី ព្រោះគេបានកាន់ដល់អង្គកាយ បីតពីឆ្ងាយនឿយឥន្ទ្រីយ យ៉ាងនេះទើប ត្រូវផ្ទុំវេណី ពិតពីបុកណគ្នានទិន្នា ។ ក្សត្រីស្តីនោះចំពោះពិត ព្រោះទ័យ ស្មានគិតថាមាត់ទារ ពេះស្រដីឯងពុំដឹងជា សព្វសំទិដ្ឋទាមាយាកល ។

គ្រានោះឯអស់ពួកអ្នកក្រុង បានឮសំឡេងនាងទៅដល់ ស្តាប់ច្បាស់ អាណាសផុតឆ្ងាយធ្ងល់ ក្រុំក្រុងខ្ញុំញ៉ាំទាំងស្មាន ។ លោនព្រុំ លំព្រះ កាណិមហាក្សត្រ ព្រះបាទព្រហ្មទត្តព្រះអង្គប្រាណ ស្តេចជ្រាបថាបុត្រ បានសងសារ ចរចាស្មោះស្មានទីងកុមារ ។

លុះដល់យាមពីរវេលាយប់ ភ្ញាក់ងាប្រារព្ធសព្វបញ្ហា ប្រាប់ពោធិ-

វង្សទ្រង់ចេស្តា ហើយនាំយាត្រាជិតខែនថៃ ។ គ្រានោះសព្វសិទ្ធិឫទ្ធិ ខាំងក្លា ស្ដូត្រសេកគាថាសិស្សសាស្ត្រសៃយ មន្តស្រូបដកតាញយកជូន ថៃ ចេញចាកពីញមាត់ទ្វារស្មោះ ។ យកទៅដាក់ក្នុងគោមយ៉ោ បានដូច ប្រាថ្នាមហាបុរស គ្មានអ្នកណាយល់ដល់តិចសោះ ទើបអ្នកពិគ្រោះសួរ ថាលា ។ ថាម្នាលចង្កៀងរឿងនេះ អ្នកចេះរឿងអ្វីបូរពណ៌នា ឲ្យយើង បានស្ដាប់សព្វមួយគ្រា គ្រាន់ជាចំណាំចាំទុកផង

គ្រានោះជូនថៃនៃគំលៀង នៅក្នុងចង្កៀងសបសាសង ថាខ្ញុំនោត នៅខ្លាកន្ទង់ ពុំដឹងដើមទងរឿងអ្វី ៗ សព្វថៃគ្រាន់តែជាក្អាក់ឆោ គេតែង អុជជាវេនប្រក្រតី តាមពេលព្រលប់យប់រាត្រី ឥតបីដឹងដល់កលបញ្ហា ៗ បើម្ចាស់ចេះចាំនាំពតិមាន រឿងរ៉ាវទិតានអតីតា សូមតានប្រោសប្រាប់ សព្វគ្រា ពិស្តារឲ្យខ្ញុំសុំស្ដាប់ផង ។ ព្រះរាជធីតាប្រាជ្ញាវៃ ជំកល់-ព្រះទ័យឥតសៅហ្មង ឃើញហេតុភេទផលដល់ពីរដង ប្លែកក្រៃកន្ទងជា អស្ចារ្យ ។ ចង្កៀងហេតុអ្វីចេះស្ដីស្ដង់ ចាំបែងដោះស្រាយដោយវោហារ ខឹងកើតគល់គិតដូចម្ដេចម្ដា កល្យាណគិតគ្រប់ឈប់ចាំស្ដាប់ ។

គ្រានោះកុមារវិការង្ស ទ្រើសទ្រូយព្រោយទ្រង់បានត្រង់ត្រាប់ ចង្កៀង ធ្លើយតបសបឥតស័ព្ទ ទើបប្រែប្រាយប្រាប់ទៅវិញខ្ញី ។ ចង្កៀងបង អើយបូរគាំងចិត្ត ស្ដាប់សព្វកាសិតសព្វសេចក្ដី ពីកាលអន្លើនព្រេងជាតិ ព្លគេស្រដីតមកថា ។

មានជាងសម្រាំងតាំងបួនប្រាណ ចំណានចំណេះចេះធ្វើការ ជាងម្នាក់ចេះគូររកន៍រូបា ម្នាក់ចេះចេនាឆ្លាក់ជាអង្គ ៗ ម្នាក់ចេះដប់ប្រុសឲ្យរស់ឡើង ម្នាក់ចេះតែងគ្រឿងប្រដាប់ធ្ងន់ សំលៀកបំពាក់ភក្ត្រផាត់ផង់ត្រូវតាមភាពតង់ជាប្រុសស្រី ៗ សម័យថ្ងៃមួយជាងបួនប្រាណ យកឈើមួយបានមកឃ្នាតខ្ទី រចនាធ្វើជារូបស្ត្រី តាមដោយសេចក្តីគណវិជ្ជា ជាងម្នាក់តាំងគូររូបសួនសាក់ ជាងម្នាក់មកឆ្លាក់ស្របចម្មមា ជាងម្នាក់សេកមន្តជបផន្ទា នៃរូបនោះរស់ឡើងស្រាប់ ៗ ជាងម្នាក់យកអស់សំពត់អាវកន្សែងស្បូត្រ សារសៃប្រដាប់ មកស្លៀកពាក់ឲ្យល្អចំណាប់ មើលទៅគួរចាប់ចិត្តចេតនា ៗ លុះតែងរូបនោះរស់ឡើងខ្ទី វិស័យជាស្រីចេះស្តីថា ឯជាងបួននោះលុះបានការ កើតដូចប្រាថ្នាដែលខ្លួនប៉ង ៗ ក៏កួចចាប់ចិត្តរតតគន យកជាប្រពន្ធតាមបំណង ដដែកវែកគ្នាស័ព្ទអឹងកង ទទាន ខ្ទះហោងពិបុកណ ៗ ចូរបងចង្កៀនគិតឲ្យល្អិត ដោយធូរក្រមក្រិត្យជាលំភាន នាងនោះទង់ទុកជាកឲ្យបាន អ្នកណាស្មោះស្មានចូរបងកាត់ ៗ ឯដួងហាទ័យនៃភិលៀង នៅក្នុងចង្កៀនកែវល្អក្តាត់ ទើបធ្វើយតតបសបវិងថ្វាត់ ថាខ្ញុំគិតកាត់តាមដោយត្រង់ ៗ ត្រូវប្រទាននាងនោះទៅអ្នកមួយដែលគេបានឲ្យគ្រឿងផ្តិតផ្គង់ មកស្លៀកបាំងបាំងកេរ្តិ៍ខ្មាសអង្គ ចិត្តចង់ឲ្យគង់កិរិយា ៗ

គ្រានោះក្សត្រីស្រីវរលក្ខណ៍ ល្អអង្គទ្រង់ភក្ត្រសមសក្តា ព្រួស្សូរ

ចង្កៀងឆ្លើយប្រស្នា ដោះស្រាយថាទៅមិនត្រូវចិត្ត ។ នាងទប់ពុំបានមាន សៅហ៍ហើយ ឆ្លើយតបឥតបីក្រែងក្រៅត្រិត្យ ថាម្ចាស់ចង្កៀងរុងរឿងឫទ្ធិ ហេតុអ្វីចៅបេះគិតបរិបា ។ យើងនៅទីនេះយូរលង់ណាស់ ពុំដែលប្រទះសព្វកាសា ឥឡូវបេះស្តីៗក្រៅការ ដែលថាយ៉ាងនោះក៏ខុសផង ។ យើងយល់ដោយពិតសុចរិតត្រង់ ថាកុំឲ្យបង់សត្យជាមួង នាងនោះគួរតែជាងធ្លាក់ហោង យកជាគូស្នេហ៍នោះទើបបាន ។ ព្រោះគេគន់គិតបេះធ្លាក់ធ្លោ គ្រប់គ្រឿងក្នុងក្រោមសង្គ្រោះព្រាណ បានកាន់ឃើញគ្រប់សព្វទិស្ថាន ហេតុអ្វីប៉ុន្មានដែលជាស្រី ។

ឯអស់បព្ចួកក្មេងតែងចាំស្តាប់ លុះបានឮសព្វសូរសៀង ព្រោះនាងសាសងគ្នងឆ្លើយខ្ញី ទើបរាយតន្ត្រីគងគោលា ។ ខ្ទះទ្រៀងខ្ទះពំផ្ទុំត្រែសង្ខ បង្ខំសព្វខ្ញាំងតាំងប្រាង្គប្រា-សាទស្នូរលេចឮដល់ព្រះកាណ៌ ព្រហ្មទត្តខត្តិយាធិបតីថ្វៃ ។ ព្រះអង្គត្រីត្រូវត្រួលបម្រើម នឹកស្បើមបុញ្ញាឫទ្ធិពិតពេកក្រៃ ថានេះយល់មានបុព្វទិស្ស័យ បានជាប្រស្រ័យនិយាយគ្នា ។

លង់លុះមប់ហ្វូរដល់យាមបី ឯកជមន្ត្រីចៅក្រាក់ង៉ារ នាំអង្គសព្វសិទ្ធរៀនប្ញទ្ធា ចូលហូសថ្នាលាជិតក្សត្រ ។ ទើបតោងសត្វត្រូវសុទ្ធ ផ្ចិលបមមកុដជាតិជនស្រី សេចក្តីដូច្នេះដោយបារមី បេញពីគោមខ្ទឹងបប្រាជ្ញា ។ យកទៅដាក់ក្នុងឋានព្រះស្រី ស្រេចទើបអ្នកស្តីសួរទៅថា

ពានអើយចូរពោលពាក្យបញ្ហា និទានឯណាដែលចាំចេះ ៗ ឲ្យយើង
បានស្ដាប់សព្ទសោះខ្វល់ ដ្បិតយើងគង់ល់ទល់ទុក្ខម៉្លេះ ទាល់តែខានដេក
យប់ថ្ងៃនេះ សូមបង់សំណោះតាមយោបល់ ៗ

ដួងចិត្តដែលចូលនៅក្នុងពាន ទើបមានបំឡើយឆ្លើយកិច្ចកល ថាខ្ញុំ
ពុំដែលពុំដឹងដល់ សែនសល់ពាល់សោះអស់ប្រាជ្ញា ៗ ដ្បិតខ្ញុំនេះជា
ពានព្រះស្រី ដំកល់សីងប៉ារីស្នា ពុំចេះពុំចាំនាំបញ្ហា តាមតែមេត្តា
ប្រោសទោសភ័យ ៗ បើម្ចាស់យល់ច្បាស់រឿងខ្វះហើយ សូមឆ្លើយ
ប្រាយប្រាប់ខ្ញុំឆាប់វៃ នឹងបានដឹងជាក់ចូលហឫទ័យ ដោយន័យបញ្ហា
អាថ៌និទាន ៗ

សុវណ្ណកេសរល្អល្អះល្អិត ទ្រង់គង់ឃុំងប់ទងដិតព្រះពាន លុះឮសំ
ឡេងថ្លែងពាក្យមាន នាងនឹកសន្និដ្ឋានដោយប្រាជ្ញា ៗ ថាពេញហៅ
ខ្វល់សល់សែនគិត ពីបុរាណព្រេងព្រឹទ្ធបុរាណ មិនធ្លាប់ឮពានដែលជាក់
ស្នា ចែងចេះចរចាអាថ៌ឧបាយ ៗ គួរបើជាបងនេះហើយ ក្សត្រី
ត្រាណត្រើយរឹងខ្វល់ខ្វាយ គិតសព្វគ្រប់អង្គផងព្រះកាយ ចាំស្ដាប់លែប
ខាយពានវាទី ៗ

សព្វសិទ្ធិបូរង្សបារមី ទើបនាំសេចក្ដីពាក្យពិតពី ព្រេងមកប្រាប់
ថាម្ចាស់ពានមណី ចូរតាំងសតិស្ដាប់និទាន ៗ យើងបានឮចាស់
លោកនិយាយ ថាពីមុនទាយនោះមិនមាន ចោរមួយនិត្យនៅព្រៃហិម·

ពាន់ ប្រកបធនធានច្រើនអនន្ត ។ សំដីប្រាប់តែរត្នសំពត់សៀ
ព្រោះវាអាស្រ័យដើរលួចប្លន់ ដណ្តើមចង់ចាប់កាប់ល្អិតល្អន់ បញ្ចាន់
រឹបរើយកតាមចិត្ត ។ មានទីគោហាជាលំនៅ ក្នុងព្រៃជ្រោះជ្រៅបាំង
ថេរបិត អ្នកណាហ៊ានដើរទៅដល់ជិត វាវាយធ្លោចល្អិតយកទ្រព្យ ។
សម័យមួយនោះចោរទ្រុស្តក្បត់ វារើទ្រព្យកត់សម្បត្តិវា ឃើញច្រើន
ពេកពិតឥតគណនា សំដីទ្រពាជា ។ មានដំឡៃ ។ មហាចោរទុច្ចរិត
គិតថប់ថា អាត្មាអញអើយសែនក្រក្រៃ ប្រសិនបើអញនេះក្សិណក្ស័យ
តែអង្គឯងនឹងឥតសន្តាន ។ ទ្រព្យធនទាំងនេះម៉ូរនឹងបាត់ ព្រាត់ព្រាយ
ខ្ចាយខ្ចាត់ចោលក្នុងបាំង ព្រៃព្រឹក្សក៏វិទស្សសាន សមនឹងខូចខានគ្មាន
ផលអ្វី ។ ចេះគួរគិតរកកូនបានម្នាក់ គ្រាន់នឹងពឹងពាក់រួមកក្តី ក្រោយ
ឥតពីឯងនឹងក្រែងក្រក្រី មានវាដើម្បីគ្រងធនធាន ។ មហាចោរគិត
ប៉ូលចិត្តហើយ ពុំយឺតយូរឡើយក្រោកឈរឈាន ចុះដើរចេញចាកព្រៃ
ហិមពាន្ត លុះលោចដល់បានស្រុកស្រែក្រៅ ។ មើលមានស្រុក
គេក្បែរមាត់ព្រៃ វិតក្រឡេកក្នុកក្រឡៅ ឃើ វាក្មេងវាលេងខ្ទលទៅ
ទើបដើរសំដៅទៅដល់ជិត ។ បានជួបបានឃ នយល់ច្បាស់ ក្មេង
មួយល្អណាស់ប្រពៃពិត ជាស្រីទំនងដំទង់ជិត ទៅលេងខាងមិត្តសំ
ឡាញវា ។ ចោរនោះស្ទុះចូលទៅដល់ចាប់ កៀកដាប់កើបឆាប់ក្រ
ឡាបក្លា តែប្រូបរួចដល់ដែនពនា ចរចូលគេហដ្ឋានបាំង ។ ហើយ

ដាក់កូននោះចុះប្រញាប់ ទៅរៀបប្រដាប់បាយទឹកបាន ឲ្យបរិភោគាជា
សុខសាន្ត ឥតមានភ័យគិតប្រថិតអ្វី ៗ កូននោះលុះនៅយូរពេលគ្រប់
បានប្រាំដណ្ដប់ស្បាន៍ ប្រកបរូបឆោមលោមពិសី ល្អស្រស់ហើសស្រី
ដទៃផង ៗ ពោរពេញស្រឡាញ់ពេញចិត្តស្មោះ ដូចកូនពិតពោះខ្លួនជា
ខ្ពង់ ពុំព្រាលពេកព្រមទេឲ្យហ្ន ចិត្តចង់ការណ៍គត់គិតប្រណី ៗ ថ្ងៃមួយ
នាង៍នោះមានគ្រោះឈឺ បង្កើតជម្ងឺពេកខាងស្រី ពុំជារដូវដូចប្រក្រតី សូម្បី
បាយទឹកប៉ុំពុំបាន ៗ រឹងឈឺចុកចាប់សព្វមំសំ ជ្រួញជ្រីវសម្បុរញ៉ាំពាំង
ប្រាណ ពោរនោះរឹតគិតគិតរវាន ភ័យឥតស្រាកស្រាន្តស្មានក្រែងក្ស័យៗ
គិតហើយចរចុះពីគ្រឹះពោ ចេញចាកអគ្គាគនាល័យ ស្វែងរកពេទ្យហ្មមក
កែខៃ ជម្ងឺកូនថ្លៃឲ្យសះជា ៗ លុះដើរទៅដល់យល់យាយចាស់ សង់
ផ្ទះមួយនៅប្រែបមាត់ទ្វារ គាត់ជាពេទ្យហ្មមើលពេកា ឯពោរនោះរាក់
ចូលទៅ ៗ ទៀងនិកើមណ្ឌលនៃដូនចាស់ លើកដៃសំពះពុំរង់នៅ
ថាលោកយាយអើយកុំយោលយៅ ខ្ញុំតោសរាក់ប្រៅសូមមេត្តា ៗ
ខ្ញុំមានអាសន្នធ្ងន់ខ្ពង់ណាស់ ប្រឹងស្ទុះមកលោកយាយនេះណា ចូរជួយខ្ញុក
ទៅសោះស្ដៅផង ដ្បិតទៅត្រូវការដោយកូនស្រី ៗ កើតពេកពេកឈាម
បង្ហាំង៍ផ្លូវ ពុំជារដូវដូចប្រក្រតី ដេកដាច់ពេលបាយទឹកចំណី ឈឺធ្ងួល
ឥតអ្វីប្រៀបដាំម្ហូង ៗ ចៅថប់ព្រួយចិត្តគិតតក់ស្លុត ភ័យ ប្អូរដាច់ខ្យល់
សោកសៅហ្មង យាយជំនាំអ្វីតិចក្តួចផង សូមមេត្តាជួយមកផលា ៗ

ឯដូនដកដាមេពេជ្យ បានស្តាប់សំដីហេតុចោរហោ គាត់រឹតភ័យ គិតថប់ថា ក្រែងចោរមោហារ៉ាធ្វើកល ៗ មកលួងបញ្ឆោតយកទ្រព្យ ពុំគាប់គាប់រ៉ាយដោយកំបាល់ រឹងភ័យព្រឺព្រាក់ហាក់ដាច់ខ្យល់ ព្រោះ គាត់ដឹងដល់ស្គាល់ចោរព្រៃ ៗ

ចោរឃើញយាយភ័យតក់ស្លុត ស្រយុតខ្លួនចុះដូច្នោះនៃ ទើប ថានៃយាយកុំគិតភ័យ អញ្ជើញឆាប់ឡើងណា ៗ

ដូនចាស់មិនដឹងគិតដូចម្តេច ទើបយកបង្វិចដែលវេចស្លា មក រៀបរាប់ស្របម្តេចថា អាគ្នាអញអើយគិតម្តេចអេះ ៗ ទីងខានមិនទៅ នៅនេះវិញ ក្រែងចោរនេះមិញរ៉ាដៀលតិះ រាគុំចង់ចាប់កាប់សំឡេះ ដូច្នេះតើទីងគិតម្តេចបាន ៗ តែរឹងពុំព្រមតាមពាក្យរ៉ា មុខជាមរណាជន្ម ពុំខាន ថប់មួយពុំដឹងដល់ដើមដាន ទើបខានរ៉ាទោះនៅត្រង់ណា ៗ គិត ហើយគាត់យកគ្រាប់ត្រសក់ រួចដក់ដាក់ថ្នក់ដោយប្រាជ្ញា ទីងពេយ តាមផ្លូវដែលយាត្រា ដំរុយទុកជាឆ្ងាយប្រាប់ ៗ ក្រែងមកមិនត្រូវ ផ្លូវត្រង់ណាទឹង ពុំដឹងដើមដានគ្មានគេប្រាប់ ទំនងមាគាំជាអណ្តាម៉ ទើប ចោរចុះឆាប់ដើរចេញទៅ ៗ

ដូនចាស់ក៏ដើរតាមក្រោយរ៉ា រូតរះមិម្មាពុំរង់នៅ ស្រូតកាត់ស្បូវស្បាត ផ្លូវគ្រោះលគ្រៅ សំដៅតម្រង់ត្រង់គុហា ៗ កាត់ស្រាយបង្វិចគ្រាប់ត្រសក់ ដែលដាក់នៅថ្នក់ពេយតាមផ្លូវ រៀនដល់មណ្ឌលដែលចោររ៉ា អាស្រ័យ

នៅផាតីបាន ៗ មហាចោរទើបចូលទៅក្នុងផ្ទះ ហើយហៅដូនចាស់
ឡើងទៅថ្កាន ដូនចាស់ក៏ចូលទៅចាប់ប្រាន នាងនោះក៏បានស្រាកស្រាន
ស្រាល ៗ ស្រេចគាត់ផ្សំថ្នាំត្រាំនឹងទឹក ឲ្យលាបឲ្យផឹកទៅតាមកាល
រើតែប្រុងប្រាប់សាច់ជំងាល ព្យាបាលបំបមថ្នមរក្សា ៗ តែពីរបីថ្ងៃក៏
សះស្បើយ បានល្ហើយបាត់ឈឺពីកាយា ឈាមសាច់តាំងគស់ក៏ស្រស់ថ្លា
ចំណីអាហារក៏សុំបាន ៗ ទើបយាយកិប្រាយលាចោរព្រៃ ទីងវិលវិលមកទី
បាន អាយចោរក៏ឃាត់គាត់ក៏ខាន នៅនោះប្រមាណខែមួយណា ៗ ដល់
ចូលខែចេត្រដិតបែកឆ្នាំ ភ្លៀងធ្លាក់សស្រាំសព្វព្រឹក្សា ត្រសក់ដែលយាយ
វាយផាសផា ដុះផិតជាចារដួរវៀបវៀង ៗ តាំងពីគុហាដែលចោរនៅ
ដក់ទៅទីបានដូនឥតល្ហៀង លូដើមទីងស្ទឹកដោយទឹកភ្លៀង មានផែក
ក្តាំងក្តៀងក្តាបក្តិបក្តា ៗ ថ្ងៃមួយនោះមិញចោរចេញចរ ចាកចោល
យាយមកចូលព្រឹក្សា ឯយាយនៅទីងក្នុងចោក គាត់រិះគិតថាទុអញអើយៗ
មិនគួរមានកាំគេនាំមក នៅជ្រកក្នុងព្រៃជ្រៅងាបត្រើយ ទីងលាចោរពុំមិន
បើកឡើយ ម៉េះហើយគួរគិតរត់ទៅផា ៗ គាត់ទិកជញ្ជាំងរពឹងសព្វ ទើប
ទាញប្រអប់វេចម្ជុល លបចុះចរចេញពីគុហា ស្រួតរូតគ្មានពេលឈប់បង្អង់ៗ
ដើរដោយដងព្រៃតៃបែរ ឃើញតែត្រសក់ដុះរហង់ រហ័សរះរូតស្រូត
ត្រាច់ត្រង់ ដល់ខ្ទមដែលសង់ក្នុងព្រឹក្សា ៗ ហើយគាត់ក៏ឡើងលើរំណោក
ទៀយណាស់ប្រេះដេកផ្អែកកាយា គាប់ជួនចោលភ្លុកតាំងដេកផ្ញា យល់

ឃើញកុមារមួយរូបល្អ ៗ ដើរចូលតម្រង់មកក្នុងផ្ទះ លើកដៃសំពះស្មូរ អង្វរ ថាឱយាយអើយខ្ញុំនេះទាល់ក្រ ប្រឹងចរស្វែងសួរលះគ្រឹះហា ៗ ត្រាច់មករើសរកស្រីរូបស្អាត ត្បិតខ្លួនខ្ញុំបាទគ្មានភរិយា នៅនេះក្រែងយាយបានស្គាល់គ្នា ប្រាប់ខ្ញុំកុំកខ្វះទៅគេ ៗ

ជូនតាស់ស្ដែងស្ដាប់សព្ទជាក់ហើយ ឆ្លើយថាចៅអើយចៅនឹកភ្នក ដើរសួរទាល់ផ្ទះពីនោះមក ចៅចង់រើសរកស្រីយ៉ាងល្អ ៗ យាយឃើញកូនស្រីចៅព្រៃម្នាក់ មានរូបគប់លក្ខណ៍គ្រប់វរ ទើបពេញក្រមុំសម្បូរស យាយទៅគង់រើបមកបាន ៗ បើចៅចូលចិត្តគិតត្រង់ណាះ ចូរចរទៅចុះតាមលំគាន មានកូនគ្រូសក់ផ្ទះដោយដាន តាំងតែពីបាននេះរៀងទៅ នោះជាតំរុយយាយត្រូយទុក ហេតុដល់មុខផ្ទះខាងនៅ តែទីនោះឆ្ងាយក្នុងព្រៃជ្រៅ គង់ឃើញស្រីទៅចៅពេញចិត្ត ៗ បុរសបានស្ដាប់ឮស្ដី ច្បាស់ ត្រេកអរពេកណាស់ត្រឹមសិរសើក ថាខ្ញុំនេះមានតែយាយអាណិត ជូនទៅបានបិតដឿតយាយស្គាល់ ៗ ហើយបានជាអ្នកនាំពាក្យពេចន៍ ដោយការបន្តិចតិចយាយស្គាល់ នោះទើបបានខាងជឹងរៀងកាល់ សោះទីង ពិកាល់យល់បានទាប់ ៗ ជូនតាស់ឆ្លើយឆ្លាស់ប្រាប់ទៅថា ចៅអើយធម្មតាការប្រញាប់ តែចាំគេនាំពាក្យប្រាប់ យាយឃើញឥតសព្វពុំគាប់សោះ ៗ ប្រុសស្រីក្រក្ដីដែលសុខុម មួយក៏ក្រមុំមួយក៏ទៅក្លោះ បើស្នេហ៍ត្រូវស្នេហ៍ ចិត្តគង់គិតស្មោះ គ្រប់គ្នាចាំងអស់មិនមួង ៗ

ចៅនោះលុះឮពាក្យសារស័ព្ទ ដូនចាស់ប្រាយប្រាប់សព្វដើមទង ទើបក្រាបសំពះបុះបាតជង្គង់ ដើរតាមគន្លងផ្លូវវៀងទៅ ៗ លុះដល់មណ្ឌលទីគុហា ក្នុងព្រៃពនាជ្រោះប្រែកជ្រៅ ថ្ងៃនោះដូនចៅចិត្តយោរយៅ ចេញចាកលំនៅទៅព្រឹកព្រ ៗ ចៅនោះដើរចូលទៅក្នុងផ្ទះ ពារពានតេចពះទាំងនោះណា ឃើញផ្កាកប់បាចចិត្តគិតស្នេហា ចរចាបែបង់លង់លុះបាន ៗ រួមរសស្វាគមកម្សេរត្បែ ខឹងនាងខុទអ្នកស្គ្រស្នោះស្នាន ក្រុមក្សាន្តសោមនស្សលុះស្ងប់ក្រោន្ត ចិត្តចាំងស្មសានបានពនា ៗ

ខឹងបែរនិយាយពីនាយចោរ ដើរតែឯកោឥតមានគ្នា ទៀបយប់ត្រលប់មកគុហា តាមវេលាសព្វមួយដង ៗ នាងនោះលុះបានឃើញតាពុក ដើរមកចំមុខក៏យកខ្នង ទើបលើកប្រុសឡើងមិនឲ្យហ្នង លាក់ក្នុងចំណាំងក្នុងកេសា ៗ ចោរនោះចរចូលដល់ក្នុងផ្ទះ ដូតទឹកជំរះហើយសុំស្វា ឯកូនក៏រៀបក្រយាហារ ឲ្យបរិភោគក្តាផ្អែតស្កប់ស្កល់ ៗ ពុំមានចាប់ក្លិតទឹកសង្កេត ទៅត្រង់ហេតុភេទបុត្រយោបល់ យកប្រុសមកភពាគប់ដោយកល ឥតដឹងដើមដល់យល់ថាផា ៗ យប់យូរចូលដេកដំណេកនៅ ព្រឹកឡើងចេញទៅពីគុហា រកកាប់ឈើវល្លិ៍ពល់វេលាទាល់យប់សន្ធ្យាទើបវិលមក ៗ កូននោះលុះតាពុកទៅព្រៃ ឥតនឹកនិរភ័យតែងលៃលក លូកទាញប្រុសវាដែលសៀតសក លើសក់នោះមកដេកសព្វថ្ងៃ ៗ បើពេលតាពុកជិតវិលវិញ យកប្រុសនោះមិញលាក់

សំបៃ ក្នុងធំដែលប្អូនអាចក្រៀមយ យូរក្រៃដល់គ្រប់ដប់មាសា ។ នាង
នោះចំពោះផើមពេញផ្ទៃ ហោរាព្រះមើលផាក់ភ្លាក់កាយា ថាអេះកូនអញ
ពេញអស្ចារ្យ មានបុណ្យឯណាផើមដូច្នេះ ។ មុខឲ្យពិកាលតួលំពេកណាស់
គួរសើចឲ្យប្រាសសោះព្រួយម៉្លេះ បើមិនខិនអត់បានមេ្តចកេះ ... នេះហៅ
វាបេះឲ្យហួសចិត្ត ។ ចិញ្ចឹមបង្ហាយស្តាយតិចអ៊ី ជាស្រីវ៉ល្អសធ្វើ
លើសត្រីតួ មិនក្រែងឯងសោះបុះហោរាផិត គណរកវាថ្មីស្រីចក្រៃ ។
មិនគិតរកកលមើលពុតវា ថាហើរម្នមាបុះបោកញ្ញ ពិទិលំនៅចាំងក្រក្រៃ
ចូលតភាល័យព្រៃព្រឹក្សា ៖ ទៅឃើញឈើមួយខ្ពស់ក្រៃលែង ផុះផត
នោះខនៀវស្រះថ្មុំ ទើបឆ្នៀងចូលឈប់ស្រប់កាយា ស្រួចហើយប្រវា
តានឡើងឱ្យ ។ តាល់ដល់ទៅចុងខ្ពង់ខ្ពស់ក្អាត់ សម្រាលតាត់តាត់មិនស្តី
បន្តិចឃើញមនុស្សប្រុសពិសី ម្នាកឯងឥតបីមានគ្នីគ្នា ។ ដើរចូលតម្រង់
មកក្នុងម្លប់ ទើបឈប់ឥឡូវមិនត្រឡប់ បានមួយស្របក្ខាក់កាយា ចេញ
ពីមាត់វាជាពីរនាក់ ។ ហើយថ្នមក្រសោបទបប្រលែង ដោយល្បែង
ដើម្បីក្តីស្នេហ៍ ស្រួចយកសំពត់មកពន្ទាក់ គ្របលើរុណក់ឲ្យដេកខ្ចី ។
ទើបវ៉ាចបេ្តុះក្នុងស្រះស្រង់ ផ្លូតទឹកលាងខ្លួនធ្លុលីដី នាងនោះល្អមើល
យល់ស្វាមី ចុះក្នុងស្រះស្រីស្រប់កាយា ។ លោខ្លាក់ប្រុសម្នាក់ធ្លាក់ពី
មាត់ មករួមប្រតិព័ទ្ធសេពកាមា រះពេលស្រួចពាមប្រុសនោះណា បាត់
ក្នុងស្មាដូចដើមដែល ។ ឯបាក្លែនោះខ្លួតទឹករួច សុះប្រេបឡើងមក

ស្លាបអន្ទើល ទូវប្រពន្ធពិតឥតប្រហែល ជាក្រោយគេក្រលនោះសោះ
ឡើយ ។ ប្រឹងតែប្រលោមលួកប្រឡែង ជាល្បែងរួមរ័កស្និទ្ធស្នេះ
ហើយ ប្រកៀកប្រគងប្រគិតកើយ ស្រេចៈហើយហាមាត់បៀមប្រពន្ធ ។
ដូចដើមដែលទើបក្រោកដើរ ពីក្រោមម្លប់ឈើបែរគេយគន់ មហាចោរ
ចិត្តទុច្ចរិតលន់ ចុះចាកពីមណ្ឌលព្រឹក្សា ។ ហើយស្រែកហាហៅថា
ចៅដើរ មានះបើដំណើរទៅស្រុកណា ចូរឈរឈប់សិនខ្ញុំសួរការណ៍
ចៅនោះឆ្លើយថាខ្ញុំដើរលេង ។ ចោរប្រាប់ទៅទៀតបើថាហ្នុះ ឈប់
ចុះដ្បិតខ្ញុំពិងឈ្លង ឃើញអ្នកឯងហៅពេញឥតព្រេង ប្រឹងដើរទទេង
មិនក្រែងក្រ ។ ខ្ញុំយល់គួបចិត្តអាណិតណាស់ ទៅផ្ទះខ្ញុំសិនរួចសិបរ
ផ្ទះខ្ញុំមិនឆ្ងាយសប្បាយល្អ ចៅនោះឆ្លើយតមកទៀតថា ។ ខ្ញុំគិតរំពឹង
ខឹងក្រឡាប់ វិលធាប់ទៅវិញនេះមិញណា តែថាបើអ្នកទឹងត្រូវការ ខ្ញុំ
សោកឥតថាទៅក៏បាន ។ នាយចោរទឹងចៅបុរសនោះ លន់លុះនិយាយ
សួរដឹងដាន បណ្ដើរគ្នាចូលដល់ឋាន ត្រេកអរពប់អានឥតសង្កា ។
ទើបចោរហៅទៅកាន់កូនស្រី កូនអើយចូរខំរៀបអាហារ ចាយទឹកទទួល
ភ្ញៀវពីសារ ប្រញាប់ធាប់ពីកុំរង់ ។ ដ្បិតគេត្រូវការមកលេងផ្ទះ មាន
គ្នាច្រើនណាស់ចូរកូនផង រៀបចាយឲ្យបានប្រាំមួយវង់ កុំរង់ក្រែង
ហួសពេលវេលា ។

(មានត)

# និទានចៅកាំបិតឈ្មោល

លោក ម៉ុន-អេង លេខាធិការ នៅមន្ទីរក្រុមប្រឹក្សាព្រះរាជអាណាចក្រ រៀបរៀង

## ធ្វើល្អ បានល្អ ធ្វើអាក្រក់ បានអាក្រក់

សឹងមាននិទានពីមាណពពីរនាក់បងប្អូន ដូចតំណាលតទៅនេះ :

ក្នុងកាលកន្លងយូរអង្វែងណាស់ទៅហើយ មានមាណពបងប្អូនពីរនាក់, បងឈ្មោះសោ ប្អូនឈ្មោះសុខ ជាកូនព្រាហ្មណ៍ម្នាក់មាននាមពុំប្រាកដ ឋិតនៅក្នុងនគរបម្លូកបុរី ។

ព្រាហ្មណ៍ជាមាតាបិតា អនិច្ចកម្មហោលទៅ នៅសល់កេរ្តិ៍មតិកជាច្រើន មានដីស្រែ ចំការនិងផ្ទះជាដើមទុកឲ្យកូន ។

មាណពបងប្អូននាំគ្នារកស៊ីចិញ្ចឹមជីវិតតទៅ, ឈ្មោះសោនិងទ្រទ្រាំនៅតែ ២ នាក់បងប្អូនពុំបាន ក៏ដើរស្វែងរកស្ត្រីយកមកធ្វើជាភរិយា ក៏ប្រទះបានឈ្មោះនាងសៅរ៍ នៅក្នុងស្រុកជាមួយគ្នា យកមករៀបការ, រូបនាងសៅរ៍និងចៅសោ មានសន្តានចិត្តប្រហែលគ្នា ។

លុះចៅសុខ ជាប្អូនមានវ័យចំរើនហើយ ក៏ទៅរៀបការយកឈ្មោះនាងសម នៅស្រុកជាមួយគ្នា យកមកធ្វើជាភរិយាដែរ ។

ចៅសោនាងសៅរ៍ ជាបងមិនចង់ឲ្យប្អូននៅរួមគេហដ្ឋានជាមួយ, ក៏ហៅចៅសុខមកប្រាប់ថា "អូនឯងត្រូវតែរៀបខ្លួនទៅធ្វើកូនខ្ទមតូចតាច

នៅបែកពីបង ទើបស្រួល" ។ ចៅសុខឆ្លើយទទួលថា "បាទ ស្រេចតែបងបង្គាប់យ៉ាងណាៗ ប្អូនទទួលតាមទាំងអស់" និយាយតែប៉ុណ្ណោះ ចៅសោនាងសៅរ៍ ក៏តាំងរៀបចំទ្រព្យមរតក ចែកឲ្យចៅសុខនាងសមៗ

ហេតុតែចៅសោនាងសៅរ៍ មានចិត្តអាក្រក់ក្បត់ប្អូនចង់បានរបស់ល្អៗ មានតម្លៃច្រើនៗ ក៏គិតគ្នាថា របស់ទ្រព្យទាំងអស់យើងចែកជាពីរផ្នែកគឺ ជារបស់ណាល្អៗ យើងសន្មតថា "របស់ញី" ត្រូវបានយើង, របស់ណាអាក្រក់ៗ សន្មតថា "របស់ឈ្មោល" ត្រូវបានប្អូន ។

គិតប្តីប្រពន្ធរួចហើយ ក៏ហៅចៅសុខនាងសមមកអង្គុយទល់មុខគ្នា ហើយតាំងចែក ។

លុះចែកទៅ ចេះតែថា "អានេះញី ត្រូវបានអញ អានេះញី ត្រូវបានអញ" លុះដល់យកកាំបិតព្រាក្ញាស់មុខគម្រិល ១ មក, ទើបចៅសោនាងសៅរ៍ប្រាប់ថា "អានេះឈ្មោល ត្រូវបានអូនឯង" ចៅសុខនាងសមក៏ព្រមថា "បាទ-បាស" ដោយហេតុខ្លាច ហើយស្រឡាញ់បងផង ។

របស់ទ្រព្យ ១ ផ្ទះបានតែកាំបិតព្រា ១ ល្អជាងគេទៅចៅសុខនាងសម, របស់ល្អៗ ក្រៅពីនេះ ចៅសោនាងសៅរ៍ យកទាំងអស់ ។

នាកាលចៅសុខនាងសម បានទទួលកាំបិតព្រា ១ ពីបងមកហើយ ក៏នាំគ្នាលាលា ទៅកាប់ឈើធ្វើខ្ទមមួយនៅ, ឆ្ងាយអំពីភូមិផ្ទះបង ។

លុះដល់ព្រឹកស្អែក នាងសមក៏និយាយគិតគ្នាប្តីប្រពន្ធថា "បង ខ្ញុំ

យើងក្រម្លេះមិនកេគួរទទួលទានបញ្ចុកជីវិតបាន បើមានតែកាំបិតព្រាតម្រិល ១ ដួងប៉ុណ្ណេះ បើតាមអូនគិតទៅ ឃើញតែទៅកាប់ឧសពីព្រៃយកមកលក់រាល់ថ្ងៃគ្រាន់បានប្រាក់កាសខ្លះ យកមកទិញស្បៀងអាហារទទួលទាន" ។ ចៅសុខឆ្លើយថា "អូនគិតនេះត្រូវល្អហើយ ចុះព្រឹកនេះ ប្អូនអូនឯងក្រោកពីព្រលឹម ដាំបាយវេចជាសំណុំឲ្យបង បងនឹងទៅកាប់ឧស" ស្វាមីភរិយានាំគ្នាចូលនិទ្រាជាសុខសម្រាន្តដល់មាន់រងាវ នាងសមក្រោកឡើងបង្កាត់ភ្លើងដាំបាយ អាំងត្រីប្រហុកឆ្អិន ក៏ខ្ចប់វេចទុកហើយស្រេច លុះប្ដីក្រោកឡើង ក៏យកទឹកជូនប្ដីលុបលាងមុខ នាងស្វាពារវេចខ្ចប់លើកជូនទាំងបាយ បារីស្លាទៅប្ដីទាំងអស់, ហើយនិយាយផ្ដាំនឹងប្ដីថា "អ្នកបង ៗ អញ្ជើញទៅកាប់ឧស ឲ្យបានសេចក្ដីសុខសប្បាយ ឲ្យបានឧសឆាប់ដូចបំណង ហើយរួតរះត្រឡប់មកផ្ទះវិញណា ! បង" ៗ

ចៅសុខបានទទួលយកសំណុំ ពីភរិយា ហើយនិងផ្ដាំមកវិញថា "អូន សម ខានយើងចេញក្រោយអូននៅផ្ទះ កុំដើរហោះហោលចោលផ្ទះ ក្រែងគេមើលងាយយើង" ៗ នាងសម ទទួលថា "ចាស" ចៅសុខក៏ចាប់យកកាំបិតព្រាចេញដើរសំដៅទៅព្រៃជ្រៅទៅ ៗ ក៏ប្រទះឃើញឧសឆាប់ក៏កាប់បាន ១ បាច់ ចងទុក ដល់ពេលល្មមស្រេកបាយ យកកាន់បាយសំណុំនិងកាំបិតស្វែងរកទឹកខ្ទង់ ដែលមានទឹកក៏ស្រាប់តែឃើញអណ្ដូង ១ នៅពីមុខ មានទឹកពេញត្រៀបមាត់ លើចៅសុខត្រេកអរ ក៏ដាក់បាយសំណុំ

ទីងកាំបិតអង្គុយចុះ នៅប្របមាត់អណ្តូង ស្រាយបាយសំណុំបរិភោគលុះបរិភោគឆ្អែតហើយ ខនក យកឃ្នង់ទឹកពីអណ្តូងទទួលទាន ស្រាប់តែកាំបិតឈោលអើលធ្លាក់ចុះទៅ ក្នុងទឹកអណ្តូងបាត់ទៅ, ចៅសុខស្រែកទ្រហោយំសៅង ស្តាយកាំបិតកេរ្តិ៍តែមួយដែលម៉ែឪបែកទុកឲ្យ, កំពុងតែយំរៀបរាប់ ស្រាប់តែលេចឃើញតាព្រាហ្មណ៍ម្នាក់ ផុសចេញពីក្នុងទឹកអណ្តូងឡើង កាន់ទាំងកាំបិតមាស ១ មកផង ហុចឲ្យចៅសុខប្រាប់ថា " ចៅឯងកុំយំស្តាយកាំបិតឈោលនោះអី យកកាំបិតតាឲ្យនេះវិញ កាំបិតមាសល្អជាងរបស់ចៅឯង"ៗ ចៅសុខប្រកែកថា "មិនមែនកាំបិតកេរ្តិ៍របស់ខ្ញុំៗ មិនយកទេ" ៗ តាព្រាហ្មណ៍ឃើញចៅសុខ មានចិត្តសន្តោសសុចរិតស្លូតត្រង់ពិត, កំមុជចុះក្នុងទឹកកាន់យកកាំបិតឈោល ហុចទៅឲ្យចៅសុខ ៗ ត្រេកអរណាស់ ស្រែកឡើងថា " លោកតាអើយ កាំបិតនេះបានពិតជាកាំបិតកេរ្តិ៍របស់ខ្ញុំ ៗ អរទីងព្រះគុណលោកតាណាស់ " មួយរំពេចនោះស្រាប់តែបាត់ចំកអណ្តូង ទីងតាព្រាហ្មណ៍ពីទីនោះទៅ ៗ

ចៅសុខដើរត្រឡប់មករកកន្លែងទុកគោវិញ ដល់ពាក់កណ្តាលផ្លូវ ជួបប្រទះឃើញមានស្ទឹងធំ ១ នៅពីមុខ មានទឹកពេញពោះស្ទឹង, ហើយឃើញមានក្បូនឫស្សីក្រាលក្តារចតនៅមាត់ច្រាំង , ឃើញតាព្រាហ្មណ៍ជាដដែលនោះ ដេញគោ១ហ្វូងបំរុងចុះស្ទឹង លុះតាព្រាហ្មណ៍ឃើញចៅសុខក៏សួរថា "អើចៅប្រុស អ្នកឯងទៅណាមកណា? ចូរមកអាយសិន ជួយ

ចែវក្បូនបម្លងគោតា ទៅដាក់ដល់ត្រើយខាងនាយបានឬទេ?"។ ចៅសុខឆ្លើយថា "បាទ បាន លោកតា" តាព្រាហ្មណ៍ក៏កៀងគោហ្វូងបញ្ចុះទៅលើក្បូនទាំងអស់ តាព្រាហ្មណ៍ឲ្យចៅសុខចែវមុខ, តាព្រាហ្មណ៍ចែវក្រោយ, ចៅសុខគិតតែពីចែវ ដរាបដល់ច្រាំងស្ទឹងខាងនាយ ។

កាលចៅសុខកំពុងតែចែវក្បូននោះ គោហ្វូងទាំងអស់វាបាននាំគ្នាជុះអាចម៍ទាំងដុំ ៗ ដាក់ពេញលើក្តារក្បូន អាចម៍គោនោះក្លាយទៅជាដុំមាសទាំងអស់, ប៉ុន្តែ ចៅសុខមើលពុំស្គាល់ជាដុំមាសទេ សំគាល់ថាដុំថ្មទៅវិញ ។

លុះតាព្រាហ្មណ៍ដេញគោហ្វូងឡើងគោកអស់ហើយ ក៏លាចៅសុខថា "ចៅអើយ ចែវក្បូនត្រឡប់ទៅត្រើយនាយវិញចុះ តាអរគុណនឹងចៅ តាលាចៅសិនហើយ" ។

ចៅសុខក៏ចែវក្បូនត្រឡប់មកត្រើយអាយវិញ លុះដល់ច្រាំងហើយ ក៏គិតក្នុងចិត្តថា "អញយកថ្ម ៣ ដុំទៅធ្វើប្រពន្ធអញ គ្រាន់គល់ធ្វើជើងក្រានអេះ" ចៅសុខលាក្រមារវេចដុំថ្មមាស ៣ ដុំស្ពាយដើរសំដៅទៅរកបាច់ទេស, រួចលីទេសវិលត្រឡប់មកផ្ទះវិញ ទំលាក់ទេសនឹងដុំថ្មទុកជិតផ្ទះ ស្រែកប្រាប់នាងសម ឲ្យយកទុកដាក់ផង ។

ឯនាងសមកាលបើបានឃើញប្តីសំឡាញ់ មកដល់ផ្ទះវិញ ក៏ត្រេកអរមហិមា រត់មកទទួលអបអរសាទរជាបំផុតហើយក្រឡេកមើលនាយកាយ

បានឃើញចាប់ចុះសន្ទឹកមាស ៣ ដុំ, ក៏សាកសួរចៅសុខពីរឿងទៅព្រៃកាប់ចុះស បានដុំថ្មមាសមក ។ ចៅសុខក៏យកប់រឿងការប្រាប់ភរិយាតាំងពីដើមដល់ចប់ ។

នាងសម ត្រេកអរកក្រៃពេកខ្លាំង ក៏ឡើបដាក់ត្រចៀកចៅសុខថា "ឲ្យហ្ន៎ លោកម្ចាស់ប្ដីអូនអើយ ដុំបីនេះ មិនមែនជាដុំថ្មធម្មជាតិទេ គឺជាដុំមាសសុទ្ធសាធ ប្រហែលជាទេព្ដាលោកដាក់ទានឲ្យយើងហើយ តើដុំនេះអស់ហើយឬនៅ ?" ។ ចៅសុខប្រាប់ប្រពន្ធថា "ខ្ញុំអីនៅសល់លើគាត្បូនគរគោក" ។ នាងសមថា "លោកម្ចាស់ប្ដីកុំមាត់ឲ្យគេដឹង ថ្ងៃស្អែកជូនបងទៅកើបយកមកទុកទៀត" ។

តាំងពីស្វាមី ភរិយា នាំគ្នាងូតទឹកជំរះកាយរួចបរិភោគអាហារ ចូលទំព្រានាសុខតាលក់ ។

នាងសមក៏ចាត់ចែងដាំបាយធ្វើមហូបចំរើនគាត ប្រញាប់ប្រញាល់ រួចក៏នាំប្ដីប្រពន្ធដើរចូលទៅក្នុងព្រៃ ទៅជួបប្រទះឃើញស្លឹងទឹងក្បូនបតនៅមាត់ច្រាំងដដែល នាងសមក្រឡេកឃើញសុទ្ធតែមាស តាំងដុំៗ ក្រហមឆ្អិនឆ្អៅ នៅពាសពេញលើគាត្បូន ក៏ប្រាប់ប្ដីឲ្យជូនទៅយកដុំមាសដាក់ពេញកញ្ជើល្អីអស់ហើយ ចៅសុខរែក នាងសមទូល នាំគ្នាវិលមកគ្រឹះឋានវិញ ក៏រៀបគូរទុកដាក់យ៉ាងប្រយ័ត្នប្រយែង ។

តពីថ្ងៃនោះមក នាងសមលែងឲ្យប្ដីទៅកាប់ចុះសទៀត ។

នាងសមបានយកដុំមាសខ្លះ ទៅបំណាយលក់យកប្រាក់មកទិញស្បៀងអាហារ ដែលមានទុជារសឆ្ងាញ់ ៗ នឹងជួលជាងឲ្យធ្វើភូមិ-ផ្ទះយ៉ាងធំ ជួលឈ្នួលប្រុស ស្រីទិញប្រដាប់ប្រដា សម្រាប់ប្រើប្រាស់មិនឲ្យខ្វះ អ្នកស្រុកនាំគ្នាមកពប់គេពឹងពារ រកប្រាក់កាសចាយវាយ ជានិច្ច ។

មានថ្ងៃមួយ ចៅសុខនឹងនាងសមនឹករលឹកដល់គុណមាតាបិតានឹងទេព្តាដែលលោកជួយផ្ដល់ឲ្យកើតមានទ្រព្យសម្បត្តិដ៏អស្ចារ្យដូច្នេះ ក៏គិតព្រមគ្នាថានឹងធ្វើបុណ្យឧទ្ទិសផលជូនដល់លោកអ្នកដ៏មានគុណ ក៏បានកំណត់ថ្ងៃនឹងធ្វើ ហើយយកប្រាក់ទៅទិញគ្រឿងឧបភោគបរិភោគ មកទុកជាស្រេច រួចហើយចៅសុខលាកិរិយាទៅប្រាប់អញ្ជើញចៅសោនាងសៅរ៍ជាបងឲ្យមកក្នុងពិធីបុណ្យនោះផង ។

លុះចៅសុខទៅដល់ក៏ជំរាបចៅសោនាងសៅរ៍ តាមដំណើរ ។

ឯចៅសោនាងសៅរ៍មានចិត្តមើលងាយប្អូន គិតតែក្នុងចិត្តថា "អាសុខក្រហាមយ៉ាងនេះ វាបានប្រាក់កាសពីណា យកមកបំណាយធ្វើបុណ្យធំដុំដល់ប៉ុណ្ណឹងកើត បើអញចែកឲ្យតែកាំបិតព្រាកញ្ចាសមួយ គត់មិនបង់ទៅបុណ្យនោះ ក៏ប៉ុន្តែទាល់គំនិតខានមិនកើត ក៏ប្រាប់ចៅសុខថា "ដល់ថ្ងៃធ្វើបុណ្យសឹមអញទៅ ប៉ុន្តែ ត្រូវឯងរកកន្ទេលក្រហាម មកក្រាលតាមផ្លូវរហូតតាំងពីមាត់ដំណើរផ្ទះអញ ទៅដល់មាត់ដំណើរផ្ទះឯង ទើបអញព្រមទៅ" ។ ចៅសុខទទួលថា "បាទ" ក៏លាបងវិលត្រឡប់ទៅផ្ទះវិញ

ប្រាប់ប្រពន្ធតាមដំណើរ ។ នាងសមក៏យកប្រាក់ទៅទិញកន្ទេលក្រហម បានគ្រប់ចំនួនរួចជាស្រេច ដល់ថ្ងៃកំណត់ធ្វើបុណ្យហើយ ក៏ចាត់ចែងមហូបអាហារគ្រប់មុខ និមន្តសមណព្រាហ្មណ៍នឹងចាស់ព្រឹទ្ធាចារ្យ ញាតិជិតឆ្ងាយ ឲ្យមកឆាន់នឹងទទួលភោជនាហារ, បានយកកន្ទេលក្រហមក្រាលតាំងពីមាត់ដំណើរផ្ទះខ្លួន រហូតទាល់ដល់មាត់ដំណើរផ្ទះចៅសោ រួចចៅសុខឡើងទៅអញ្ជើញចៅសោ ៗ ក្រឡេកមើលទៅដី ឃើញកន្ទេលក្រហមក្រាល ក៏ទាល់គំនិត ស្រែកប្រាប់នាងសៅឲ្យនៅចាំផ្ទះ ចៅសោរៀបខ្លួនចុះទៅជាមួយចៅសុខ ៗ

លុះដើរទៅជិតដល់ផ្ទះចៅសុខ ក្រឡេកមើលទៅឃើញភូមិធំទូលាយ មានដំណាំដើមឈើផ្កាផ្លែ សួនច្បារគ្រប់មុខ ផ្ទះធំសម្បើម មើលតែផ្ទះគហបតី ហើយឮតមាត់ភ្ញៀវនិយាយគ្នាលាន់ឮអឺងអែ ចៅសោក៏នឹកស្ងើមក្នុងចិត្តស្ទើរតែមិនហ៊ានដើរចូលទៅផង ក្រែងមិនមែនផ្ទះចៅសុខ ប៉ុន្តែដោយចៅសុខបង្ខំខ្លាំងណាស់ ក៏ដើរឡើងទៅលើផ្ទះ នាងសមរត់មកសំពះបងថ្លៃ អញ្ជើញពិសាភោជនាហារ, ចៅសោបរិភោគអាហារមានឱជារសយ៉ាងឆ្ងាញ់ពិសា ដែលខ្លួនមិនធ្លាប់បានបរិភោគសោះ ដរាបដល់ឆ្អែត ។ ចំណែកភ្ញៀវទាំងអស់ ក៏លាចៅសុខនាងសម វិលទៅផ្ទះរៀងខ្លួនវិញៗ

ចៅសោបរិភោគរួចហើយ ក៏គិតក្នុងចិត្តតែម្នាក់ឯងថា "អាសុខប្អូនអញ វាមានអីមានម៉្លេះ បានទ្រព្យពីណា បើអញចែកតែកាំបិតព្រាមួយ

មកវាទេ នឹកឆ្ងល់តែម្នាក់ឯង, នឹងគិតបុំទ្រព្យវាខ្លះ ដូចជានឹកខ្មាសមុខ ប្រពន្ធវា មិនគក់មិនលែង ក៏លបខ្សឹបសួរចៅសុខខ្សឹបតិចៗ មិនឲ្យនាងសមឮ, សួរពីហេតុដែលចៅសុខមានទ្រព្យសម្បត្តិស្តុកស្តម្ភដល់ម្ល៉េះ តើរកស៊ីអ្វីខ្លះ" ។

ចៅសុខ ស្រឡាញ់បងដោយស្មោះ ក៏និយាយប្រាប់ដោយត្រង់ៗ ពុំមានលាក់លៀមបន្តិចឡើយ ។

ចៅសោឮហើយ ក៏គាត់ទុកក្នុងចិត្តគិតថា ដល់ត្រឡប់ទៅផ្ទះវិញ និយាយប្រាប់ដល់នាងសៅជាភរិយា ។

វេលាទន់ទាបព្រះសុរិយាកាលណា ចៅសោលាចៅសុខនាងសមវិលទៅកាន់គេហដ្ឋាននៃខ្លួនវិញ, នាងសៅឃើញប្តីមកដល់ ក៏និយាយចំអកចំទយឲ្យថា "យ៉ុះមេចទៅ គាត់ឯងទៅធ្វើបុណ្យផ្ទះកាសុខមេសម បានអ្វីលិទ្ធខ្លះ បានជាមានមុខរីកប៉ុនដញ្ចាំងផ្ទះ" ។ ចៅសោតបវិញថា "ហាងអើយ អញមិនដឹងជាកាសុខប្អូនអញ មានដល់ម្ល៉ឹងទេ មានអីមានម្ល៉េះ" មានមិនបេះខ្លះមុខអ្វី, ផ្ទះឯង មិនបាននឹងកេរគោវាផង" ។

នាងសៅថា "មានអ្វីខ្លះទៅ វាធ្វើមេចបានជាមាន ឯងបានសួរវាទេ?" ។ ចៅសោឆ្លើយថា "អញបានសួរដែរ" ក៏តាំងចាប់និយាយពីរឿងចៅសុខទៅកាប់ខុសក្នុងព្រៃ តាំងពីដើមហូតដល់ចប់ នាងសៅចាំហាមាត់ចាំតែស្តាប់ លុះចប់ហើយនាងសៅថា "បើដូចនេះស្អែកឡើងយើងគិត

ទៅកាប់ខុស ឲ្យបានមាសច្រើនដូចជាអាសុខ" ចៅសោឆ្លើយថា "បាទអើយ សំណាងឯង ក្រែងមិនដូចសំណាងអាសុខមេសមប្អូនអញ, ក្រែងធ្វើទៅមិនបានសម្រេច នាំឲ្យនឿយខ្លួនឥតអំពើ"ៗ នាងសៅថា "កុំមាត់ច្រើន ស្រេចនឹងអញ" ឥឡូវគិតទៅដួតទឹកឡើងមកស៊ីបាយដេកយកកំឡាំង ព្រឹកឡើងក្រោកពីព្រលឹម ទៅកេកាប់ខុស អញទៅដែរ ។

ចៅសោនាងសៅឈប់ជជែកគ្នា, នាំគ្នាបរិភោគអាហាររួចហើយចូលនិទ្រាទៅ ។

ចំណែកនាងសៅ ជាស្រីសន្ដចិត្តអាក្រក់លោភលន់ យប់នោះដេកមិនលក់ទេ ចង់បានមាសឆាប់ៗ ដេកក្រោកៗ តិចតួច ។ ទន្ទឹងចាំតែឮមាន់រងាវ ទីងអាលក្រោកដាំបាយ លុះមាន់រងាវហើយនាងសៅបង្កាត់ភ្លើងដាំបាយ ដុតប្រហុកបុកអំបិលម្ទេសដុតត្រី ធ្វើស្រេចរួចជាកញ្ចប់រួចស្រេចជាស្ដី ឲ្យក្រោកកេកាំបិតព្រានងអាលទៅ, លុះភ្លឺស្រឡះចៅសោនាងសៅខ្វេលបាយសំណុំនាំគ្នាចេញពីផ្ទះ ដើរលះលោំងចូលក្នុងព្រៃជ្រៅ នាំគ្នាកាប់ខុសបាន ១ បាច់ ចងទុករួចស្រេចទើបឈប់, ហើយដើររកអណ្ដូងទឹកនិងអង្គុយបរិភោគបាយ ។

លុះដើរបានតែបន្តិច ក៏ស្រាប់តែលេចឃើញអណ្ដូង ១ នៅពីមុខនាំគ្នាឈប់អង្គុយចុះ ស្រាយបាយសំណុំ នាំគ្នាបរិភោគ, ចៅសោបរិភោគឆ្អែតហើយ ក៏ទនកាយយកដៃក្បង់ទឹកពីអណ្ដូងយកមកផឹក, ក៏ស្រាប់តែ

កាំបិតព្រាវអើលធ្លាក់ចុះ ក្នុងទឹកអណ្ដូងជ្រៅបាត់ ពេលនោះចៅ ហាក់ទួញយំសោកថា "ស្ដាយកាំបិតគេក្ដែម៉ើផ្ទៃកមកឲ្យ" នោះស្រាប់តែលេចរូបតាព្រាហ្មណ៍ ផុសចេញពីទឹកអណ្ដូង កាន់កាំបិតទ្រា ១ ហុចមកឲ្យចៅសោ ៗ ឆ្លើយប្រកែកថា "ទេ តាពុំមែនកាំបិតខ្ញុំទេ កាំបិតខ្ញុំ ធ្វើពីមាសកាំបិតតាឲ្យនេះជាកាំបិតធ្វើពីដែក ខ្ញុំមិនយកទេ" ។

តាព្រាហ្មណ៍គិតថា "យីអានេះ មនុស្សចិត្តអាក្រក់លោភលន់ពន់ប្រមាណណាស់ វាហ៊ាននិយាយមុសាវាទ បោកបញ្ឆោតអញផង" តាព្រាហ្មណ៍គិតតែប៉ុណ្ណោះ ក៏គៀសខ្លួនចេញ បាត់ទាំងទឹកអណ្ដូង បាត់ទាំងកាំបិតចៅសោផង ។

ចៅសោមិនដឹងធ្វើម្ដេច ក៏បបួលនាងសៅរ៍ដើរទៅរកកន្ទួងបាច់ទុសវិញ ក៏ស្រាប់តែឃើញមានស្ទឹងធំ ១ នៅពីមុខ មានទឹកពេញមាត់ច្រាំង ហើយឃើញក្បូនឬស្សី គ្រាលក្ដារមួយនៅចតមាត់ច្រាំង ទីងឃើញតាព្រាហ្មណ៍ដដែលនោះដេញគោ ១ ហ្វូង បំរុងចុះក្បូន ឃើញដូចចៅសុខជាប្អូនប្រាប់, ក៏លូកដៃគេះនាងសៅរ៍ឲ្យប្រាប់ថា "អុញហ្នឹ ឯងឃើញទេនៅពីមុខយើង, យើងមិនទាន់អស់សង្ឃឹមទេ" ។

ចៅសោនាងសៅរ៍ ទំដើរស្រូតទៅដល់ជិតតាព្រាហ្មណ៍ក៏ប្រែកសួរថា "អើតាអើយ ដេញគោហ្វូងទៅណា ? ឲ្យខ្ញុំជួយដេញឲ្យបានឬទេ? " ។ តាព្រាហ្មណ៍ឆ្លើយថា "ស្រួលហើយចៅ ចូលមកជួយដេញតា ហើយ

ជួយថែក្បួនចម្លងគោទៅក្រោយនាយផង ។

ចៅសោនាងសៅរ៍ នាំគ្នាជួយរៀបចំហ្វូងគោលើក្បួនអស់ ហើយ តាព្រាហ្មណ៍គាត់ឲ្យថែមុខ ចៅសោសុំថែក្រោយ ដោយគិតចាំគ្រងយកសាច់គោមាស ។

តាព្រាហ្មណ៍ក៏ព្រមចុះទៅថែមុខ ចៅសោថែពីក្រោយនាងសៅរ៍អង្គុយបៀត ក្អែកចេះតែរំពៃមើលទៅគូថគោក្រែងវាជុះសាច់ គោវាមិនជុះសោះ, ចេះតែនិយាយតិច ៗ ជាមួយប្រពន្ធថា "មេចគោនេះក៏វាមិនឃើញជុះសាច់ ១ ដុំសោះ" ក្បួនក៏ចេះតែលឿនទៅៗ ជិតទៅមាត់ប្រាំង, មានគោបាធំ ១ វាធ្វើជាលៀនសាច់ ១ ដុំធំ ក្រហមដូចមាស នៅជាប់ស្បឹមទងគូថមិនព្រមធ្លាក់មកសោះ ចៅសោនឹងនាងសៅរ៍អត់ទ្រាំពុំបាន, នាងសៅរ៍ក៏កេះប្ដីថា "ឲ្យលូកទៅ ៗ ចាប់យកមក" ចៅសោយកដៃឆ្វេងលូកផ្ទាប់ចាប់ដុំមាស គោបានខ្ទប់គូថភ្ជាប់ជាប់ដៃចៅសោ ។ ស្រែកយ៉ូយឲ្យតាព្រាហ្មណ៍ជួយផង តាព្រាហ្មណ៍នៅតែស្ងៀម ៗ ដរាបដល់មាត់ប្រាំង តាព្រាហ្មណ៍ដេញគោឡើងគោក វាយបំបោលគោ គោចេះតែបោលទៅ ៗ ដៃចៅសោជាប់ស្អិតក្នុងគូថគោបា ក៏ចេះតែរត់តាមក្រោយគោ នាងសៅរ៍ក៏ខំរត់លយតាមក្រោយទៅដែរ បានប្រហែលជា ៥០០ ម៉ែត្រទើបគោបង្អង់ ស្រាប់តែមានរូបអ្នកតាថ្ម ១ ប៉ុនរូបមនុស្សនៅអង្គុយបែនភ្នែនក្នុងពេងប្រក់ស្បូវ ១ នៅប្របផ្លូវនោះ ក្នុងមាត់អ្នកតាមានបៀមមាស ១ ដុំធំ ពណ៌ក្រ-

ហាមផ្អៅ, ចៅសោក្រឡេកឃើញដូច្នោះក៏មានចិត្តលោភ, ចង់បានដុំមាស ពីមាត់អ្នកតា, ក៏លើកដៃខាងស្តាំស្រវាលូកឆក់ដុំមាសពីមាត់អ្នកតា ៗ ខ្ទប់ ជាប់ដៃខាងស្តាំទៀត, តាខំរូតចោលទៅ បានរបូតដៃឆ្វេងចៅសោរួច មកវិញ, គោហ្វូងនឹងតាព្រាហ្មណ៍ទៅបាត់ហ្វូត ៗ

ឯអ្នកតាឯណេះវិញ ក៏ចេះតែបៀមបិទដៃស្តាំចៅសោបន្តិចម្តង ៗ ចៅសោឈឺស្រែកទ្រហោយំអោងឡាងរំពងទាំងដងព្រៃព្រឹក្សា ខំដកដៃ ចេញពីមាត់អ្នកតា មិនរួចសោះ ៗ

នាងសៅកែខំដើរទៅដល់ខ្ទមអ្នកតានោះ ឃើញចៅប្តីជាប់ដៃស្តាំ ក្នុងមាត់អ្នកតាវិញដូច្នេះ ក៏លាន់មាត់ថា « យើសអីចេះ រួចពីឯណោះ មកជាប់ឯណេះ បើអីចឹងឲ្យអញជួយធ្វើមេចទៅ » ៗ

ចៅសោក៏និយាយប្រាប់ថា « អញឃើញដុំមាសក្នុងមាត់អ្នកតា អញចង់បាន បានជាលូកយក, ឥឡូវមិនបានសំរេចមកជាប់ដៃស្តាំ, របូតដៃឆ្វេងពីគូថគោមក ៗ

ទើបនាំប្តីប្រពន្ធយំរៀបរាប់អង្វរករអ្នកតាឲ្យលែង, ឲ្យបានតែរួចខ្លួន ទៅផ្ទះវិញ មិនបានអីក៏ហើចុះ, បើទុកជាចៅសោនាងសៅយំកន្ទក់កន្ទេញ យ៉ាងណា ៗ ក៏អ្នកតាមិនលែង ៗ

ចៅសោនឹកក្នុងចិត្តថា « ឱហ្ន៎អញអើយអស់សង្ឃឹមជាគ្មានរួចរស់វិល ទៅផ្ទះវិញហើយ » ក៏លួងលោមទៅនាងសៅវិញថា អូនអើយអូន

បងមុខជាស្លាប់ចោលប្អូនឲ្យនៅមេម៉ាយតែម្នាក់ឯងហើយ ; ប៉ុន្តែណ្ហើយ ចុះបើមុខជានឹងស្លាប់ដដែល ចូរអូនខំតដិតមក បងនៅដៃម្ខាងដែរ សុំប្រាំឡើងបន្តិចឲ្យអស់ចិត្តបង បងលាស្លាប់ឥឡូវនេះហើយ ចូរអូនវិលត្រឡប់ទៅនៅរក្សាទ្រព្យសម្បត្តិឲ្យល្អ រកស៊ីចិញ្ចឹមជីវិតចាំស្លាប់ទៅតាមបង ជាខាងក្រោយចុះ ។

នាងសៅឮប្តីនិយាយដូច្នោះ ក៏ឥតគំនិតប្តីខោចចិត្ត ក៏ខិតប្តូលមកជិតឲ្យប្តីប្រឡែងដោយដៃម្ខាង ស្រាប់តែអ្នកតាគាត់ឃើញ គាត់អស់សំណើច គាត់សើចហា! ហា! បើកមាត់ធំឡើងៗ របូតដៃចៅសោត្រៃភិស, ពីមាត់អ្នកតា, ចៅសោដួលប្រុសស្ទុះងើបឡើងអរឥតឧបមា នាងសៅក៏ស្រែកថា កុំតែបានមកជិតអញ កុំអីឯងឆាប់អសារឥតការ ។

ចាំតែប៉ុណ្ណោះក៏នាំគ្នាតែចុះក្បូនខំស្រូតចែវអុំលែងហ៊ានមើលក្រោយ ដល់ត្រើយអាយគេបង្ហួតដល់ផ្ទះ តែខុស ១ ហាប់ក៏មិនវិលយកផង ។

តាំងពីថ្ងៃនោះមក ចៅសោនាងសៅរកស៊ីបេះតែត្រកៅ ៗ លក់ របស់ទ្រព្យស៊ីចាយពាល់តែអស់រលីង ។

រីឯចៅសុខនាងសមរកស៊ីបេះតែមានឡើងៗ សុខហូតដល់យាវជីវកៀនខ្ទង ។

មានចិត្តសន្តោស ទេព្តាប្រោសប្រាណ
លោភហួសប្រមាណ ទេព្តាផ្តន្ទា ។

x x x

# សុភាសិត ជាតិស៊ីរី និងលីបង់

(តចប់)

លោក ភិយ-ប៊ុក ដកស្រង់ រៀបរៀង

---

១៩៤- ការប្រយ័ត្នបន្តិចបន្តួច ប្រសើរជាងឱសថ១០០ គីឡូ ។

១៩៥- អប្បមាទធម៌ មានតម្លៃជាងឱសថ ពីរនៃភាគបី ។

១៩៦- សុខភាពមករបស់ ដូចជាមកតាមគូថមូល ពេលព្យាធិស្ទុះមកដូចជាទឹកជ្រោះហូរពីខ្នងភ្នំ ។

១៩៧- យកឱសថដាក់ក្នុកឈើ ប្រសើរទុកក្នុកឲ្យខ្លាក់ ។

១៩៨- គេអាចដកយកជាតិល្វីងបាន ដោយតែដែលមានជាតិល្វីងស្រាប់ ។

១៩៩- អនាម័យនាំឲ្យបានសុខភាព ២ ក្នុងភាគ ៣ ។

២០០- ដៃបុគ្គលសុចរិតជាជញ្ជីង ។

២០១- កូនជញ្ជីងតាមការថ្លឹង ។

២០២- កិត្តិយសនាយពាណិជ្ជបិតនៅត្រង់ទូដែក កិត្តិយសបណ្ឌិតបិតនៅត្រង់សៀវភៅ ។

២០៣- មនុស្សមានពូជល្អ មិនចេះកុហកទេ ។

២០៤- មនុស្សប្រស្រ័យគ្មានទីអណ្ដាត មិនមែនទីនស្នែងទេ ។

២០៥- ខ្លួបនរក ទឹងមិនទៅរក ។

២០៦- សាសនាជាមាតា បើយើងមានជោគជ័យ យើងភ្លេច បើយើងមានទុក្ខទោសភ័យ យើងចូលទៅពឹងពាក់ ។

២០៧- អ្នកណាធ្វើខុសថពុល អ្នកនោះនឹងដឹកនូវខុសថពុលនោះមិនខាន ។

២០៨- អ្នកណាសុំលន់តួទោសគេ អ្នកនោះទុកជាគ្មានទោស ។

២០៩- បំណាងអាក្រក់ ធ្លាក់ទៅលើអ្នកបំណាង ។

២១០- ការទុក្ខលំបាក មិនអាចសម្លាប់អ្នកណា ដែលមិនទាន់អស់អាយុសង្ខារ ។

២១១- គ្មានអ្នកណាគេចឲ្យផុត ពីជោគវាសនារបស់ខ្លួន ។

២១២- កិច្ចការទាំងអស់មកពីទម្លាប់ សូម្បីតែការគោរពសាសនា ក៏មកពីការទម្លាប់ដែរ ។

២១៣- គេបន់ស្រន់ ដើម្បីសូមសន្តោសក្រាប្រណីទោស ។

២១៤- បុគ្គល ៣ ពួកមិនជាទីពេញចិត្តនៃអ្នកផង: មនុស្សចាស់គ្មានការពិសោធន៍ សេដ្ឋីកុហក និងយាចកក្រអឺតអួតអាង ។

២១៥- ចូរអ្នកស្តាប់មហាជនពោល តែអ្នកកុំធ្វើតាមកិច្ចការមហាជន ។

២១៦- មនុស្សខ្វាក់ដឹកដៃមនុស្សខ្វាក់ មុខជាធ្លាក់ក្នុងអន្លង់ ។

២១៧ អ្នកណាជីកអន្លង់ ដើម្បីឲ្យគេធ្លាក់ អ្នកនោះនឹងធ្លាក់ខ្លួនឯងក្នុងអន្លង់ ។

២១៨- វិញ្ញូជនមិនបំពេញសកម្មភាព ដូចជាពពកគ្មានភ្លៀង ។

២១៩- ចូរអ្នកស្លាប់ដោយមានប្រាជ្ញា កុំឲ្យតែរស់នៅដោយល្ងង់ខ្លៅ ។

២២០- គេមិនអាចបង្ហាត់កូនឆ្កែព្រៃបានទេ ។

២២១ មាន់រងាវ ឬ មិនរងាវ ព្រះសូរិយាក៏គង់តែរះដដែល ។

២២២ អ្នកលេងនឹងឆ្មា ត្រូវអត់ធន់ទទួលនូវក្រចកឆ្មា ។

កែវមណីមិនមានសព្វភ្នំ
គជកុញ្ជរមិនមានសព្វគជេនជ័យ
ជាតិខ្លឹមចន្ទន៍មិនមានកើតសព្វព្រៃ
ប្រាជ្ញប្រពៃមិនមានកើតសព្វឋាន ។

លោកនីតិបករណ៍

# រឿងសាមកុក

## ភាគទី ៣៥

ឧកញ៉ាវិបុលរាជសេនា នូ-កាន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជការឯស បើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

រួចស៊ុនគួនក៏ឲ្យចាត់ចែងទុកបម្រុង ទីងហាត់ទាហានឲ្យព្រមព្រៀងគ្នា ទើបឲ្យជីវយីលើកទាហានជាកងទ័ពទឹក ទៅតាំងរក្សាភយ នៅមាត់កំពង់អេងហា ។

ពេលដែលជីវយីទៅតាំងទ័ពនៅទីនោះ តែងតែហ្វឹកហាត់សេនាទាហានគ្មានដាច់ ១ ថ្ងៃ ប្រាថ្នាទីងឲ្យស្ទាត់ជំនាញ ឯស៊ុនគួនក៏លើកទាហានទៅតាំងនៅដំបន់ឈីសង់ ក្រៅស្រុកកាំងតាំង ប្រាថ្នាទីងចាំការពារសឹកសត្រូវ ។

ឯទាហានដែលឡើពីប្រើឲ្យលបទៅស្តាប់ការ ខាងស្រុកកាំងតាំង

បានសេចក្តីនាំមកប្រាប់ឡៅពីថា ឥឡូវ ស៊ិនគួនលើកកងទ័ព ទៅយកស្រុកកាំងវៃហ សម្លាប់ហាំងចៅហ្វាយស្រុកស្លាប់ហើយ រួចលើកកងទ័ពត្រឡប់ទៅស្រុកកាំងតាំង សំរាំងនឹងត្រៀមពលទាហាន ឲ្យដើរយើលើកកងទ័ពទូកទៅតាំងនៅកំពង់អេងហ ខ្ទួនស៊ិនគួនលើកទាហានទៅតាំងការពារគេក្រស្រុកនៅដំបន់ឈើសង ៗ ឡៅពីដឹងដូច្នោះ ទើបឲ្យអញ្ជើញខុងបេងមក ហើយអធិប្បាយពីរបៀង ឲ្យស្តាប់គ្រប់ប្រការ ៗ ខុងបេងនៅស្ងៀម មិនទាន់ឆ្លើយថាប្រការម្តេច ទទួលមានបំរើមកប្រាប់ឡៅពីថា ឡៅបឿវឲ្យអញ្ជើញលោកទៅស្រុកកេងជិវ នឹងបានប្រឹក្សាការពងការផង ខុងបេងបានឮដូច្នោះ ទើបនិយាយនឹងឡៅពីថា ដែលឡៅបឿវឲ្យមកអញ្ជើញលោកទៅប្រឹក្សាការពងការនោះ ព្រោះហេតុថាស៊ិនគួនសម្លាប់ហាំងចៅហ្វាយស្រុកកាំងវៃហស្លាប់ ដែលលោកនឹងទៅនោះខ្ញុំបាទតឹសូមទៅជាមួយផង នឹងបានជួយគិតការទាំងពួង ៗ ឡៅពីសួរថា បើយើងទៅដល់ឡៅបឿវហើយ លោកនឹងឲ្យខ្ញុំនិយាយដូចម្តេច ? ៗ

ខុងបេងតបថា បើលោកទៅដល់ហើយ ត្រូវទទួលសារភាពទោសនឹងឡៅបឿវមុនថា ដែលមិនបានទៅទទួលគំនាបពួកខ្ញុំពងការ ឲ្យចប់ចុងចប់ដើម ជាដំនួសលោកនោះ ឃើញថាខុសណាស់ទៅហើយ បើឡៅបឿវប្រើលោកឲ្យលើកកងទ័ពទៅវាយស្រុកកាំងតាំង លោកកុំកេលទទួល

ពាក្យ ចូរនិយាយការកែបែបព្រះដើយថា នឹងសូមត្រឡប់ទៅចាត់ចែងការឯស្រុកស៊ិនកៀសិន ។ ឡៅពីក៏ទទួលពាក្យហើយនាំខុងបេងនឹងទៀវហ៊ុយទូវអស់ទាហានប្រហែល ៥០០ នាក់ ទៅដល់ស្រុកកេងជីវ ទើបឲ្យទៀវហ៊ុយត្រៀមទាហាននៅចាំខាងក្រៅ ហើយឡៅពីនាំខុងបេងចូលទៅ, ឡៅពីគំនាប់ឡៅប៉ៀវហើយថា ដែលខ្ញុំបាទមិនបាននៅទទួលគំនាប់ខ្ញុំពជការនាំងពួងជំនួសលោក ឲ្យចប់ចុងចប់ដើមនោះ ជាទោសខុសលើខ្ញុំបាទណាស់ហើយ ។

ឡៅប៉ៀវបានស្តាប់ហើយក៏ឆ្លើយថា ដែលកើតហេតុទាំងអម្បាលណោះ ព្រោះតែយើងមិនបានរិះគិតផង លុះឯក្រោយទើបយើងបានដឹងសេចក្តី យើងនឹងឲ្យកាត់ក្បាលឈួម៉ជាមនុស្សមានទោសនាំមកស្នាលាទោសនឹងអ្នក តែទប្រឹក្សានឹងទាហានទាំងពួងនាំគ្នាសូមទោស ឲ្យលើកទោសចោលចេញ បើប្អូនមានសេចក្តីខឹងក្តៅក្នុងរឿងនេះ បងសូមកុំឲ្យប្អូនប្រកាន់ទោសខឹងតទៅឡើយ ។ ឡៅពីឆ្លើយតបថា ដែលកើតហេតុទាំងអម្បាលណោះ ក៏មិនមែនត្រឹមឈួម៉នឹងគិតធ្វើតែនៅខ្លួនឯងទេ ព្រោះឈួម៉ជាធំ មានចិត្តសុចរិតទៀងត្រង់ ខ្វាចក្រែងមានបក្ខពួកបាវព្រាវឈួម៉គប់គិតគ្នាធ្វើឯង ខ្ញុំបាទក៏ឥតប្រកាន់ទោសពៃរ៍អ្វីឡើយ ឡៅប៉ៀវឆ្លើយថា ឥឡូវស៊ុនគួនលើកកងទ័ពទៅវាយបែកស្រុកកាំងហែ សម្លាប់ហងចជាចៅហ្វាយស្រុកស្លាប់ហើយ បានជាបងឲ្យអញ្ជើញប្អូនមកប្រឹក្សាការពជការ

ប្រាថ្នាទឹងឲ្យប្អូនលើកទ័ពទៅវាយស្រុកកាំងតាំង ដើម្បីសងសឹកវិញ ។

ឡៅពីញជួហោះក៏ឆ្លើយថា ហងិចជាមនុស្សអាក្រក់មិនដឹងរិះគិតការអ្វី ចាំងមិនស្គាល់មនុស្សល្អទឹងអាក្រក់ ទើបមានទុក្ខមកដល់ខ្លួន ដែលលោកទឹងឲ្យលើកទ័ព ទៅវាយស្រុកកាំងតាំងនោះ ប្រសិនបើដឹងដំណឹងទៅដល់ស្រុកហ៊ូតោ ប៉ូច្ចូក៏ទឹងលើកកងទ័ពមកវាយយកស្រុកគេងជីវ លុះលើកទាហានមកជួយវិញ ក៏មិនទាន់ការឯកកងទ័ពស៊ុនគួន ក៏ទឹងលើកតាមមកជាប់គ្នាចាំងសង្ខាង មុខជាយើងទឹងបានសេចក្តីលំបាកមិនដឹងបើទឹងរេខ្លួនទៅខាងណា សូមឲ្យលោកត្រិះរិះមើលសិន ។

ឡៅប៉ៀវយល់ឃើញត្រូវផងក៏ឆ្លើយថា ខ្លួនបងសព្វថ្ងៃក៏កាន់តែចាស់ជរាណាស់ហើយ ចាំងពេលក៏បៀតបៀនរឿយ ៗ ណាស់ ប្អូនប្រុមកនៅជួយធ្វើរាជការ ក្នុងស្រុកគេងជីវផង បើយើងអស់បុណ្យវាសនាកាលណា ខ្លួនប្អូនត្រូវធ្វើជាចៅហ្វាយស្រុកគេងជីវតែម្តងទៅចុះ ។ ឡៅពីតបថា ខ្ញុំបាទមានជម្រះប្រាជ្ញាក៏តិច ចាំងកំឡាំងក៏ទន់ខ្សោយ ដែលបានកមជ្រកកោនវ័តពីងបុណ្យលោកនៅទីនេះ មានគុណធ្ងន់កេទីបំផុតគ្មានដែលលោកទឹងឲ្យខ្ញុំបាទទទួលស្ដីពីជការជំនួសលោកទៅនោះ មិនគួរឡើយតែគុណរបស់លោកគ្រាន់តែខ្ញុំបាទនៅប៉ុណ្ណោះ ក៏ជាទម្ងន់ណាស់ទៅហើយខ្ញុំបាទគ្រាន់តែជួយទំនុកបំរុងទៅតាមសតិបញ្ញា លុះនិយាយហើយក៏នាំខ្លួនបេងលាឡៅប៉ៀវចេញទៅ នៅសំណាក់អាស្រ័យខាងក្រៅ ។

ខុនបេនសួរឡៅពីថា ដែលឡៅបឿនិយាយតាំងពីម្សិលនេះប្រាថ្នានឹងឲ្យស្រុកគេនជិតមេលោក ហេតុម្តេចបានជាលោកមិនទទួល ព្រាងើយដូច្នេះ ៗ ឡៅពីតបថា ឡៅបឿមានគុណានឹងខ្ញុំច្រើនណាស់ កូនចៅរបស់គេក៏មាននៅជាច្រើន បើខ្ញុំទៅត្រេកអរទទួលយកសេចក្តីគរហានិន្ទានឹងមានដល់ខ្លួនខ្ញុំទៀតៗ ៗ ខុនបេនឆ្លើយថា ខ្លួនលោកមានសេចក្តីសុចរិតពិតត្រង់ណាស់ ទទួលឡៅគីជាបុត្រច្បងរបស់ឡៅបឿចូលមកសួរឡៅពីៗក៏ហៅឲ្យចូលមកអង្គុយទីសមគួរ ឡៅគីគំនាប់ហើយក៏យំពណ៌នារឿងរ៉ាវឲ្យឡៅពីស្តាប់ថា សព្វថ្ងៃនេះនាងឈូហ៊ុយនជាម្តាយចុងខ្ញុំបាទ មានចិត្តបាំសាប្រាថ្នានឹងប្រទូសរ៉ាយ ឲ្យខ្ញុំបាទដល់នូវសេចក្តីស្លាប់ លោកចូរអនុគ្រោះជួយរិះគិត កុំឲ្យភ័យមកដល់ខ្លួនខ្ញុំបាទផងចុះ ៗ

ឡៅពីឃើញខុនបេនញញឹមដូច្នោះ ក៏និយាយនឹងខុនបេនថា សូមឲ្យលោកជួយរិះគិត ឲ្យឡៅគីផង ៗ ខុនបេនឆ្លើយថា ដែលនឹងឲ្យរិះគិតការក្នុងផ្ទះផងនោះឃើញថាមិនបានទេ ៗ ឡៅគីក៏លាចេញមកវិញ ៗ ឡៅពីក៏ចេញមកតាមបន្ទាប់ហើយខ្សឹបប្រាប់ឡៅគីថា ព្រឹកស្អែកយើងនឹងក្លែងឲ្យខុនបេនទៅសួរគេ អ្នកចូរអង្វរសាកសួរឲ្យខុនបេនជួយគិតប្រាប់ដំណើរទំនងឲ្យបាន ឡៅគីទទួលពាក្យហើយក៏លាទៅវិញ ៗ

លុះព្រឹកឡើងឡៅពីក្លែងធ្វើជាឈឺ ឲ្យអញ្ជើញខុនបេនចូលមកនិយាយថា ពេលម្សិលមិញឡៅគីមកគំនាប់យើង ថ្ងៃនេះត្រូវតែយើងនឹង

ទៅសួរវិញតាមប្រវេណី ទទួលខ្ញុំមិនស្រួលសប្បាយ ពេកកប៉ូរទៅជួសខ្លួនខ្ញុំម្ដងចុះ ។ ខុនបេនទទួលពាក្យហើយក៏ទៅផ្ទះឡៅគី លុះទៅដល់ក៏ទទួលបដិសណ្ឋារៈតាមទម្លាប់ទៅវិញទៅមក ឡៅគីក៏អធិប្បាយពីរឿងឲ្យខុនបេនស្ដាប់ហើយថា ខ្លួនខ្ញុំបាទសព្វថ្ងៃនេះ ម្ដាយចុងគិតប្រទូសរ៉ាយជាដរាប សូមលោកជួយអាណិតអាសូរណា នាំពន្យល់ កុំឲ្យមានភ័យមកដល់ខ្លួន ព្រោះខ្ញុំបាទសព្វថ្ងៃ មានសេចក្ដីព្រួយខ្លាំងណាស់ ។

ខុនបេនឆ្លើយតបថា ខ្លួនខ្ញុំជាភ្ញៀវមកពីក្រៅ មិនត្រូវបង់ដឹងកិច្ចការខាងក្នុងទំលំនៅ ឲ្យញាតិសន្ដានបងប្អូនរបស់អ្នកបែកបាក់គ្នានោះ មិនគួរសោះ បើប្រសិនសេចក្ដីនោះជ្រួតជ្រាបទៅដល់ឡៅប៉ៀវជាបិតាអ្នក យើងក៏មិនរួចពីសេចក្ដីខុស" ហើយខុនបេនក៏ក្រោកឡើងលាមកវិញ ។ ឡៅគីក៏ក្លែងបញ្ឆោតថា លោកកុំអាលអញ្ជើញទៅ សំបុត្របណ្ណរបស់ខ្ញុំបាទមាននៅ ១ ច្បាប់ អញ្ជើញលោកឡើងទៅមើលលេងលើល្វែងលើសិន ទើបដឹកដៃខុនបេនឡើងទៅលើឡៅ ហើយឡៅគីក៏យំអង្វរខុនបេនថា "ជីវិតខ្ញុំបាទនឹងដល់នូវសេចក្ដីវិនាសព្រោះមាតាចុងម្ដងនេះហើយ ហេតុម្ដេចបានជាលោកមិនអាណិតជួយដោះទុក្ខឲ្យខ្ញុំបាទបានរួចពីសេចក្ដីស្លាប់ផង បើលោកមិនប្រោសប្រណីទេ ខ្ញុំបាទក៏សុំស្លាប់កន្លែងនេះឲ្យហើយទៅ" ហើយឡៅគីក៏ហូតយកក្រិសចេញមកនឹងចាក់សម្លាប់ ។

ខុនបេនឃើញដូច្នោះ ក៏ភ័យស្លុតស្មារតីស្ទុះទៅកន្ត្រាក់ក្រិសពីដៃ

ទៀតមកទុក ហើយឃាត់ថា « អ្នកកុំអាលធ្វើជីវិតរបស់ខ្លួនឲ្យអន្តរាយដូច្នេះ ខ្ញុំនឹងជួយសង្គ្រោះអ្នកឲ្យរួចពីភ័យឲ្យបាន ហើយថាខ្លួនអ្នកក៏បានរៀនសំ-បុត្រដែរ មិនដឹងឬ? ក្នុងទិតានស្ដេច ១៨ ព្រះអង្គ បានគ្រងរាជសម្បត្តិ១៨ នគរនោះ ។ ព្រះចៅជិនហៀនកុងបានគ្រងស្រុកចិន ព្រះមហេសីនោះ មានព្រះរាជបុត្រ ២ព្រះអង្គ ឈ្មោះស៊ុនសេង ១ តុងយី ១, ឯនាងលីគីជា ព្រះស្នំក៏មានបុត្រ២ អង្គដែរ ឈ្មោះហ៊ុយបេ១ តុកជូ១; លុះអំណើះតមកព្រះ មហេសីសុវណ្ណគត រាជសម្បត្តិក៏ទំនងបានដល់ស៊ុនសេងនឹងតុងយី ឯកូន យើងទាំង២ ក៏នឹងនៅក្រោមកណ្ដាប់ដៃគេ បើដូច្នេះ យើងត្រូវគិតកលឧបាយ ឲ្យព្រះចៅជិនហៀនកុង សម្លាប់ស៊ុនសេងនឹងតុងយីចេញ រាជសម្បត្តិក៏ នឹងបានដល់កូនយើង ” ។

សម័យ ១ ពេលយប់ប្រហែលយាម ៣ ថ្វាយ នាងលីគីភ្ញាក់ពីដេក ក៏ធ្វើជាទួញយំជំទុកមានប្រការផ្សេងៗ ។ ព្រះចៅជិនហៀនកុងទ្រង់ឃើញ ក៏ត្រាស់សាកសួរនាងលីគីថា «ហេតុអ្វីបានជាយំសោកដូច្នេះ?» ។ នាង លីគីទូលថា ខ្ញុំម្ចាស់យល់សប្តិឃើញថា ព្រះមហេសីនៃព្រះអង្គដែល សុគតទៅនោះ ដើរចូលមកដល់ទីខាងក្នុង ហើយយំថា អត់បាយទឹកចំណី អាហារបរិភោគ ខ្ញុំម្ចាស់ភ្ញាក់ឡើងឲ្យមានសេចក្ដីអាណិតខ្លោចចិត្ត បានជា យំសោកដូច្នេះ ” ។ ព្រះចៅជិនហៀនកុងមិនដឹងកលឧបាយនៃស្ត្រី ទើប ត្រាស់ថា ប្អូនកុំយំសោកសៅឡើយ យើងនឹងតែងតុះទៅសែនឲ្យ មហេសីនៃយើងបានបរិភោគអាហារ ” ។

លុះវេលាព្រឹក ស្ដេចឲ្យហៅស៊ិនសេនទីនគុនយីជាព្រះរាជឱរស ចូលមក ហើយប្រាប់សេចក្ដីទាំងពួនឲ្យស្ដាប់ ឲ្យរៀបតែងតុះដាក់ចំណីអាហារយកទៅសែនសពព្រះមាតា ស៊ិនសេនទីនគុនយីមានសេចក្ដីអាណិតមាតាណាស់ ទើបនាំគ្នាធ្វើតាមព្រះរាជឱង្ការបង្គាប់ ហើយយករបស់ដែលសែននោះ មកថ្វាយព្រះបិតាសោយតាមទំនៀម ។ ឯនាងលីគីក៏យកថ្នាំពិសទៅលបដាក់ក្នុងចំណីទាំងពួង លុះព្រះចៅជិនហៀនកុងនឹងរៀបសោយ នាងលីគីក៏ទូលទាស់ថា ព្រះអង្គកុំអាលសោយ ព្រោះរបស់នេះធ្វើនាំមកពីខាងក្រៅ នឹងទុកចិត្តមិនទាន់បាន ក្រែងមានអន្តរាយ សូមឲ្យទ្រង់ពិសោធមើលសិនសិមសោយ ។ ព្រះចៅជិនហៀនកុងទ្រង់យល់ឃើញផង ទើបឲ្យយកអ្នកទោសអស់អាយុ ដែលនៅក្នុងគុកមកស៊ីចំណីនោះ ចំពោះព្រះភក្ត្រ លុះអ្នកទោសនោះបរិភោគចូលទៅ ក៏ដល់នូវសេចក្ដីស្លាប់មួយរំពេច ព្រះចៅជិនហៀនកុង ឃើញដូច្នោះក៏ទ្រង់ព្រះពិរោធ ទើបទ្រង់ត្រាស់ថា ស៊ិនសេងទីនគុនយីដាក់ថ្នាំពិសក្លែងឲ្យយើងស្លាប់ ប្រាថ្នានឹងដណ្ដើមរាជសម្បត្តិ ទើបបង្គាប់ឲ្យនាហ្មឺនទាំងពួង ទៅចាប់យកខ្លួនស៊ិនសេនទីនគុនយីសម្លាប់ចោល នាម៉ឺនទាំងពួងក៏ចេញទៅ ។

ខណៈនោះ មានមនុស្សស្និទ្ធស្នាល លបទៅទូលព្រះរាជឱរសទាំង ២ ព្រះអង្គ តាមដំណើរដែលព្រះរាជបិតាខ្ញាល់គ្រប់ប្រការ ។ ឯកុង

យើជាព្រះអណ្ដជជីនដូច្នោះ ក៏ប្រឹក្សានឹងស៊ុនសេនជាព្រះរៀមថា ឥឡូវភ័យមកដល់ខ្លួនយើងហើយ យើងត្រូវតែរត់ឲ្យរួចខ្លួនទៅសិន ។ ស៊ុនសេនតបថា ខ្លួនយើងជាបុត្រព្រះរាជបិតានឹងដាក់ទោសប្រហារជីវិត បើនឹងរត់ទៅឲ្យផុតពីភ័យ ក៏ដូចជាគ្មានសេចក្ដីកតញ្ញូនឹងព្រះបិតា, ប្រការ១សោត ធម្មតាអ្នកដែលធ្វើជាសេនាបតីជាខ្ញុំរាជការនោះ, បើទោះបីធ្វើសេចក្ដីខុស ដោយប្រការឯណាមួយក្ដី សូម្បីព្រះមហាក្សត្រនឹងដាក់ទោសនោះនឹងរត់ឲ្យរួចពីព្រះរាជទណ្ឌនោះក៏ពុំគួរ ដូចជាគ្មានសេចក្ដីសត្យសុចរិតត្រង់នឹងផែនដីនៃព្រះមហាក្សត្រ ដូច្នេះខ្លួនបងនេះនឹងបង់សូមចូលទៅទទួលព្រះរាជអាជ្ញា ទោះតែអស់ជីវិតទៅចុះ ។ គុនយីបានស្ដាប់ស៊ុនសេនជាព្រះរៀមថាដូច្នោះ ក៏ថាខ្លួនខ្ញុំមិនព្រមស្លាប់ទេ ព្រោះខ្ញុំមិនមានសេចក្ដីទុច្ចរិតអ្វីសោះ ថាហើយក៏លបរត់ចេញពីស្រុកគ្រុង ។ ឯស៊ុនសេនក៏ចូលទៅទទួលទោស ឲ្យបណ្ដានាម៉ឺនមុខមន្ត្រីចាប់ខ្លួនយកទៅប្រហារជីវិតតាមជម្រាស ។

អំណើះតមក ព្រះចៅជិនហៀនកុងទ្រង់ទិវង្គត ។ ហ៊ុយបនីងតុកជូក៏បានសោយរាជសម្បត្តិដល់ ១៩ ឆ្នាំ ។ ឯគុនយីដែលរត់ទៅនៅក្រៅដែននោះ ក៏ជ្រើសរើសទាហានប្រុសប្រៀបរៀបក្បួនទ័ពជាច្រើន ហើយលើកចូលមកដល់ទីក្រុង ក៏ច្បាំងវាយយកស្រុក ចាប់ហ៊ុយបនីងតុកជូ សម្លាប់ចោល គុនយីក៏បានសោយរាជសម្បត្តិជំនួសព្រះបិតាជាដំណាត

មក ៗ និតានេះអ្នកក៏បានដឹងអស់ហើយថា ដែលនឹងនៅក្នុងស្រុកនោះ ក៏មែនមានភ័យអន្តរាយដូចរឿងនេះ បើចេញទៅនៅស្រុកក្រៅក៏គង់ត្រឡប់បានការជាក្រោយ ឥឡូវស្រុកកាំងហែក៏នៅទំនេរគ្មានខ្លួនចៅហ្វាយស្រុក អ្នកចូររិះគិតអង្វរឡៅប៉ៀវជាបិតា សូមទៅនៅរក្សាស្រុកកាំងហែស្រួលជាងនៅក្នុងទីនេះ ហើយត្រូវខំស្វាហាប់ធ្វើសេចក្ដីព្យាយាមឲ្យដូចគុនឃើញទៅចុះ តះទៅអនាគតនោះ គង់នឹងបានសេចក្ដីសុខតទៅ ឡៅតីបានស្ដាប់ដូច្នោះ ក៏មានសេចក្ដីសោមនស្សត្រេកអរ ក្រោកឡើងលុតជង្គង់គំនាប់ខុងបេងហើយថា ដែលលោកមានប្រសាសន៍ណែនាំពន្យល់ឲ្យខ្ញុំបាទដឹងដូច្នេះ មានគុណធ្ងន់ជាទីបំផុត ខ្ញុំបាទនឹងសូមរិះគិតធ្វើតាមប្រសាសន៍លោកគ្រប់ប្រការ ខុងបេងក៏លាឡៅតីទៅរកឡៅពីពណ៌នាសេចក្ដីឲ្យឡៅពីស្ដាប់ តាមដែលបានណែនាំពន្យល់ឡៅតីនោះសព្វគ្រប់ប្រការ ៗ

លុះវេលាព្រឹកឡើង ឡៅតីក៏ចូលទៅនិយាយនឹងបិតាថា ឥឡូវស៊ុនគ្លួនក៏ងាប់ហង់ចស្លាប់ទៅហើយ ឯស្រុកកាំងហែក៏នៅទំនេរ ខ្ញុំបាទនឹងសូមចេញទៅឈររក្សា ៗ ឡៅប៉ៀវនៅស្ងៀមមិនទាន់តបថាប្រការម្ដេច ក៏ឲ្យហៅឡៅពីទៅប្រឹក្សាតាមពាក្យឡៅតី ៗ ឡៅពីឆ្លើយថា ឯស្រុកកាំងហែនោះ ក៏ជាទីមាំមួនដែរ ដែលឡៅតីនឹងសូមទៅនៅឈររក្សានោះគួរណាស់ ព្រោះជាទីជាយខេត្តដែលស៊ុនគ្លួនចូលនឹងមក ៗ (មានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់

## ដើមកំណើតរបាំ

### ស៊ិន-ហ៊ាន រៀបរៀង

ការលេងរបាំ ជាប្រពៃណីមានមកយូរអង្វែងហើយ ក្នុងពួកមនុស្សគ្រប់ជាតិគ្រប់សាសន៍ ទូទៅក្នុងពិភពលោកនេះ សុទ្ធសឹងតែមានវិធីរាំទៅតាមវិស័យនៃជាតិរបស់ខ្លួនទាំងអស់ កុំថាឡើយតែពួកមនុស្ស សូម្បីតែពួកសត្វតិរច្ឆានក៏មានវិធីរាំរបស់វាដែរ ។ ន័យនេះយើងអាចសង្កេតឃើញបានដោយងាយ ដូចយ៉ាងសត្វទាំងឡាយមានមាន់ទីងទ្អកជាដើម កាលណាវាបានជួបប្រទះអារម្មណ៍ជាទីសប្បាយរីករាយហើយ កាលនោះវាក៏សំដែងអាការលោត ហក់កញ្ឆេង តែក្រោយដោយលំនាំផ្សេងៗរបស់វា, កិរិយាដូច្នេះឯង ឈ្មោះថាការរាំរបស់ពួកសត្វតិរច្ឆាន ។ អាស្រ័យហេតុនេះ ទើបអ្នកប្រាជ្ញគិតស្រាវជ្រាវរកហេតុដើមនៃការរាំ ហើយសម្រេចសន្និដ្ឋានថា ការរាំនេះមានមូលហេតុកើតមកអំពីវិស័យសត្វ ក្នុងកាលដែលបានទទួលអារម្មណ៍ជាសុខ ឬជាទុក្ខដោយពិតប្រាកដ គឺថាសត្វទាំងនោះកាលទទួលអារម្មណ៍ខ្លាំងក្លាមិនអាចទប់បាន ក៏បណ្តាលចេញមកជាកិរិយាផ្សេងៗ ឲ្យប្រាកដខាងក្រៅឡើង ៗ ឧទាហរណ៍ ដូចតារកវេលាបានទទួលអារម្មណ៍ជាសុខ ក៏លោតហក់សំដែងកិរិយាសប្បាយរីករាយ,

កាលបានទទួលអារម្មណ៍ជាទុក្ខ ក៏យំរែកបម្រះនទៀត សំដែងកិរិយាឲ្យឃើញថាមិនសប្បាយ លុះធំដឹងក្តីឡើងហើយ កិរិយាដែលទទួលនូវអារម្មណ៍ក៏រើរតែមានច្រើន រហូតដល់សំដែងនូវតម្រេកក្នុងកាមារម្មណ៍ដែលជាទីគាប់ចិត្ត និងសំដែងនូវកិរិយាព្យាបាទចងក្រោធជាដើម ដែលមិនជាទីគាប់ចិត្ត, កិរិយាដែលបានទទួលនូវអារម្មណ៍ទាំងនេះ កប់ថាជាមូលហេតុនៃការកំ ។

មនុស្សទាំងឡាយដឹងនូវតបំណងផ្សេងៗ នៃការកំដែលមានលំនាំដូចពោលមកហើយ ទើបប្រឌិតយកកិរិយាអម្បាលនោះមកប្រើហាក់ដូចជាកាសាយ៉ាំ, កាលបើត្រូវការនឹងសំដែងឲ្យប្រាកដដល់អ្នកដទៃដោយទឹកចិត្តក៏ ឬដោយកិច្ចកលមាយាក្នុងវេលាលេងសើចក្តី ក៏សំដែងកិរិយានោះ ជាគ្រឿងបំភាល់នៃអារម្មណ៍នោះៗ ដូចយ៉ាងសំដែងពីសេចក្តីស្នេហា ក៏ធ្វើកិរិយាញាក់ញ័រញ៉ាំញើ ញញឹមញញែម, សំដែងពីសេចក្តីត្រេកអរសប្បាយចិត្ត ក៏លេចចេញមកជាកំប្លែង ឬសំដែងពីកិរិយាខឹងឬធ្វើឲ្យគេខ្លាច ក៏ធ្វើមុខក្រញូវក្អេកក្អរ ឡោតលោតទន្ទ្រំជាដើម ទើបកើតទៅជាបែបបទក្បាច់ក្បួនដើមហេតុនៃរបាំឡើង ។

លំដាប់តមកទៀត ពួកអ្នកឈ្លាសវៃចេះជ្រើសរើសយកនូវកិរិយាដែលសំដែងទៅតាមអារម្មណ៍ផ្សេងៗនោះ មកបង្គ្រងរៀបរៀងឲ្យជាប់តាក់តង់គ្នាជាក្បាច់កំ ដើម្បីឲ្យឃើញល្អនឹងជាទីត្រូវចិត្តនៃអ្នកមើលទូទៅ

ទើបកើតមានជាតម្រាំ ជាប្រពៃណីការកាំឡើងតាមលំដាប់កាល ។

សេចក្ដីដែលបានពោលមកប៉ុណ្ណេះ, តែងមានជាធម្មតារបស់មនុស្សគ្រប់ជាតិ, ទើបកើតមានទំនៀមកាំតាមក្បួនដែលជាតិរបស់ខ្លួននិយមឃើញថាល្អនោះៗឡើង ។ រីឯទំនៀមកាំនេះ ចំពោះប្រទេសកម្ពុជា មិនមែនគ្រាន់តែសម្រាប់ហាត់ពួកអ្នកប្រកបការរកស៊ីដោយស្រែចំការប៉ុណ្ណោះទេ គឺអំពីដើមមកតែងមានសម្រាប់បុគ្គលដ៏មានបណ្ដាស័ក្តិគ្រប់ជាន់ រហូតដល់ទៅក្នុងការសង្គ្រាម នឹងពិធីការផ្សេងៗជាច្រើនយ៉ាង ដែលធ្លាប់មានមកក្នុងប្រទេសនេះ ដូចយ៉ាងក្នុងតម្រាគជសាស្ត្រ ដែលគេរាប់ថាជាវិជ្ជាជាន់ខ្ពស់មួយយ៉ាងសម្រាប់ការសង្គ្រាមក្នុងសម័យបុរាណរបស់ខ្មែរ : ស្ដេចសឹក ឬមេទ័ព ដែលត្រូវហាត់ជិះដំរីប្រដល់គ្នា ក៏ត្រូវហាត់កាំលើខ្នងដំរីឲ្យសង្ហាផង សូម្បីតែព្រះពជាម្ចាស់ផែនដី ក៏ទ្រង់ហាត់កាំដែរ សឹងមានដរាបមកដល់ជួ-កាលព្រះករុណា ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ (ព្រះបរមរាជានុកោដ្ឋ) ។ ការកាំក្នុងយុទ្ធពិធីដទៃទៀត ដូចយ៉ាងហាត់គុនក៏ជាវិជ្ជាមួយយ៉ាង ដែលព្រះមហាក្សត្រនឹងអ្នកមានបណ្ដាស័ក្តិគ្រប់ជាន់ តែងហាត់មកអំពីដើមដែរ ។ តាមន័យដែលបានពោលមកនេះ បង្ហាញឲ្យឃើញថា អំពីបុរាណគេប្រកាន់ថា ការកាំនេះជាអង្គការមួយក្នុងការសិក្សាសម្រាប់ប្រទេសជាតិ, ទើបមានទំនៀមហាត់កាំទូទៅគ្រប់ជាន់នៃបុគ្គល ដែលមានបណ្ដាស័ក្តិ ។

វេលាក្រោយតមក, ការកាំនេះធ្លាក់ទៅជាសម្បត្តិរបស់បុគ្គលជាពួកៗ

ដោយច្រើន គឺធ្វើការបង្វឹកបង្ហាត់ជាប់មុខជាពួករៀងៗខ្លួន, ការដែលទុកដាក់ឲ្យតែបុគ្គលពួកខ្លះហាត់រាំនោះ ដោយបំណងចង់ឲ្យបានឃើញល្ខោនដែលល្អបំផុត ទើបជ្រើសរើសយកតែពួកខ្លះ មកបង្ហាត់ឲ្យស្ទាត់ចំពោះតែការរាំប៉ុណ្ណោះ សម្រាប់ទីនាំសំដែងឲ្យមនុស្សទាំងឡាយមើល ។ ការបង្ហាត់ដែលបានបែបបល្អហើយ, កាលចេញទៅសំដែងក្នុងទីប្រជុំជន រមែងជាទីត្រេកចិត្តត្រេកអរនៃជនានុជនទាំងពួង ទើបកើតមានអ្នករាំឡើងមួយពួកជាប់ដោយឡែក តែដែលពិត វិជ្ជារាំល្ខោនមកតែអំពីទំនៀមរបស់បុគ្គលអ្នកមានបណ្ដាស័ក្តិ ក្នុងជាន់ដើមនោះឯង ។

វិធីរាំលេងក្នុងប្រទេសកម្ពុជានេះ គួរញែកចេញជាពីរពួក គឺល្ខោនក្រៀង ១, ល្ខោនរាយរង ១ ។ ល្ខោនរាយរងនេះមានច្រើនបែបទៅទៀត ដូចល្ខោនទាល-យីកេ-ឆាប៉ី-ឆាយ៉ៃជាដើម តែរបាំម្យ៉ាងនេះសូមទុកតែប៉ុណ្ណោះ នឹងពណ៌នាចំពោះតែល្ខោនក្រៀងតទៅ ។

ក្បួនរាំដែលខ្មែរយើងរាំលេងតាំងអំពីដើម រហូតមកដល់សព្វថ្ងៃនេះ ច្បាប់ដើម ឬ ដើមបែបបានមកពីប្រទេសឥណ្ឌៀ ដោយក្នុងកាលនោះខ្មែរយើងចេញចាកប្រទេសឥណ្ឌៀមកនៅក្នុងប្រទេសកម្ពុជានេះ បានទាំងនាំក្បួនរាំដែលហៅថានាដសាស្ត្រនោះមកផង ។

ពួកឥណ្ឌូគេប្រកាន់ថា ការរាំជារបស់ព្រះឥសូរជាម្ចាស់ទ្រង់ប្រឌិតរាំឡើង ហើយទ្រង់បង្ហាត់បង្រៀនដល់ពួកមនុស្ស ឲ្យរាំក្នុងពិធីផ្សេងៗ

ដើម្បីមង្គលសួស្តី, អ្នកណាកំប្ត ឲ្យមានការកាត់តាមទេវបញ្ញត្តិឈ្មោះថា បានទទួលនូវមង្គលសួស្តីនឹងបានសុគតិភពទៅថ្ងៃមុខ ។

តាមរឿងនោះមានសេចក្តីតំណាលថា តម្រាកាំដែលហៅថានាងសាស្ត្រ នេះ ជារបស់ព្រះឥសីឈ្មោះគារគៈ បានតុបតែងឡើងជាបំបួងដោយបាន រៀបរៀង ទៅតាមបែបបទរបស់ព្រះឥស្វរ ដែលជាគ្រូដើម លោកកំទីងទ្រង់ប្រទានបែបបទទុកតមក ដូចមានប្រាកដក្នុងគោលិយៈបុរាណម៍ សំដែង អំពីរឿងរ៉ាវដែលព្រះឥស្វរទ្រង់តែងតាំងតម្រានាងសាស្ត្រថា ក្នុងសម័យមួយ មានឥសីមួយពួក តាំងអាស្រមនៅជាមួយភរិយាក្នុងព្រៃឈ្មោះតារកៈ លុះកាលយូរមកឥសីទាំងនោះ បានប្រព្រឹត្តអនាចារ ពុំដោយគន្ធងច្បាប់ទេវបញ្ញត្តិ ពុំកោតក្រែងព្រះឥស្វរជាម្ចាស់, ព្រះឥស្វរទ្រង់ខ្ញាល់ ទើបបបួលព្រះនារាយណ៍ស្តេចចុះមកឋានមនុស្សលោក ដើម្បីនឹងទូន្មានពួកឥសីនោះ, ព្រះឥស្វរទ្រង់ប្លែងភេទជាយោគីកម្លោះ ឲ្យព្រះនារាយណ៍ប្លែងភេទជាប្រ-ពន្ធក្រមុំ មានសរីរូបមុខគួរពេញទាំងពីរអង្គបានស្តេចតម្រង់ទៅឯព្រៃតារកៈ ពួកឥសីឃើញហើយ ក៏មានសេចក្តីស្រឡាញ់នាងនារាយណ៍ ៗ បំណែក ពួកភរិយាឥសីក៏កើតសេចក្តីស្រឡាញ់យោគីកម្លោះតែពល់ៗគ្នា ក៏កើតទៅជារឿងវិវាទគ្នាឡើងយ៉ាងកោលាហល ដោយអំណាចពាក់ះបណ្តាល ៗ ពួកឥសីនោះនាំគ្នាចែចង់នាងនារាយណ៍យ៉ាងដូចម្តេច ក៏មិនបានសម្រេចតាមបំណងឡើយ ។ ពួកឥសីក៏ក្រោធខឹង ទើបនាំគ្នាដាក់បណ្តាសា

ព្រះជាម្ចាស់ទាំងពីរអង្គ ដោយមិនដឹងច្បាស់ថា ព្រះជាម្ចាស់ទាំងពីរអង្គនឹងត្រូវអន្តរាយដូចបណ្ដាសារបស់ខ្លួនក៏ទេ ។ ពួកឥសីនិម្មិតខ្លួនទៅជាសត្វខ្លាដើម្បីចាំយោគីកម្លោះនឹងនាងនាគយណ៍ជាភរិយា, យោគីកម្លោះដែលជាតួព្រះឥសូរ ក៏សម្លាប់ខ្លានោះពន្លាត់យកស្បែកធ្វើជាប្រមខ្នួ (កម្រាលអង្គុយ), ពួកឥសីនិម្មិតខ្លួនទៅជានាគ ដើម្បីព្រួសពិសសម្លាប់ព្រះជាម្ចាស់, ព្រះឥសូរក៏ចាប់យកនាគនោះមកធ្វើជាសង្វា ទើបគេសាងរូបព្រះឥសូរឡើងមានដណ្ដប់ស្បែកខ្លាពាក់សង្វានាគ ដោយមានរឿងមកដូច្នេះឯង ។ ពួកឥសីទាល់គំនិតនឹងធ្វើអន្តរាយតទៅទៀតក៏នៅស្ងៀម, ព្រះឥសូរឃើញពួកឥសីអស់ឫទ្ធិហើយ ទើបទ្រង់រាំធ្វើជាបាដិហារ្យដោយព្រះអង្គឯងយ៉ាងអស្ចារ្យ ។ ខណៈនោះ មានយក្សតមមួយឈ្មោះមុយកល ស្ទុះចូលទៅជួយពួកឥសី, ព្រះឥសូរក៏លើកព្រះបាទជាន់លើខ្នងយក្សតមនោះ ហើយទ្រង់ឈររាំទាល់តែអស់ក្បាច់រាំ , ពួកឥសីក៏អស់ទិដ្ឋិមានះសុខចិត្តទទួលទោស ក្រាបបង្គំទូលសុំទោសចំពោះព្រះជាម្ចាស់ទាំងពីរអង្គ ។ កាលព្រះឥសូរទ្រង់ទូន្មានពួកឥសីរួចហើយ ទ្រង់ស្ដេចយាងត្រឡប់ទៅឯភ្នំកៃលាស ព្រះនាគយណ៍ក៏ទ្រង់ស្ដេចយាងត្រឡប់ទៅឯក្សីរសមុទ្រដែរ ។

គ្រាកាលដែលស្ដេចយាងទៅបង្ក្រាបពួកឥសីនោះ, ស្ដេចអនន្តនាគរាជ បានតាមហែព្រះនាគយណ៍ទៅផង បានឃើញព្រះឥសូរទ្រង់រាំល្អចំឡែក ជាទីគាប់ចិត្តពន់ពេក លុះតាមព្រះនាគយណ៍ត្រឡប់ទៅដល់

គ្រីសមុទ្រវិញ នៅតែទឹកចង់មើលចង់ឃើញព្រះឥសូររាំទៀត ទើបទូលរឿងរ៉ាវនោះដល់ព្រះនារាយណ៍ៗក៏ត្រាស់ថា យើងទាំងទៅទូលសុំអញ្ជើញព្រះឥសូរឲ្យទ្រង់រាំទៀតនោះមិនបានទេ បើយើងត្រូវការចង់មើលចង់ឃើញព្រះឥសូរទ្រង់រាំទៀត យើងគោរពធ្វើយញ្ញពិធីបូជាទៅដល់ភ្នំកៃលាស ឲ្យព្រះឥសូរទ្រង់ព្រះមេត្តាប្រោសប្រទានពរសិន ទើបទូលសុំពរឲ្យបានមើលព្រះអង្គទ្រង់រាំម្តងទៀតតាមបំណង ៗ ស្តេចអនន្តនាគរាជក៏ធ្វើតាមព្រះរាជបន្ទូលព្រះនារាយណ៍ទ្រង់តម្រាស់ណែនាំ ដោយអំណាចយញ្ញពិធីរបស់ស្តេចអនន្តនាគរាជនោះ ក៏បណ្តាលជាកំដៅទៅដល់ព្រះឥសូរ ៗ ក៏ស្តេចយាងចុះមកប្រទានពរថា ស្រេចហើយតែអនន្តនាគរាជត្រូវការរបស់អ្វី ឲ្យរើសយករបស់នោះចុះ នឹងទ្រង់ប្រសិទ្ធិឲ្យបានសម្រេចដូចបំណង ៗ ស្តេចអនន្តនាគរាជ ទើបក្រាបបង្គំទូលថា របស់ទាំងពួងដែលមាននៅក្នុងត្រៃភពនេះ ទូលព្រះបង្គំមិនចង់បានទាំងអស់ទេ សូមឲ្យតែទ្រង់ព្រះមេត្តាប្រោសប្រទានពរមួយយ៉ាង គឺឲ្យបានឃើញព្រះអង្គទ្រង់រាំម្តងទៀត ៗ ព្រះឥសូរទទួលពាក្យហើយត្រាស់ថា ស្តេចនឹងចុះទៅរាំឲ្យមនុស្សលោកមើលនៅដំបន់ចិទម្ពរម ដែលជាផ្នែកណ្តាលនៃពិភពលោក ព្រមដោយទេពនិករជាបរិវារ ទ្រង់និម្មិតសុវណ្ណសាលា ហើយទ្រង់រាំគ្រប់ក្បាច់រាំ តាមដែលទ្រង់ប្រទានពរដល់ស្តេចអនន្តនាគរាជនោះ ៗ រាប់ថាទ្រង់ប្រទានពរតម្រា-នាដសាស្ត្រទុកក្នុងមនុស្សលោកយើងនេះ តាំងពីនោះមកជាគ្រាដំបូង ៗ

លុះសម័យតមកទៀត ព្រះឥសូរស្តេចប្រថាប់នៅកណ្តាលទេវសភា លើភ្នំកៃលាស ទ្រង់មានព្រះរាជបំណងធ្វើសំដែងពិធីវិធីទុកឲ្យជាបែបច្បាប់ ទើបអញ្ជើញព្រះកុមារទេវី ឲ្យឡើងទៅប្រថាប់ជាប្រធានលើសុវណ្ណបល្ល័ង្ក ឲ្យព្រះសរស្វតីទេពីរបស់ព្រះព្រហ្មជាអ្នកដេញពិណ ឲ្យព្រះឥន្ទ្រជាអ្នកផ្លុំខ្លុយ ឲ្យព្រះព្រហ្មគោះឈឹង ឲ្យព្រះលក្ស្មីទេពីរបស់ព្រះនារាយណ៍ជាអ្នកច្រៀង ឲ្យព្រះនារាយណ៍វាយគោន ព្រះឥសូរទ្រង់រាំដោយព្រះអង្គឯង ឲ្យទេវតា ឥសី គន្ធព យក្ខនឹងនាគទាំងឡាយ ដែលឡើងទៅគាល់បានមើលម្តងទៀតទូទៅគ្រប់គ្នា ។ ទ្រង់រាំរួចហើយ ទ្រង់ព្រះបញ្ជាការគេ ឥសី ឲ្យមកតែងក្បួនរាំប្រដាប់ពួកមនុស្ស ឲ្យហាត់រាំតាមបែបដែលព្រះជាម្ចាស់ទ្រង់រាំប្រទានឲ្យមើលក្នុងគ្រានោះ ។

ដោយអាស្រ័យមានរឿងនិទានដំណាលមកដូច្នេះ, ពួកឥណ្ឌូប្រកាន់ថា នៅស្រុកចិទម្ព័រម្បិតនៅក្នុងប្រទេសឥណ្ឌៀប៉ែកខាងត្បូង គឺក្នុងដែនមទ្រាស ជាកន្លែងដែលព្រះឥសូរស្តេចចុះមករាំក្នុងលោក លុះយូរមកគេគិតសាងរូបព្រះឥសូរតំណាងកាយស្តេចរាំនោះ ហៅថានាដរាជ ប្រែថា ស្តេចរាំ ហើយក៏ទ្រង់បញ្ជាឲ្យយកបែបសាងនោះទៅសាងផ្សាយទូទៅក្នុងប្រទេសដែលកាន់សាសនាព្រាហ្មណ៍ ។ ក្នុងប្រទេសកម្ពុជាយើងនេះ ក៏មានសាងជាច្រើនណាស់ដែរ ព្រោះជាតិខ្មែរយើងក៏ជាប់ពូជពីជនជាតិឥណ្ឌៀ ដែលធ្លាប់កាន់សាសនាព្រាហ្មណ៍មកអំពីដើមនោះ

ដែរ ៗ កាលបើជនពួកនោះមកនៅក្នុងប្រទេសនេះហើយ ក៏ដោយតាំងទំនៀមទម្លាប់នោះមកផង ដូចមានបុរាណវត្ថុផ្សេង ៗ មានទេវរូបជាដើម នៅប្រាសាទបុរាណអង្គរវត្តរបស់យើងជាភស្តុតាងស្រាប់ ៗ នៅស្រុកចិទម្ព័រមនោះ មានទេវស្ថានមួយគេសាងទុកឡើងកាលពីពុទ្ធសករាជប្រមាណ ១៨០០, ចម្លាក់ប្រថាប់ស៊ុំគេឆ្លាក់ជារូបព្រះឥសូរទ្រង់រាំជាក្បាច់រាំផ្សេង ៗ ចំនួន ១០៨ ក្បាច់ ឬ ១០៨ បែប, តាមបែបដែលមានមកក្នុងគម្រាំរបស់ភារតៈឥសី ៗ ឯក្បាច់រាំតាំង ១០៨ បែបនោះ ចៅភ្នាក់ងារម្នាក់ក្នុងដែនមទ្រវដ្ឋបានផ្តិត ចំឡងយកមកបោះពុម្ពផ្សាយ កាលពីគ្រិស្ត-សករាជ ១៩១៤ មានទាំងឈ្មោះក្បាច់រាំជាភាសាសំស្ក្រឹត ព្រមទាំងពាក្យអធិប្បាយ ៗ

បរិយាយពីដើមកំណើតរបាំចប់តែប៉ុណ្ណេះ ។

**ផ្នែកនាំណាត់និងប្រវត្តិការណ៍**

## ពិធីបុណ្យពុទ្ធជយន្តិ នៅប្រទេសជប៉ុន

នៅក្រុងតូក្យូប្រទេសជប៉ុន បានរៀបចំធ្វើបុណ្យពុទ្ធជយន្តិ គឺបុណ្យរំលឹកពុទ្ធសករាជ ២៥០០ ចំនួន ៥ ថ្ងៃ ផ្តើមធ្វើនៅថ្ងៃទី ២៧ បង្ហើយនៅថ្ងៃទី ៣១ ខែមីនា ពុទ្ធសករាជ ២៥០១ គ្រិស្តសករាជ ១៩៥៩ នេះ ។

តាមសេចក្តីអញ្ជើញពីប្រទេសជប៉ុន ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់សព្វព្រះរាជហឫទ័យ បាតតាំងគណៈប្រតិភូ ១ ទៅរួមរួមក្នុងពិធីបុណ្យនោះ ។

គណៈប្រតិភូនេះ មានចំនួន ៣ រូបគឺ

- លោក យៀន-ចឹម អគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ ប្រធាន;
- ព្រះគ្រូ ថាច់-ប្រាង ឥន្ទបញ្ញោ ដំណាងគណៈមហានិកាយ សមាជិក;
- ព្រះបមុខវង្ស សុខ-យ៉ឹន ញាណទីបោ ដំណាងគណៈធម្មយុត្តសមាជិក ។

គណៈប្រតិភូនេះ ក្រោយពីពេលបុណ្យពុទ្ធជយន្តិ នឹងធ្វើដំណើរទស្សនាបូជនីយដ្ឋាននានា ក្នុងប្រទេសជប៉ុនអស់ថេរវេលាចំនួន២សប្តាហ៍ ។

គណៈប្រតិភូនេះ បានចេញដំណើរទៅឡើងអាកាសយាន នៅចំណតអាកាសយានពោធិចិនតុង វេលាម៉ោង ៨ កន្លះព្រឹក ថ្ងៃទី ២២ ខែមីនា នេះ ឆ្ពោះទៅកាន់ក្រុងតូក្យូនៅចំពោះមុខវរសមណៈនិងវរជនទាំងឡាយ

ទាំងព្រះសង្ឃគណៈមហានិកាយជាច្រើនអង្គ មានព្រះតេជព្រះគុណព្រះពោធិវង្សប្រធានហ្វានពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតជាដើម គណៈធម្មយុត្តជាច្រើនអង្គ មានព្រះធម្មត្រៃលោកាចារ្យ កែត-គោ ជាដើម, ខាងគ្រហស្ថមានលោកទីប្រឹក្សាបច្ចេកទេស នឹងលោកលេខាធិការនៃស្ថានឯកអគ្គរាជទូតប្រទេសជប៉ុន ប្រចាំប្រទេសកម្ពុជា, លោក អ៊ុក-ឈុំ នាយកមន្ទីរ លោកទៀងតាយ-ឈុន នាយខុទ្ទកាល័យ លោក ប៉ះ-ប៊ុក នាយការិយាល័យនៃក្រសួងធម្មការ នឹងបុគ្គលិកក្រុមពុទ្ធសាសនបណ្ឌិត្យជាដើម ដែលយើងសូមអភ័យទោសដោយពុំបានរាយនាមសព្វគ្រប់ នឹងក្រុមគ្រួសាររបស់លោកយៀន-ចឹម, បុនិមន្ត បានអញ្ជើញជូនដំណើរដល់ចំណតអាកាស-យាន ដោយបំពេញឋានៈកិត្តិយសរបស់ប្រទេសពុទ្ធសាសនិក ដំណាងពុទ្ធបរិស័ទទូទៅ នឹងបំពេញឋានៈមិត្តភាពរវាងគណៈប្រតិភូពុទ្ធសាសនាទាំង ៣ រូប ដ៏ប្រកបដោយសេចក្ដីរីករាយយ៉ាងជ្រាលជ្រៅ ។

គណៈប្រតិភូខ្មែរទាំង ៣ រូបនេះ បានទៅរួមក្នុងពិធីបុណ្យ ព.ស. ២៥០០ នៅក្រុងតូក្យូ នឹងខែត្រនានានៃប្រទេសជប៉ុន ហើយបានត្រឡប់មកដល់ចំណតអាកាសយានពោធិចិនតុងវិញនៅថ្ងៃទី២០ខែមេសា១៩៥៩ វេលាម៉ោង ១៧ ដោយសុវត្ថិភាព ។

ក្នុងពេលនោះ យើងបានសង្កេតឃើញ ផ្នែកខាងបព្វជិតមានព្រះតេជព្រះគុណព្រះពោធិវង្ស អគ្គាធិការនៃពុទ្ធិកសិក្សា ព្រមទាំងព្រះសង្ឃ

ទាំងពីរគណៈ-ផ្នែកខាងគ្រហស្ថ មានលោកតំណាងក្រសួងធម្មការ និងអ្នករាជការទាំងឡាយនៃក្រុមពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងគ្រួសារនិងញាតិមិត្រជាច្រើនរបស់លោកប្រធាន និងរបស់សមាជិកនៃគណៈប្រតិភូៗ

ក្រោយដែលបានប្រស្រ័យឆ្លើយឆ្លងសណ្ឋារកិច្ចគួរសម ចំពោះព្រះសង្ឃ-គ្រហស្ថ និងគ្រួសារញាតិមិត្ររួចហើយ, គណៈប្រតិភូក៏បានឡើងរថយន្តមកកាន់រាជធានីវិញ ៗ

គណៈប្រតិភូខ្មែរនៃពិធីបុណ្យ ព.ស.២៥០០ នៅប្រទេសជប៉ុន សូមថ្វាយព្រះរាជកុសល ដែលបានទៅបំរើកិច្ចក្នុងពិធីបុណ្យនោះ ចំពោះព្រះករុណា ជាអម្ចាស់ជីវិតនិងសម្តេចព្រះមហាក្សត្រិយានី សូមព្រះអង្គគង់នៅ-ជាសុខក្នុងសិរីរាជសម្បត្តិ មួយអន្លើដោយព្រះរាជវង្សានុវង្ស អស់កាលជាយូរអង្វែងតទៅ ព្រមទាំងសូមព្រះរាជកុសលនេះ ទៅជួយឧបត្ថម្ភសម្តេចព្រះឧបយុវរាជព្រះបិតាឯករាជ្យជាតិ ដែលទ្រង់កំពុងព្យាបាលព្រះរោគព្រះអង្គឯប្រទេសបារាំង, សូមបានទ្រង់ជាសះស្បើយព្រះរោគដោយឆាប់រហ័ស និងបានទ្រង់និវត្តមកកាន់ប្រទេសកម្ពុជា ក្នុងពេលឆាប់ៗ សូមអស់និស្សិតខ្មែរនៅឆ្ងាយពីប្រទេសកម្ពុជា សូមបានប្រកបដោយសុភមង្គលសិរីសួស្តីគ្រប់យ៉ាង ៗ

ពត៌មានផ្សេងៗ របស់ក្រសួងធម្មការ

## អំពីការតាំងឋានានុក្រមសម្រាប់ព្រះសង្ឃ

- បានតាំងភិក្ខុ ប៉ក់-ឆេង ឲ្យឡើងជាវិ.មុហ៍ វត្តលង្កា ក្រុងភ្នំពេញ ។

- បានតាំងភិក្ខុ សួន-សៀម ឲ្យឡើងជាវិសមុហ៍ឃោសាភិ វត្តលង្កា ក្រុងភ្នំពេញ ។

- បានតាំងភិក្ខុ យស់ ផាត់ ឲ្យឡើងជាទីព្រះគ្រូឃោសបណ្ឌិត សម្រាប់វត្តលង្កា ក្រុងភ្នំពេញ ។

- បានតាំងភិក្ខុ សូ ប្រាក់ ជាព្រះវិន័យធរ វត្តមុនីសេដ្ឋា ឃុំសិង ស្រុកសំពេន ខែត្រតាកែវ ។

- បានតាំងភិក្ខុ សោម-វឿន ជាព្រះបាឡាត់ពុទ្ធរក្ខិតសហការី របស់ព្រះពុទ្ធវង្ស វត្តឧណ្ណាលោម សង្កាត់លេខ ៣ ក្រុងភ្នំពេញ ។

## អំពីការតាំងចៅអធិការ -គ្រូសូត្រស្តាំ-ឆ្វេង

- បានតាំងភិក្ខុ គង់-អ៊ុក ជាចៅអធិការវត្តចំបក់ប៉ិចមាស ឃុំពត់ស ស្រុកបាទី ខែត្រតាកែវ ។

- បានតាំងភិក្ខុ សូត-យុន ជាចៅអធិការវត្តព្រៃផ្អាវ ឃុំរទាម ស្រុកទ្រាំង ខែត្រតាកែវ ។

-បានតាំង ភិក្ខុ ហ៊ិន សេក ជាចៅអធិការវត្តពោធិ ឃុំទ្រាល ស្រុកបារាយណ៍ ខេត្តកំពង់ធំ ៖

-បានតាំងភិក្ខុ ខៀវ-យោ ជាគ្រូសូស្តាំ វត្តបំបក់បិទមាស ឃុំពត់ស ស្រុកបាទី ខេត្តតាកែវ ។

-បានតាំងភិក្ខុ យឹម-អែល ជាគ្រូសូត្រឆ្វេង វត្តបំបក់បិទមាស ឃុំពត់ស ស្រុកបាទី ខេត្តតាកែវ ។

-បានតាំងភិក្ខុ ប៉ែន-សន ជាគ្រូសូត្រស្តាំ វត្តកំពង់ក្ដុក ឃុំកំពង់ក្ដុក ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

x x x

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

អជយ បុ. អជ័យ, កិរិយាចាញ់ ។

អជយ្យ គុ. ដែលគេមិនគប្បីឈ្នះបាន។

អជរ គុ. ដែលមិនគ្រាំគ្រា, មិនរលិ, មិនសឹក។

អជរាមរ គុ. ដែលមិនចាស់នឹងមិនស្លាប់ ។

អជយ៌ នបុ. មិត្រភាព ។

អជស្រ គុ. ដែលមិនដាច់គ្នា, រដឹក, ជានិច្ច ។ អជស្រម, អស់កាលជានិច្ច ។

អជាគរ គុ. ដែលមិនភ្ញាក់, ដែលដេកលក់ ។

អជាជី ស្ត្រី. ដើមអជាជី (គេដាំយកគ្រាប់ ទុំនក្រអូប) ។

អជាត គុ. ដែលមិនទាន់កើត,ដែលមិនទាន់មាន។ – *បក្ស* គុ. ដែលមានស្លាបមិនទាន់ដុះហើយ ។ – *រជស* គុ. ដែលមានលំអង ឬ ធុលីមិនមាន ។ – *លោម* គុ. ដែលមានរោមមិនទាន់ដុះហើយ ឬ ដែលមានរោមមិនដុះហើយ ។ – *វ្យញ្ជន* គុ. ដែលមានព្យញ្ជនៈមិនទាន់កើតហើយ ( មនុស្សមិនទាន់ពេញជាកំលោះ ឬ ក្រមុំ, ដើមឈើមិនទាន់ដល់នូវចេញផ្លែផ្កា ) ។ – *ឝត្រុ* គុ. ដែលមានសត្រូវមិនមាន; បុ. ព្រះនាមព្រះបាទយុធិឞ្ឋិរ, ព្រះនាមព្រះរាជាដែនកាសី ។ – *សារ* គុ. ដែលមានសារមិនមាន ។ អជាតារិ, បុ. ព្រះនាមព្រះបាទយុធិឞ្ឋិរ ។